ហុកសិបឆ្នាំនៃការប្រយុទ្ធ

ប្រឆាំងនឹងភាពក្រីក្រជា

សកល

# ការរឹតត្បិតសិទ្ធ ស្ត្រីពលករចំណាកស្រុកនៅ ប្រទេសថៃ កម្ពុជា និងម៉ាឡេស៊ី



## War on Want គឺជាចលនារបស់មនុស្សដែលបានតាំងចិត្តដើម្បីភាពយុត្តិធម៌ជាសកល

ទស្សនៈវិស័យ របស់យើង គឺដើម្បីសកលលោកមួយ ដែលរួចផុតពីភាពក្រីក្រ និងភាពកេងប្រវញ្ច័ជិះជាន់ ដោយផ្អែកតាមយុត្តិធម៌សង្គម ភាពស្មើគ្នា និងសិទ្ធិមនុស្សសម្រាប់ទាំងអស់គ្នា។

បេសកកម្ម របស់យើងគឺដើម្បីធ្វើការប្រយុទ្ធប្រឆាំងនឹងមូលហេតុសំខាន់ៗបណ្ដាលឲ្យមានភាពក្រីក្រ និងការប្រើហិង្សាផ្នែកសិទ្ធមនុស្ស ដែលជាផ្នែកមួយនៃចលនាពិភពលោកសម្រាប់យុត្តិធម៌ជាសកល។

**យើងអាចសម្រេចកិច្ចការទាំងនេះដោយ:**

- ធ្វើការជាដៃគូជាមួយចលនាសង្គម ពាណិជ្ជកម្ម សហជីព និងស្ថាប័នកម្មករជាច្រើន ដើម្បីផ្ដល់អំណាចដល់ពួកគេក្នុងការប្រយុទ្ធប្រឆាំងដើម្បីសិទ្ធិរបស់គេ។
- ធ្វើយុទ្ធនាការសាធារណៈដែលនិយមធ្វើច្រើនជាងគេ និងមានលក្ខណៈតស៊ូស្វិតស្វាញ ដើម្បីប្រយុទ្ធប្រឆាំងនឹងមូលហេតុបណ្ដាលឲ្យមានភាពក្រីក្រ និងការប្រើហិង្សាលើសិទ្ធិមនុស្ស។
- ធ្វើការចល័តការគាំទ្រ និងកសាងសម្ពន្ធ័ភាពជាមួយនឹងសកម្មភាពនានាក្នុងការគាំទ្រសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរបស់កម្មករ។
- បង្កើនចំណេះដឹងដល់សាធារណៈជនអំពីមូលហេតុសំខាន់ៗ ដែលបណ្ដាលឲ្យមានភាពក្រីក្រ ភាពខ្វះខាតនិងអយុត្តិធម៌ និងពង្រឹងអំណាចប្រជាពលរដ្ឋក្នុងការធ្វើសកម្មភាពដើម្បីផ្លាស់ប្ដូរ។

**ចូលរួមជាមួយយើងទាំងអស់គ្នា**

ជ័យជំនះសម្រាប់ការងាររបស់យើង គឺផ្អែកទៅលើការជួយលើកទឹកចិត្តឲ្យមានការចូលរួមក្នុងការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងការរំលោភបំពានសិទ្ធមនុស្ស។ មានមធ្យោបាយចំនួន ៣ ដែលមានលក្ខណៈងាយស្រួលសម្រាប់អ្នក ក្នុងការចូលវិភាគទាន និងចូលរួមក្នុងចលនានេះតាមរយៈ៖

**ទូរស័ព្ទ** ០២០ ៧៣២៤៥០៤០

**ចូលទៅកាន់គេហទំព័រ** www.waronwant.org/support-us

**តាមរយៈប្រៃសណីយ៍៖** សម្រាប់សមាជិកភាពសូមផ្ញើទៅកាន់អាសយដ្ឋាន ដែលនៅផ្នែកខាងក្រោយនៃរបាយការណ៍នេះនឹងផ្ញើទៅកាន់:

War on Want

44-48 Shepherdess Walk London NI 7JP

# អារម្ភណ៍កថា

កម្មករចំណាកស្រុក បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យជោគជ័យផ្នែកសេដ្ឋកិច្ចនៃប្រទេសជាច្រើនក្នុងតំបន់អាស៊ីអាគ្នេយ៍ករយៈពេលថ្មីៗនេះ ដែលប្រទេសទាំងនេះ បានឱបក្រសោប និងផ្តោតជាសំខាន់ " ការវិលត្រលប់ទៅកាន់ពិភពខាងក្រៅ " ក្នុងដំណើរស្វែងរកទិសដៅនៃការនាំចេញកម្មករចំណាកស្រុក ដែលជាការផ្តល់ធនធានពលកម្មដ៏ទៀងទាត់មួយ គឺកំលាំងពលកម្ម ដែលមានតម្លៃថោក ដែលនេះបានអនុញ្ញាត ឲ្យចង្វាក់ផលិតកម្មឧស្សាហាកម្ម ទទួលបានជោគជ័យក្នុងទីផ្សារពិភពលោក។ ជាពិសេសស្ត្រីចំណាកស្រុ ដែលប្រកបកិច្ចការ ដែលមានលក្ខណៈលំបាកខ្លាំង និងជាកិច្ចការដែលកម្មករក្នុងស្រុកមិនចង់ធ្វើ ។ ប្រទេសថៃ ប្រទេស កម្ពុជា និងម៉ាឡេស៊ីទទួលអត្ថប្រយោជន៍ដ៏ធំសម្បើមខាងផ្នែកសេដ្ឋកិច្ចពីការចូលរួមរបស់ពលករចំណាកស្រុក។

នៅប្រទេសកម្ពុជា ៩០ ភាគរយនៃកម្មករនៅរោងចក្រកាត់ដេរ គឺជាស្ត្រីវ័យក្មេងដែលបានចាកចេញពីតំបន់ជនបទមកកាន់ទីក្រុង។ ចំណាកស្រុកដែលមកពី ប្រទេសជិតខាង គឺជាធនធានកំលាំងពលកម្មដ៏សំខាន់ និងមានតំលៃថោកសម្រាប់ឧស្សាហាកម្មនាំចេញរបស់ប្រទេសថៃ និង ប្រទេសម៉ាឡេស៊ី។ ប៉ុន្តែទោះបីជាមានការចូលរួមពីពួកគេយ៉ាងនេះក៏ដោយ ក៏ប្រទេសទាំងនោះបានធ្វើការបដិសេធដូចគ្នា ក្នុងការធានាពីសិទ្ធិ និងសុវត្ថិភាព ដែលពលករចំណាកស្រុកត្រូវទទួលបាន។ របាយការណ៍ដែលបង្ហាញពីលទ្ធផលនៃការស្រាវជ្រាវថ្មីមួយអំពីជីវភាពរស់នៅ និងស្ថានភាពដែលស្ត្រីចំណាកស្រុកជួប្រទះនៅក្នុងប្រទេសថៃ កម្ពុជា និង ប្រទេស ម៉ាឡេស៊ី។ ជាពិសេសរបាយការណ៍នេះបានបង្ហាញអំពីរបកគំហើញ ដែលមានលក្ខណៈជាស៊េរី ដែលបានមកពីការសំភាសន៍ស្ត្រីពលករចំណាកស្រុក (ភាគច្រើនក្នុងចំណោមពួកគេ គឺជាយុវវ័យ) នៅក្នុងប្រទេសនីមួយៗខាងលើនោះ។ កិច្ចសំភាសន៍នេះបានបង្ហាញឲ្យឃើញនូវព្រឹត្តការណ៍ជារួម នៃជីវភាព ដែលមានលក្ខណៈមិនទៀងទាត់របស់ស្ត្រីចំណាកស្រុក ដោយសារតែការគៀបសង្កត់និងការកេងប្រវ័ញ្ច ដែលស្ថិតក្នុងដៃរបស់និយោជកដែលមិនស្មោះត្រង់។ ក្រុមហ៊ុនជាច្រើនដែលមកពីប្រទេសលោកខាងលិច ក៏កំពុងតែទាញយកផលចំណេញពីការរំលោភបំពានលើកម្មករស្ត្រីចំណាកស្រុក ដែលនឹងត្រូវបង្ហាញជាលំអិតនៅក្នុងរបាយការណ៍នេះ។ ជាមួយនឹងក្រុមហ៊ុនជាច្រើនដែលមានម៉ាកល្បីៗ ដូចជាក្រុមហ៊ុន Adidas Nike Reebok and Levi-Strauss លក់ទំនិញដែលផលិតក្នុងប្រទេសទាំងបីនេះ។ ក្នុងខណៈពេលដែល

កំលាំងពលកម្មមានតម្លៃថោក បានធ្វើឲ្យប្រទេស កម្ពុជាក្លាយជាប្រទេសប្រភព ក្នុងការផលិតសំលៀកបំពាក់ដែលមានតម្លៃថោកសម្រាប់ហាងសំលៀកបំពាក់ដែលមានម៉ាកល្បីៗដូចជា Gap Zara Marks & Spencer and H&M ។ ចំណែកកម្មករនៅរោងចក្រឧស្សាហកម្មអេឡិចត្រូនិចនៅប្រទេសម៉ាឡេស៊ីផ្តល់ការផ្គត់ផ្គង់ដល់ទីផ្សារដែលនាំមុខគេទូទាំងពិភពលោក។ War on Want ជឿជាក់ថា ស្រ្តីកម្មករចំណាក ស្រុកនៅតំបន់អាស៊ីអាគ្នេយ៍ ក៏ដូចជាកម្មករទាំងអស់ មានសិទ្ធិក្នុងការទទួលបានប្រាក់ឈ្នួលដែលអាចទ្រទ្រង់ជីវភាពរស់នៅរបស់គេ និងសិទ្ធិក្នុងការប្រកបការងារ ដែលមានលក្ខខ័ណ្ឌសមរម្យ។ ជាការខុសសម្រាប់ប្រទេសដូចជាប្រទេសថៃ ប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី ដែលពឹងផ្អែកលើកម្លាំងពលកម្មនៃកម្មករទាំងនោះក្នុងការទទួលបានជោគជ័យផ្នែកសេដ្ឋកិច្ច តែបែរជាបដិសេធមិនធានាការពារសិទ្ធិ សូម្បីតែសិទ្ធិរស់នៅជាមូលដ្ឋានរបស់កម្មករក៏ដោយ។ ដូច្នេះវាមិនមានភាពស្មើភាពគ្នាទេ សម្រាប់ក្រុមហ៊ុននៅប្រទេសលោកខាងលិចមួយចំនួន ដើម្បីទទួលបានប្រាក់ចំណេញបានប្រើហិង្សាទៅលើសិទ្ធិរបស់កម្មករចំណាកស្រុក នៅក្នុងសង្វាក់នៃផលិតកម្មផ្គត់ផ្គង់របស់ពួកគេ។ អ្នកអានទាំងអស់ត្រូវបានលើទឹកចិត្តឲ្យចូលរួមដើម្បីធ្វើសកម្មភាព ដែលនឹងត្រូវបានដាក់ក្នុងបញ្ជីនៅផ្នែកចុងក្រោយបំផុតនៃរបាយការណ៍នេះ ដើម្បីធានាឲ្យមានភាពយុត្តិធម៌ សម្រាប់ស្រ្តីកម្មករចំណាកស្រុកនៅប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ និងនៅក្នុងពិភពលោក។

***John Hilaw***

# សេចក្តីសង្ខេប

ក្នុងកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រែក្លាយជាការប្រកួតប្រជែងដែលមានលក្ខណៈជាសកលប្រទេសកម្ពុជា និងប្រទេសម៉ាឡេស៊ី បាននឹងកំពុងតែផ្តោតជាសំខាន់ទៅលើទិសដៅនៃការនាំចេញសង្វាក់ផលិតកម្មឧស្សាហាកម្ម ដែលផ្អែកទៅលើកំលាំងពលកម្មដែលមានតម្លៃថោក ហើយដែលជាញឹកញាប់ គឺកម្លាំងពលកម្មរបស់កម្មករចំណាកស្រុក។ រដ្ឋាភិបាលក្នុងប្រទេសនីមួយៗទាំងនោះ បានបង្កើតគោលនយោបាយ ដែលជួយទៅដល់វិស័យឧស្សាកម្ម និងគិតគូរជាពិសេសក្នុងការដាក់ឲ្យមាកិច្ចការពារផ្សេងៗ ដល់ការធ្វើពាណិជ្ជកម្ម ដែលវាអាចជា បញ្ហាប្រឈមសម្រាប់កម្មករ ក្នុងការទទួលបានការការពារ និងជំនួយ នៅពេលដែលគេទទួលបានប្រើប្រាស់សិទ្ធរបស់ខ្លួនក្នុងការប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ច ។ ក្នុងប្រទេសកម្ពុជា ស្ត្រីវ័យក្មេងបានចាកចេញពីភូមិកំណើត ដើម្បីធ្វើការក្នុង វិស័យ នេះ ខណៈពេលដែលនៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី កំពុងមានលំហូរចូលកម្លាំងពលកម្មនៃជនចំណាកស្រុកមកពីប្រទេសជិតខាង ។ ទោះបីជាការធ្វើចំណាកស្រុកនាំឲ្យមាននិរន្តភាពនៃការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ចក៏ដោយ ក៏ភាពនាំមុខនេះមិនត្រូវបានទទួលការលើទឹកចិត្ត ឬ ធ្វើការសម្របសម្រួលឲ្យបានប្រសើរឡើយ។ នៅក្នុង ប្រទេសថៃ និងម៉ាឡេស៊ី គោលនយោបាយទេសន្តប្រវេសន៍ជាធរមានមួយចំនួនត្រូវបានអនុមត័ឡើងក្នុងគោលបំណងរិតត្បិតចំនួនប្រជាជន ក្នុងការចូលទៅក្នុងប្រទេសរបស់ពួកគេ និងរក្សាស្ថានភាពមិនអចិន្ត្រៃយ៍នៃការរស់នៅរបស់ជនចំណាកស្រុកទាំងនោះ។ ហេតុដូចនេះ ប្រព័ន្ធជំនួយដែលលួចលាក់ ត្រូវបានបង្កើតឡើងដើម្បីជួយដល់កម្មករ ដែលរួមមានមេខ្យល់ជាអ្នករៀបចំការធ្វើដំណើរស្វែងរកការងារសម្រាប់កម្មករ និងបង្កើតឲ្យមានប្រព័ន្ធសម្រាប់ការផ្ញើប្រាក់កម្រៃមកផ្ទះ។ នៅពេលដែលប្រព័ន្ធនេះមានប្រសិទ្ធិភាព និងមានលក្ខណៈជាជំនួញនោះ អ្នកធ្វើជំនួញទាំងឡាយបានដាក់ជនចំណាកស្រុកក្នុងស្ថានភាពមួយ ដែលមានគ្រោះថ្នាក់ និងសម្រាប់តែភាពចំណេញរបស់ពួកគេតែប៉ុណ្ណោះ។ នៅពេលចូលក្នុងវិស័យនៃការប្រកបការងារភ្លាម កម្មករចំណាកស្រុកមិនត្រូវបានផ្តល់ការងារមួយ ដែលមានប្រសិទ្ធិភាពឡើយ។ ជនចំណាកស្រុក ត្រូវរស់នៅមិនអចិន្ត្រៃយ៍ និងក្នុងស្ថានភាពមួយដែលមិនទៀងទាត់ (ដែលនេះជាការផ្តល់ភាពងាយស្រួល និងអត្ថប្រយោជន៍ទៅដល់និយោជក ដែលអាចជួលកម្លាំងពលកម្ម ឬ បណ្តេញកម្មករចេញស្របទៅតាមតែតម្រូវការនៃទំនិញ ហើយដែលនាំឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ជនចំណាកស្រុកទាំងការរស់នៅក្នុងពេលបច្ចុប្បន្ន និងពេលអនាគតរបស់ពួកគេ ។

របាយការណ៍នេះ នឹងផ្តោតជាពិសេសទៅលើស្ត្រី ដែលធ្វើចំណាកស្រុកទៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី និងការធ្វើចំណាកស្រុកនៅក្នុងប្រទេសរបស់ប្រទេសកម្ពុជា ក្នុងការស្វែងរកការងារនៅក្នុងរោងចក្រកាត់ដេរ និងរោងចក្រឧស្សាហកម្ម ដែលផលិតអេឡិចត្រូនិច។ ស្ត្រីភាគច្រើនបានធ្វើចំណាកស្រុកដើម្បីតែការរស់រានផ្នែកសេដ្ឋកិច្ចតែប៉ុណ្ណោះ ប៉ុន្តែសម្រាប់ជនចំណាកស្រុកភូមាវិញ ដែលមានប្រជាជន ជាជនភៀសខ្លួន ការធ្វើចំណាកស្រុករបស់ពួកគេ គឺដើម្បីរត់គេចខ្លួនពីការសង្កត់សង្កិនផ្នែកនយោបាយ និងការចោទប្រកាន់នានា នៅក្នុងប្រទេសភូមា។ សម្រាប់កម្មករទាំងអស់ គឺជាដើមទុនមួយសំខាន់ ដែលផ្តល់ផលចំណេញយ៉ាងសម្បើមសម្រាប់ក្រុមហ៊ុនជាច្រើន។ ពួកគេបានចាកចេញពីគ្រួសារ និងមិត្តភក្តិ ហើយជាញឹកញាប់ពួកគេបានខ្ចីបុល ឬ ក៏លក់ទ្រព្យសម្បត្តិរបស់ខ្លួន ដើម្បីធ្វើដំណើរ និងស្វែងរការងារ ហើយគេបានចាកចេញដោយមានការប្តេជ្ញាចិត្តថា ពួកគេមិនអាចត្រលប់មកភូមិកំណើតវិញដោយដៃទទេបានទេ។ ការតស៊ូដើម្បីទទួលបានសិទ្ធិ គឺជាបញ្ហាប្រឈមដ៏ធំសម្រាប់ពួកគេ ដែលវាជាការប្រឈម នឹងភាពប្រថុយប្រថានក្នុងការបាត់បង់ការងារ ជីវភាពរស់នៅ និងកិត្តិយស ព្រមទាំងប្រឈមមុខនឹងគ្រោះថ្នាក់ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ក្នុងការដោះបំណុលវិញ។ និយោជិក និង អ្នកបណ្តាក់ទុន បានដឹងពីបញ្ហានេះ ប៉ុន្តែនៅតែធ្វើការកេងប្រវ័ញ្ច និងបង្កភាពលំបាកដល់ជីវភាពរស់នៅនៃជីវិតរស់នៅរបស់កម្មករចំណាក ដោយមិនមានភាពភ័យខ្លាចក្នុងការប្រឈមមុខនឹងច្បាប់ឡើយ។ រដ្ឋាភិបាលក៏បានដឹងពីបញ្ហានៃភាពងាយរងគ្រោះរបស់ពួកគេ ប៉ុន្តែមិនអាចផ្តល់ការការពារដល់ពួកគេឲ្យបានពេញលេញឡើយ។ ជាការពិត មានករណីក្នុងករណីជាច្រើនបានបង្ហាញឲ្យឃើញពីភាពអសមត្ថភាពរបស់រដ្ឋាភិបាលក្នុងការធានា និងការពារសិទ្ធិដល់កម្មករ សូម្បីតែករណីដែលមានលក្ខណៈធម្មតាក៏ដោយ ដែលជាការបង្ហាញអោយឃើញពីភាពកំសោយក្នុងការអនុវត្តន៍ច្បាប់ការងារមួយ ប្រកបដោយប្រសិទ្ធិភាព។ កម្មករបាន ប្រឈមមុខ នឹងការរិតត្បិតសិទ្ធិ ដែលជាឧបសគ្គសម្រាប់ពួកគេក្នុងការប្រើប្រាស់សិទ្ធិរបស់ពួកគេ ។ ការរិតត្បិតផ្នែកច្បាប់ ដូចជានៅប្រទេសថៃជាដើម ឬ ការរិតត្បិតសេវាសង្គម ដែលបណ្តាលមកពីគោលគំនិតដើមនៃការធ្វើកិច្ចសន្យាដែលមិនអចិន្ត្រៃយ៍ ឬ ស្ថានភាពដែលមិនមានសុវត្ថិភាព ដែលរារាំងកម្មករចំណាកស្រុកក្នុងការបង្កើតសហជីព និងហាមឃាត់ពួកគេមិនអោយចូលរួមក្នុងបណ្តាញសកម្មជនដ៏សំខាន់ ដើម្បីតទល់ក្នុងការទទួលបានលក្ខខ័ណ្ឌការងារមួយដែលមានលក្ខណៈល្អប្រសើរ ។ ជនចំណាកស្រុកត្រូវបានផ្តល់ឲ្យអត្ថប្រយោជន៍ផ្នែកច្បាប់តិចតួចពីការបង្កើត និងការកំណត់អត្តសញ្ញាណច្បាប់នៅក្នុងប្រទេសគោលដៅរួមទាំងការរិតត្បិតផ្សេងៗ ដូចជាការទទួលបានប័ណ្ណបើកបរសម្រាប់ការធ្វើដំណើរ ការបង្កើតព្រឹត្តិការណ៍ ឬ ការជួបជុំក្នុងទ្រង់ទ្រាយធំៗ និងការបើកគណនីធនាគារជាដើម។ ការស្រាវជ្រាវមួយរបស់ War on Want នេះ បានរកឃើញថា ឧស្សាហកម្មរោងចក្រកាត់ដេរ និងវាយនភ័ណ្ឌនៅក្នុង

ប្រទេសកម្ពុជា ប្រទេសម៉ាឡេស៊ី និងប្រទេសថៃ និងឧស្សាហកម្ម ផ្នែកអេឡិចត្រូនិចក្នុងប្រទេសម៉ាឡេស៊ី ដែលមានករណីជាច្រើនបានបង្កឲ្យមានគ្រោះថ្នាក់អំពីការបង្ខំកម្មករឲ្យធ្វើការដែលទទួលបានប្រាក់ឈ្នួលតិច និងមិនមានលក្ខណៈស្តង់ដារ លក្ខខណ្ឌការងារដែលមិនសមរម្យ ជាពិសេសសម្រាប់ស្ត្រីកម្មករចំណាកស្រុក។ ការស្រាវជ្រាវត្រូវបានរកឃើញថា កម្មករមិនមានកិច្ចសន្យាការងារ ឬ មិនដឹងថាគេនឹងកំពុងធ្វើការនៅកន្លែងណា ដែលនេះជាកិច្ចសន្យាមិនស្របតាមផ្លូវច្បាប់ឡើយ។ កម្មករធ្វើការជាទៀងទាត់ ១០ ម៉ោងក្នុង ១ ថ្ងៃ ដោយមិនមានប្រាក់ឧបត្ថម្ភលើការងារថែមម៉ោងនេះទេ ហើយពួកគេជួបប្រទះនឹងការបៀតបៀនផ្សេងៗនៅកន្លែងការងារ ដែលជាការងារមិនមានសុវត្ថិភាព និងជាការងារ ដែលមិនមានលក្ខខណ្ឌសមរម្យ ហើយបែជាទូលបានប្រាក់ឈ្នួលទាបជាងតម្រូវការចាំបាច់សម្រាប់ការរស់នៅរបស់ពួកគេទៅវិញ។ពួកគេត្រូវបានហាមឃាត់ មិនឲ្យសុំច្បាប់ឈប់សម្រាក និងការចេញទៅក្រៅពីបរិវេណរោងចក្រទោះក្នុងពេលកំពុងមានផ្ទៃពោះក៏ដោយ។ ពួកគេអាចប្រឈមមុខនឹងការផាកពិន័យ ពេលគេសុំឈប់សម្រាក មកដល់កន្លែងធ្វើការយឺត និងទៅបន្ទប់ទឹក និងកិច្ចការតូចៗផ្សេងៗទៀតដែលនេះ ត្រូវបានចាត់ទុកថាជាការរំលោភបំពាន។

ទោះបីប្រាក់ឈ្នួលទាបខ្លាំងយ៉ាងណាក៏ដោយ កម្មករជាច្រើននៅតែមានគោលបំណងក្នុងការសន្សំ ដើម្បីអាចមានលទ្ធភាពផ្ញើថវិកាមកផ្ទះ តាមរយៈ ការខិតខំរិតត្បិតក្នុងការចំណាយលើចំណីអារហាររបស់ពួកគេ។ ប្រាក់ដែលផ្ញើមកផ្ទះមិនគ្រប់គ្រាន់សម្រាប់ទ្រទ្រង់តម្រូវការជាមូលដ្ឋាននៃគ្រួសាររបស់ពួកគេឡើយ និងក៏មិនគ្រប់គ្រាន់សម្រាប់ធ្វើអោយស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់ពួកគេផ្លាស់ប្តូរដែរ។ គោលនយោបាយសេដ្ឋកិច្ច ដែលពាក់ព័ន្ធនឹងកង្វះខាតនៃការអនុវត្តន៍ច្បាប់ស្តីពីការងារបានលាក់បាំងតម្លៃសង្គមសម្រាប់ស្ត្រី ដែលធ្វើដំណើរឆ្លងកាត់ប្រទេស ឆ្លងកាត់ព្រំប្រទល់ និងឆ្លងទ្វីបក្នុងការស្វែងរកការងារដែលសមរម្យ និងស្វែងរកជីវភាពរស់នៅដោយមានសុវត្ថិភាពដើម្បីជួយទ្រទ្រង់ខ្លួនឯង និងគ្រួសាររបស់ពួកគេ។ War on Want ជឿជាក់ថា ស្ត្រីទាំងនេះក៏ដូចជាកម្មករទាំងអស់មានសិទ្ធិ ក្នុងការទទួលបានប្រាក់បៀវត្សន៍សម្រាប់ទ្រទ្រង់ជីវភាពរស់នៅ និងលក្ខខ័ណ្ឌការងារសមរម្យ។ យើងជម្រុញអោយអ្នកអានរបាយការណ៍នេះចូលរួមជាមួយយើងក្នុងការប្រយុទ្ធប្រឆាំងដើម្បីធ្វើអោយការទាមទារសិទ្ធិរបស់ពួកគេជាការពិត។

# ទេសន្តរប្រវេសន៍នៃតំបន់អាស៊ីអាគ្នេយ៍

ការធ្វើចំណាកស្រុក គឺជាវិធីសាស្ត្រក្នុងការទទួលបានការងារជាចំបងនៅតំបន់អាស៊ីអាគ្នេយ៍ និងជាផ្នែកមួយនៃការអភិវឌ្ឍន៍របស់រដ្ឋាភិបាល ជាផែនការសេដ្ឋកិច្ច និងការរស់នៅនៃបុគ្គលម្នាក់ៗ ។ ប្រទេសប្រភពសំខាន់ៗរួមមានៈ ហ្វីលីពីន ឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា វៀតណាម និងកម្ពុជា។ ជនចំណាកស្រុកពីប្រទេសទាំងនេះធ្វើចំណាកស្រុកទៅកាន់ប្រទេសដទៃទៀត នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសទៅប្រទេសម៉ាឡេស៊ី និងថៃ និងទៅកាន់តំបន់ខាងកើតសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក។ កាលពីពាទសវត្សរ៍កន្លងទៅ ប្រជាជនពីប្រទេសមីយ៉ាន់ម៉ា កម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានសម្រេចចិត្តគេចវេសពីភាព ក្រីក្រ និង ជម្លោះនយោបាយក្នុងប្រទេសរបស់ពួកគេ ដើម្បីឆ្លងព្រំប្រទល់ទៅកាន់ប្រទេសថៃ។ ពួកគេបានចាកចេញពីប្រទេសរបស់ពួកគេ ដោយមិនមានឯកសារសំរាប់រស់នៅ និង ប្រកបការងារនៅក្នុងប្រទេសថៃ ស្រដៀងគ្នា ទៅនឹងកម្មករចំណាកស្រុកដែលគ្មានឯកសារ ។ រដ្ឋាភិបាលនៃប្រទេសថៃបានធ្វើការឆ្លើយតប ដោយបានផ្តល់ការស្នាក់នៅសម្រាប់រយៈពេល ០១ឆ្នាំ ចំពោះជនចំណាកស្រុក ដែលបានចុះបញ្ជីជាមួយនឹងអាជ្ញាធរមូលដ្ឋាន ប៉ុន្តែនេះផ្តល់អោយត្រឹមតែស្ថានភាពផ្នែកច្បាប់ពាក់កណ្តាលតែប៉ុណ្ណោះ។ ជនចំណាកស្រុកត្រូវបានចាត់ទុកថា បានចូលទៅក្នុងប្រទេសដោយខុសច្បាប់ និងត្រូវបានធានាការអនុញ្ញាតអោយស្នាក់នៅចំនួន ០១ឆ្នាំ ក្នុងពេលដែលពួកគេត្រូវរង់ចាំការបញ្ជូនមកប្រទេសខ្លួនវិញ។ ការចុះបញ្ជីជាដំបូង គឺនៅឆ្នាំ ១៩៩២ និងចុងក្រោយបំផុតនៅខែមិថុនា ឆ្នាំ២០១១។ នៅឆ្នាំ២០០៣ នៅក្នុងការប៉ុនប៉ងធ្វើ អោយមានបទបញ្ញត្តិពាក់ព័ន្ធ នឹងស្ថានភាពរបស់ជនចំណាកស្រុកនៅប្រទេសថៃ អនុសារណៈនៃការយោគយល់ត្រូវបានធ្វើឡើង ជាមួយនឹងប្រទេសមីយ៉ាន់ម៉ាប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ តាមរយៈប្រព័ន្ធនេះ ជនចំណាកស្រុកអាចចាកចេញពីប្រទេសរបស់ខ្លួនដោយផ្ទាល់ដោយមិនចាំបាច់មានឯកសារ ឬ ពួកគេអាចធ្វើតាមប្រព័ន្ធនៃការផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេដោយស្នើសុំអោយប្រទេសប្រភព ចេញលិខិតឆ្លងដែនបណ្តោះអាសន្ន។ តាំងពីឆ្នាំ២០០៤ ជនចំណាកស្រុកចំនួន ១.២ លាននាក់ក្នុងចំណោមជនចំណាកស្រុកសរុបប្រហែល ២.៥លាននាក់មានឯកសារខ្លះៗ។ ប្រហែលជា ៥០% នៃជនចំណាកស្រុក គឺជាស្ត្រី។ នៅប្រទេសថៃកម្មករ ចំណាកស្រុកជាស្ត្រី

ត្រូវបានធ្វើការនៅក្នុងវិស័យខុសៗគ្នា រួមមានៈ កសិកម្មឧស្សាហកម្ម ការងារបំរើសេវាផ្លូវភេទ សាកវប្បកម្មផលិតកម្ម ការងារសំណង់ ការធ្វើអាហារសមុទ្រ និងការងារបំរើតាមផ្ទះ។

ប្រទេសជិតខាង ដូចជាប្រទេសម៉ាឡេស៊ីជាដើមមានកម្មករចំណាកស្រុក ដែលបានចុះបញ្ជីចំនួន១.៨លាននាក់ និងផ្សេងៗទៀតក្នុងរវាង ១លាននាក់ និង ២.៥លាននាក់ជាកម្មករដែលមិនមានឯកសារបន្ថែមទៅលើអ្នកដែលបានចុះបញ្ជី ។ កម្មករចំណាកស្រុកដែលមានឯកសារ និង មិនមានឯកសារធ្វើការនៅក្នុងវិស័យស្រដៀងគ្នារួមមានៈផលិតកម្មសំណង់ ដូងប្រេង ដំណាំកៅស៊ូ ការងារបំរើតាមផ្ទះ ការងារសេវាកម្ម និង កសិកម្ម ។ ជនចំណាកស្រុក ដែលមានឯកសារ ភាគច្រើនមកពីប្រទេសឥណ្ឌូនេស៊ី បង់ក្លាដេស នេប៉ាល់មីយ៉ាន់ម៉ា ឥណ្ឌា វៀតណាម កម្ពុជា និងហ្វីលីពីន។ ប្រទេសទទួលទាំងពីរមាន ប្រទេសថៃ និងប្រទេសម៉ាឡេស៊ី ទទួលយកជនចំណាកស្រុកពីប្រទេសកម្ពុជាទោះ បីជាកម្មករចំណាកស្រុកកម្ពុជាភាគច្រើនប្រហែល ២សែននាក់ នៅក្នុងប្រទេសថៃ ដែលគ្មានឯកសារបច្ចុប្បន្នកំពុងដំណើរការនៃការធ្វើឯកសារតាមរយៈដំណើរការផ្ទៀងផ្ទាត់សញ្ជាតិក្តី។ ការធ្វើចំណាកស្រុកដ៏ធំបំផុតសម្រាប់ប្រទេសកម្ពុជា គឺការធ្វើចំណាកស្រុកក្នុងប្រទេស។ តួយ៉ាងនៅឆ្នាំ២០០៩ មានជនចំណាកស្រុកក្នុងស្រុក ២.៥លាននាក់នៅប្រទេសកម្ពុជា ហើយភាគច្រើន គឺជាស្ត្រីវ័យក្មេងដែលមកពីតំបន់ជនបទដែលកំពុងប្រកបការងារ ជាប្រភេទការងារដែលប្រើកម្លាំងហើយទទួលបានប្រាក់ចំណូលទាប។ ប្រហែល ជា៩០% នៃកម្មកររោងចក្រកាត់ដេរនៅប្រទេសកម្ពុជា គឺជាស្ត្រីវ័យក្មេងដែលបានចាកចេញពីតំបន់ដាច់ស្រយាល។

ចរិកលក្ខណៈ នៃការធ្វើទេស្តប្រវេសន៍ក្នុងតំបន់អាស៊ីអាគ្នេយ៍ឆ្លុះបញ្ចាំងអោយឃើញ ពីនយោបាយសង្គម និងសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍នៃប្រទេសនីមួយៗ។ ការប្រៀបធៀប GDP នៅក្នុងតំបន់បាន ផ្តល់នូវរបកគំហើញនៃការអភិវឌ្ឍន៍រវាងប្រទេសៈ GDP របស់ម៉ាឡេស៊ី ៦៩៦៧ដុល្លារ ថៃ ៣៨៩៤ដុល្លារ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ៨៨៤ដុល្លារ កម្ពុជា ៧២៩ដុល្លារ និង មីយ៉ាន់ម៉ា ៣៨០ដុល្លារ។ មានប្រទេសចំនួន ៣ ត្រូវបានដាក់ក្នុងបញ្ជីដោយអង្គការសហប្រជាជាតិ ក្នុងចំណោមប្រទេសដែលអភិវឌ្ឍន៍យឺតបំផុតក្នុងពិភពលោក។ សមាគមអាស៊ីអាគ្នេយ៍ (ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ហ្វីលីពីន សឹង្ហបុរី ប្រ៊ុយណេ មីយ៉ាន់ម៉ា កម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និងវៀតណាម) ខិតខំសម្របសម្រួលដើម្បីភាពលូតលាស់ផ្នែកសេដ្ឋកិច្ចថ្នាក់តំបន់ និងដើម្បីមាន

សមត្ថភាពក្នុងការប្រកួតប្រជែងជាមួយនឹងប្រទេសដែលមានសេដ្ឋកិច្ចរឹងមាំដូចជា៖ សហភាពអឺរ៉ុប សហរដ្ឋអាមេរិក និងប្រទេសចិន។ ក្នុងកំឡុងពេលជាង ២ទស្សវត្សន៍កន្លងមក អាស៊ានបានខិតខំធ្វើការដើម្បីបង្កើនកិច្ចសហការសេដ្ឋកិច្ច និង លុបបំបាត់រាល់បញ្ហាប្រឈមក្នុងការធ្វើពាណិជ្ជកម្មក្នុងចំណោមប្រទេសសមាជិករបស់ខ្លួន និងដើម្បីធ្វើការទាក់ទាញការវិនិយោគបរទេសដោយផ្ទាល់ទៅក្នុងតំបន់។ លើសពីនេះទៅទៀត អាស៊ានបានចរចារកិច្ចព្រមព្រៀងពាណិជ្ជកម្មដោយសេរីជាមួយនឹងប្រទេសមួយចំនួនដូចជា ចិន ជប៉ុន កូរ៉េខាងត្បូង ឥណ្ឌា អូស្ត្រាលី និងប្រទេស ញូហ្សេឡែន។

ដើម្បីសម្រេចបានយុទ្ធសាស្ត្រ នៃការទាក់ទាញការធ្វើវិនិយោគដោយផ្ទាល់ពីបរទេស ដែលជាប្រភពដំបូងនៃចំណូល ប្រទេសជាសមាជិកអាស៊ានបានផ្តល់បុព្វសិទ្ធិដល់ វិនិយោគិនបរទេស និងបង្កើតអោយមានតំបន់សេដ្ឋកិច្ចពិសេស ដែលជាញឹកញាប់តំបន់ទាំងនោះត្រូវបានបង្កើតឲ្យមាននៅក្នុងតំបន់ជិតព្រំប្រទល់ ។ តំបន់សេដ្ឋកិច្ចពិសេស មិនត្រូវបានបង្កើតឡើងឲ្យមានគ្រប់ប្រទេសនោះទេជាមួយគ្នានេះផងដែ អាស៊ានក៏គិតគូរផងដែរ ពីការផ្តល់កម្លាំងពលកម្មដែលមានតម្លៃថោកមកពីប្រទេសជិតខាងដើម្បី ធ្វើការទាក់ទាញវិនិយោគិន នៅក្នុងការផ្តល់ការលើទឹកចិត្តផ្នែកកម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្ម។ ប្រទេសថៃ និង ប្រទេសកម្ពុជា ជាផ្នែកមួយនៃ គំរោងផ្តួចផ្តើមកម្មវិធីសេដ្ឋកិច្ចនៅក្នុងប្រទេសនៃអនុតំបន់ទន្លេមេគង្គ(GMS) ដែលធ្វើឡើងដោយធនាគារអភិវឌ្ឍន៍អាស៊ីឆ្នាំ១៩៩២ ដែលមានប្រទេស ៦ នៃប្រទេសអនុតំបន់ទន្លេមេគង្គដើម្បីពង្រីកទំនាក់ទំនងសេដ្ឋកិច្ច តាមរយៈការសម្របសម្រួល ការអភិវឌ្ឍនៃហេដ្ឋារចនាសម្ព័ន្ធ ។ យុទ្ធសាស្ត្រទាំងនេះអាចជួយបង្កើនការលូតលាស់ផ្នែកសេដ្ឋកិច្ច នៃប្រទេសជាច្រើនប៉ុន្តែមិនអាចជួយកម្មករ ដែលមានជំនាញទាបដោយប្រើកម្លាំងពលកម្ម ហើយក៏មិនអាចជួយកាត់បន្ថយភាពក្រីក្របានដែរ។ម្យ៉ាងទៀតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសតាមព្រំដែនទាំងនេះ ឬ មជ្ឈមណ្ឌលឧស្សាហកម្ម កម្មករចំណាកស្រុកដែលមានជំនាញទាបប្រឈមនឹងការរឹតត្បិតផ្នែកច្បាប់ទៅលើការដើរហើររបស់ពួកគេកំណត់ព្រំដែន ការចូលរួមក្នុងហេដ្ឋារចនាសម្ព័ន្ធសង្គម និងកង្វះខាតនៃឯកសារសម្រាប់ការធ្វើចំណាកស្រុក ឬ ការងារ។ ប្រទេសទាំង៣ ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះ ធ្លាប់មានបទពិសោធន៍នៅក្នុងការធ្វើចំណាកស្រុកផ្នែកសេដ្ឋកិច្ច ការធ្វើចំណាកស្រុកដោយបង្ខំ ការធ្វើចំណាកស្រុកនៅតំបន់ជនបទ និងជាយក្រុង និងការធ្វើចំណាកស្រុកដោយឆ្លងកាត់ព្រំដែន។ ជាពិសេសការលូតលាស់ផ្នែកសេដ្ឋកិច្ចភ្លាមៗ នៅក្នុងប្រទេសថៃ និងប្រទេសម៉ាឡេស៊ី ដោយសារតែមានការកើនឡើងនៃការវិនិយោគដោយផ្ទាល់ពីបរទេស បាន

បង្កើតអោយមានកង្វះខាតកម្លាំងពលកម្ម សម្រាប់ឧស្សាហកម្មនាំចេញ ដោយក្នុងនោះមានលក្ខខណ្ឌមួយចំនួនដូចជាកម្មករក្នុងស្រុកបដិសេធ មិនធ្វើការនៅក្នុងផ្នែកនេះ។ កង្វះខាតកម្លាំងពលកម្មត្រូវបានបំពេញបន្ថែមដោយកម្មករចំណាកស្រុក ដែលមានភាពរងគ្រោះខ្ពស់ ពីការកេងប្រវ័ញ្ច និងរើសអើង។ ប្រទេសកម្ពុជាបានក្លាយខ្លួនជាប្រទេស ដែលប្រជាជនជួបនឹងការលំបាកក្នុងការស្វែងរកសាច់ប្រាក់សម្រាប់តម្រូវការមូលដ្ឋាន ក្នុងជីវភាពកសិកម្មតាមទម្លាប់ ដូច្នេះពួកគេបានចាកចេញទៅកាន់ទីក្រុងដើម្បីស្វែងរកការងារនៅក្នុងមណ្ឌលឧស្សាហកម្ម។ ក្នុងអំឡុងពេលរដ្ឋាភិបាលនៃប្រទេសទាំង៣ ប្រែក្លាយខ្លួនឯងជាប្រទេសប្រកួតប្រជែងខ្លាំងជាងមុនស្របតាមតម្រូវការទីផ្សារ ជាជាងការខិតខំអនុវត្តច្បាប់ការងារដែលមានស្រាប់ ក្នុងការធានាលក្ខខណ្ឌល្អសម្រាប់កម្មករចំណាកស្រុក។ ម៉្យាងទៀតប្រាក់បៀវត្សទាបខ្លាំងការងារ ប្រភេទការងាររយៈពេលខ្លី និងសិទ្ធិត្រូវបានរឹតត្បិតត្រូវបានគេមើលឃើញជាបញ្ហាប្រឈមផងដែ ។ កម្មករចំណាកស្រុកជាពិសេសជួបនឹងការលំបាកនៃការប្រើអំពើហិង្សាលើសិទ្ធិរបស់គេតាមរយៈតុលាការ ដោយសារតែស្ថានភាពចំណាកស្រុករបស់ពួកគេ មិនមានភាពច្បាស់លាស់ និង ទៀងទាត់។ និយោជកជាច្រើន បញ្ឈប់ការងារចំណាកស្រុកប្រសិនបើពួកគេទាំងនោះ ធ្វើការទាមទារ អោយមានការគោរពសិទ្ធិសេរីភាព ហើយការបញ្ឈប់នេះបន្សល់ទុកអោយជនចំណាកស្រុកនៅក្នុងស្ថានភាពប្រឈមក្នុងការចាប់បញ្ជូនមកប្រទេសកំណើតវិញ ។ កម្មករចំណាកស្រុក គឺស្ថិតនៅក្នុងចំណោមក្រុមដែលងាយរងគ្រោះជាងគេដោយសារថា ពួកនិយោជិតមានជំនឿថាពួកគេអាចកេងប្រវ័ញ្ចកម្មករចំណាកស្រុកដោយសេរី។

## ការគេចប្រវ័ញ្ចនិងការផាត់ចេញនៅប្រទេសថៃ

មានកម្មករចំណាកស្រុកប្រហែល ២.៥លាននាក់ ដែលកំពុងរស់នៅ និងធ្វើការក្នុងប្រទេសថៃ៉ ជនចំណាកស្រុក ដែលមានចំនួនច្រើនជាងគេគឺមកពីប្រទេសមីយ៉ាន់ម៉ា ប៉ុន្តែក៏មានជនចំណាកស្រុកមកពីប្រទេសកម្ពុជា និងសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវផងដែរ។ ក្នុងចំនួនប្រហែល ៥០% នៃជនចំណាកស្រុក គឺជាស្ត្រី។ កម្មករស្ត្រីចំណាកស្រុកបានប្រកបការងារក្នុងវិស័យវាយនភ័ណ្ឌ និងរោងចក្រកាត់ដេរ ការងារបម្រើតាមផ្ទះ សំណង់ កន្លែងកំសាន្តសប្បាយ សេវាកម្ម ដំណាំកៅស៊ូ ចំការ ឧស្សាហកម្មនេសាទ និងក្នុងរោងចក្រផលិតអាហារសមុទ្រ។ ការលូតលាស់ផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័សនៅចុងឆ្នាំ១៩៨០ និង ឆ្នាំខាងមុខៗទៀត បានផ្តោតទៅលើគោលដៅសម្រាប់នាំចេញនៅក្នុងផលិតកម្ម និង ផលិតផលកសិកម្ម ដែលទាមទារឲ្យមានតម្រូវការកម្លាំងពលកម្ម ដែលមានតម្លៃថោក និងនាំទៅរកចំនួនដ៏ច្រើននៃចំនួនកម្មករអ្នកធ្វើចំណាកស្រុកចូលទៅក្នុងប្រទេសថៃពីប្រទេសជិតខាងខ្លួន។ ដោយសារតែវិបត្តិនយោបាយនៅក្នុងប្រទេសរបស់ខ្លួន ភាគច្រើនស្ទើតែទាំងអស់នៃចំនួនកម្មករចំណាកស្រុកនៅក្នុងប្រទេសថៃមិនមានឯកសារគ្រប់គ្រាន់។ តាំងពីឆ្នាំ ១៩៩២ រាជរដ្ឋាភិបាលថៃ បានឆ្លើយតបទៅនឹងការហូរចូលកម្មករចំណាកស្រុកដែលមិនមានឯកសារ ដោយអនុញ្ញាតិឲ្យកម្មករចំណាកស្រុកណា ដែលបានកំពុងតែធ្វើការនៅក្នុងប្រទេសថៃបានចុះបញ្ជីដើម្បីធ្វើការនៅក្នុងប្រទេសថៃបាយរយៈពេល ១ ឆ្នាំគិតពីថ្ងៃចុះបញ្ជី ដែលមានន័យថា ក្នុងអំឡុងពេលដែលពួកគេកំពុងរង់ចាំការចាប់បញ្ជូនត្រលប់មកប្រទេសខ្លួនវិញ។ នៅឆ្នាំ២០០៣ ប្រទេសថៃបានចុះហត្ថលេខាលើអនុសារណៈយោគយល់ជាមួយនឹងប្រទេសមួយចំនួន (ប្រទេសមីយ៉ាន់មា កម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតឡាវ) ដើម្បីធ្វើឲ្យមានភាពស្របច្បាប់ សម្រាប់ជនចំណាកស្រុកដែលបានរស់នៅ និងធ្វើការនៅក្នុងប្រទេសថៃ។ មានការព្រមព្រៀងគ្នាថា ប្រទេសប្រភពទាំងឡាយត្រូវបញ្ជូនមន្ត្រីទទួលបន្ទុកចូលមកក្នុងប្រទេសថៃដើម្បីធ្វើការផ្ទៀងផ្ទាត់សញ្ជាតិ និងផ្តល់លិខិតឆ្លងដែនបណ្តោះអាសន្ន។ ដំណើរការនេះមានការយឺតយ៉ាវ មានតម្លៃថ្លៃ និងមានអំពើពុករលួយ ។ ត្រឹមខែ មិនា ឆ្នាំ២០១១ កម្មករចំណាកស្រុកជាង ៤ សែននាក់ ក្នុងចំណោមកម្មករចំណាកស្រុកទាំងអស់ប្រហែល ២.៥ លាននាក់ក្នុងប្រទេសថៃប៉ុណ្ណោះ ដែលត្រូវធ្វើការផ្ទៀងផ្ទាត់ការទទួលបានសញ្ជាតិ។ វិស័យវាយនភ័ណ្ឌ និងផលិតកម្មសំលៀកបំពាក់ នៅតែបន្តជារោងចក្រឧស្សាហកម្មដែលធំជាងគេមួយក្នុងចំណោមរោងចក្រ

ផ្សេងទៀត នៅក្នុងប្រទេសថៃដែលមានកម្មករធ្វើការច្រើនជាង ១លាននាក់ និងបាននាំចេញប្រចាំឆ្នាំក្នុងតម្លៃច្រើន ជាង ៧កោដិដុល្លារ[iii]។ ការនាំចេញរបស់ប្រទេសថៃ មានចំនួន ៣៨% នៃវិស័យវាយនភ័ណ្ឌ និងរោចក្រកាត់ដេរទៅកាន់សហរដ្ឋអាមេរិច ៣០% ទៅកាន់សហភាពអឺរ៉ុប ៦% ទៅកាន់ប្រទេសជប៉ុន និង ផ្នែកដែលនៅសល់មាន ១៩ % ទៅកាន់អាហ្វ្រិក និងតំបន់មជ្ឈឹមបូព៌ា[iv]។ ម៉ាកសម្លៀកបំពាក់ដែលល្បីៗដែលមានប្រភពមកពីប្រទេសថៃមានដូចជា ម៉ាក Adidas Reebok Nike Levi Strauss Timberland និងBenetton[v]. វិស័យកាត់ដេររបស់ ប្រទេសថៃកំពុងតែបន្តស្វែងរកប្រភពធនធានកម្លាំង ពលកម្មដែលមានតម្លៃថោក។

## ២.១ បទពិសោធន៍ស្ត្រី

ការសំភាសន៍បានធ្វើជាមួយនឹងស្ត្រីចំណាកស្រុកចំនួន ២២ នាក់ដែលមកពីប្រទេសមីយ៉ាន់ម៉ាធ្វើការនៅរោងចក្រកាត់ដេរក្នុងប្រទេសថៃ។ កម្មករដែលជាស្ត្រីដែលក្មេងជាងគេ ដែលត្រូវបានសំភាសន៍សម្រាប់ធ្វើរបាយការណ៍នេះ អាយុ ១៧ ឆ្នាំ និងចាស់ជាងគេអាយុ ៥០ ឆ្នាំ ។ ចំនួនភាគច្រើននៃស្ត្រីទាំងនោះ (១២ ក្នុងចំណោម ២២) គឺមានអាយុចាប់ពី ១៧ ឬ១៨ ឆ្នាំ ។

ស្ត្រីទាំងអស់ដែលត្រូវបានសម្ភាសន៍ បានលើកឡើងថា ពួកគេសម្រេចចិត្តធ្វើចំណាកស្រុកដោយសារតែស្ថានភាពសេដ្ឋកិច្ច និងកង្វះឱកាសការងារ នៅប្រទេសមីយ៉ាន់ម៉ា ប៉ុន្តែក៏មានក្នុងករណីខ្លះ ដោយសារតែវិបត្តិនៅផ្ទះរបស់គេ ក៏ជាមូលហេតុធ្វើឲ្យពួកគេសម្រេចចិត្តធ្វើចំណាកស្រុកផងដែរ។ ខាងក្រោមនេះជាការលើកឡើងរបស់ស្ត្រីម្នាក់ ក្នុងចំណោមស្ត្រីផ្សេងទៀត ដែលបានចាកចេញពីទីក្រុងរ៉ង់ហ្គូន ប្រទេសមីយ៉ាន់ម៉ា ទៅកាន់ Mae Sot ប្រទេសថៃ:

*ស្ត្រីធ្លាប់ជាអ្នកធ្វើការក្នុងផ្ទះ បុរស គឺជាអ្នករកស៊ី ផ្គត់ផ្គង់ជីវភាពគ្រួសារ ប៉ុន្តែបច្ចុប្បន្នពួកគេត្រូវធ្វើការទាំងពីរនាក់ ដើម្បីជៀសវាងមិនឲ្យគ្រួសារជំពាក់បំណុលគេ។ ខ្ញុំបានធ្វើការលែងលះស្វាមីរបស់ខ្ញុំ។ ខ្ញុំមានកូន ២ នាក់ និងគ្រួសាររបស់ស្វាមីខ្ញុំមិនអនុញ្ញាតិឲ្យខ្ញុំបានជួបជាមួយនឹងកូនរបស់ខ្ញុំទេ។ ដោយសារតែបញ្ហានេះខ្ញុំមានការអស់សង្ឃឹម និងបានចាកចេញពីផ្ទះ។*

សម្រាប់ស្ត្រីផ្សេងទៀតជាច្រើន ដែល បានធ្វើការសម្រេចចិត្តក្នុងការធ្វើចំណាកស្រុកមកប្រទេសថៃ គឺដោយសារទទួលព័ត៌មានពីក្រុមគ្រួសារ និងមិត្តភក្តិ ដែលធ្លាប់មានបទពិសោធន៍ធ្វើ

ចំណាកស្រុក និងផ្តាំផ្ញើត្រលប់វិញ ពីភាពងាយស្រួល និងចំនួនប្រាក់ឈ្នួលដែលខ្ពស់បើប្រៀបធៀបនឹងប្រាក់ឈ្នួលរបស់ការងារក្នុងស្រុក។ រោងចក្រកាត់ដេរជាច្រើននៅក្នុងប្រទេសថៃ គឺស្ថិតនៅតាមបណ្តោយព្រំដែនប្រទេសថៃ និងប្រទេសមីយ៉ាន់ម៉ា ក្នុងតំបន់ភ្នំដែលទុកចោលមិនប្រើប្រាស់ សម្រាប់ការងារដឹកជញ្ជូនទំនិញទៅកាន់កំពង់ផែដែលនៅជិតបំផុត ។ ប៉ុន្តែបញ្ហាដែលមិនសម្ប និងធ្ងន់ធ្ងរបំផុតនោះ គឺដោយសារតែការផ្គត់ផ្គត់ជាបន្តបន្ទាប់នៃកម្មករចំណាកស្រុកពីប្រទេសមីយ៉ាន់ម៉ា (គឺជាប្រទេសប្រភពដែលផ្តល់កម្លាំងពលកម្មធំជាងគេមកក្នុងប្រទេសថៃ ដែលនិយោជកអាចធ្វើការកេងប្រវ័ញ្ចបានដោយសេរី)។

ច្បាប់ក្នុងការការពារកម្មកររបស់ប្រទេសថៃ ឆ្នាំ ១៩៩៨ បានចែងថា លក្ខខ័ណ្ឌការងារ និងដែនកំណត់នៃម៉ោងការងារ គឺ ៨ ម៉ោងក្នុង ១ថ្ងៃ ឬ ៤៨ ម៉ោងក្នុង ១សប្តាហ៍។ បន្ទាប់ពីការងារ ៨ ម៉ោង ការងារថែមម៉ោងក៏ត្រូវបានចំណាយឲ្យក្នុងអត្រា ១.៥ដង ទៅលើប្រាក់បៀវត្សន៍ធម្មតា។ ប៉ុន្តែទោះជាយ៉ាងនេះក្តីក្នុងការអនុវត្តជាក់ស្តែង គឺឆ្ងាយពីអ្វីដែលច្បាប់បានចែង។ នៅ Mae Sot នៅតាមព្រំដែនថៃ-ភូមា ស្ត្រីដែលត្រូវបានធ្វើការសម្ភាសន៍ បានធ្វើការ ១១ ម៉ោងក្នុង ១ថ្ងៃដោយមិនបានទទួលប្រាក់កម្រៃ ទាំងសម្រាប់អាហារថ្ងៃត្រង់ និងអាហារពេលល្ងាច។ រោងចក្រខ្លះមិនបានផ្តល់កម្រៃដល់កម្មករនៅថ្ងៃឈប់សម្រាកនៅរៀងរាល់ថ្ងៃអាទិត្យហើយខ្លះទៀតផ្តល់កម្រៃតែ ២ ដង ប៉ុណ្ណោះក្នុងមួយខែ។ ការផ្តល់កម្រៃដល់កម្មករសម្រាប់ការងារថែមម៉ោងត្រូវបានគិតអោយផងដែរ តែបន្ទាប់ពីកម្មករបំពេញការងារ ១១ម៉ោងក្នុង ១ ថ្ងៃនេះ ។ និង ការងារថែមម៉ោង ត្រូវបានគេមើលឃើញថា ជាការងារបង្ខិតបង្ខំ មិនមែនជាការងារតាមជម្រើសស្របតាមកម្មករចំណាកស្រុកខ្លួនឯង។

ស្ត្រីដែលធ្វើការនៅរោងចក្រកាត់ដេរនៅ Mae Sot បានទទួលប្រាក់ឈ្នួលតែ ៦៩ បាត្រក្នុង ១ ថ្ងៃ (€១.៤០)[vi] សម្រាប់ការងារ ១០ ទៅ ១១ ម៉ោងក្នុងថ្ងៃ ។ ប្រាក់ឈ្នួលអប្បរមានៅ Mae Sot ក្នុងកំឡុងពេល សម្ភាសន៍ គឺ ១៥៣ បាត្រ (៣.១០ដោន) ក្នុង ១ ថ្ងៃ។ នៅក្នុងរោងចក្រមួយ ដែលកម្មករត្រូវបានគេជួលដើម្បីបំពេញគិតជាភាគនៃការងារដែលទទួលបានប្រាក់ឈ្នួល ២០ បាត្រ (0.40ដោន) សម្រាប់ ១០០ ភាគ ។ ការងារបន្ថែមម៉ោងត្រូវបានទទួលប្រាក់ឈ្នួល ១៥បាត្រ (0.30 ដោន) សម្រាប់ការបំពេញការងារ ២ ម៉ោងសម្រាប់អ្នក ដែលមានបទពិសោធន៍ការងារល្អ ១១ បាត្រ (០.២២ដោន) ក្នុង ១ម៉ោង។ នៅក្នុងម៉ោងដ៏រវល់ជាមួយនឹងការងារបន្ថែមម៉ោង កម្មករនិយាយថា ពួកគេអាចទទួលប្រាក់

ឈ្នួល ១០០ បាត្រក្នុង ១ថ្ងៃ (ប្រហែល ២ដោន) ដែលនៅតែស្ថិតនៅក្រោម ប្រាក់ឈ្នួលអទៅប្បរមា។ បន្ថែមលើនេះទៀត យោងតាមកិច្ចសម្ភាសន៍ ប្រាក់ឈ្នួលមិនត្រូវបានគេបង់ឲ្យទាន់ពេលវេលាឡើយ។

ពេលកម្មករបង្កើតផលិតផលសម្រាប់ម៉ាកបរទេសល្បីៗ គឺមានការរិតត្បិតម៉ោងការងារ ដូចជា: ម៉ោងការងារធម្មតាគឺ ៨ ម៉ោងក្នុង ១ ថ្ងៃ មិនអនុញ្ញាតិម៉ោងធ្វើការបន្ថែម លើសពី ៤ ម៉ោងឡើយ។ ប៉ុន្តែជាលទ្ធផល កម្មករត្រូវបាននៅក្រោមសម្ពាធយ៉ាងធ្ងន់ធ្ងរ ក្នុងការផលិតសម្លៀកបំពាក់ឲ្យបានច្រើន។ កម្មករកាត់ដេរម្នាក់នៅបាងកកបានលើកឡើងថា៖

*ប្រសិនបើយើងធ្វើបាន ៨០ សម្លៀកបំពាក់សម្រាប់ រយៈពេល ១ម៉ោង ពួកគេនឹងត្រូវបានគេបង្ខំឲ្យធ្វើរហូតដល់ ១០០ ដែលមានន័យថា យើងត្រូវធ្វើការ ឲ្យបានខ្លាំងក្លា និងលឿន ប៉ុន្តែមិនទទួលបានប្រាក់ឈ្នួលសម្រាប់ម៉ោងបន្ថែមនោះទេ។*

សម្រាប់កម្មករនៅក្នុងរោងចក្រ ដែលផលិតសម្លៀកបំពាក់សម្រាប់ម៉ាកបរទេស ដែលល្បីៗ ទទួលបានប្រាក់ឈ្នួលអប្បបរមាស្របទៅតាមអ្វីដែលច្បាប់បានចែង។ ស្ត្រីម្នាក់បានប្រាប់យើងថា ប្រសិនបើពួកគេធ្វើបានចំនួនខ្ពស់ជាងនេះ ពួកគេអាចទទួលបានប្រាក់ឈ្នួល ២០៧ បាត្រក្នុង ១ថ្ងៃ (៥.១៩ដោន) និង ៣៨ បាត្រក្នុង ១ម៉ោង សម្រាប់ការងារថែមម៉ោង (០.៧៧ដោន)។ ដូច្នេះ ពួកគេទទួលបានប្រាក់បៀវត្សន៍ប្រហែល ១០០០០បាត្រ (២០២.៥៥ដោន) ក្នុង ១ខែ សម្រាប់ការងារ ១២ ម៉ោងក្នុង១ថ្ងៃ (រួមបញ្ចូលទាំងការងារថែមម៉ោងជារៀងរាល់ថ្ងៃ) ជាមួយនឹងថ្ងៃឈប់សម្រាក១ ថ្ងៃក្នុង ១ សប្តាហ៍។ ពេលដែលពួកគេសុំឈប់សម្រាកបន្ថែមទៀត ដែលមិនមាន ឬមានការអនុញ្ញាតិ ពួកគេមិនមានបញ្ហាឡើយ។ នៅពេលដែលយើងសួរថា ពួកគេត្រូវគេអនុញ្ញាតិឲ្យឈប់សម្រាកពេលមានជម្ងឺដែល ឬទេ? ពួកគេអាចសុំឈប់ ១ថ្ងៃ ដោយមិនចាំបាច់ទទួលបានប្រាក់ឈ្នួលនៅពេលដែលពួកគេឈឺ "ដោយគ្មានភាពសុខសប្បាយ"។

កិច្ចសន្យាការងារ ជាញឹកញាប់មិនមានសម្រាប់ស្ត្រីចំណាកស្រុកឡើយ នៅក្នុងរោងចក្រឧស្សាហកម្ម សម្លៀកបំពាក់នៅប្រទេសថៃ។ ស្ត្រីចំណាកស្រុកដែលផលិតម្ហូបអារហារសម្រាប់ម៉ាកបរទេសបានចុះហត្ថលេខាលើកិច្ចសន្យា ប៉ុន្តែពួកគេមិនបានផ្តល់ឲ្យសំណៅថតចម្លងនៃកិច្ចសន្យារបស់ពួកគេមួយច្បាប់ឡើយ ហើយពួកគេក៏មិនត្រូវបានគេផ្តល់ព័ត៌មានលេខកូដនៃក្រុមហ៊ុននោះដែរ។

ស្ត្រីដែលធ្វើការក្រុមហ៊ុន ដែលមិនមែនជាក្រុមហ៊ុនបរទេសដែលមានម៉ាកល្បី មិនមានកិច្ចសន្យាការងារ ឬបទបញ្ញត្តិសម្រាប់លក្ខខ័ណ្ឌការងារដែរ។

សម្រាប់កម្មករដែលមានឯកសារ ត្រូវបានតម្រូវឲ្យដាក់ឯកសារនៅតាមខ្លួនគ្រប់ពេលវេលាទាំងអស់ ដើម្បីបង្ហាញពីលក្ខខណ្ឌចំណាកស្រុករបស់ខ្លួន ។ សម្រាប់ស្ត្រីស្ទើរតែទាំងអស់ដែលត្រូវបានសម្ភាសន៍ បាននិយាយថា ថៅកែរបស់ខ្លួនជាអ្នករក្សាឯកសាររបស់ពួកគេ។ អ្នកដែលត្រូវបានគេសម្ភាសន៍បាននិយាយថា ប៉ូលីសមិនដែលយល់ព្រមលើឯកសាររបស់ពួកគេ ដើម្បីជាភស្តុតាងបញ្ជាក់អំពីស្ថានភាពចំណាកស្រុករបស់ពួកគេជានិច្ចជាកាលនោះទេ និងបានចាប់បង្ខំឲ្យពួកគេត្រូវបង់ថ្លៃ ១០០បាត្រ (២ ដោន ) ជាប្រាក់ពិន័យទៀតផងក្នុងករណីដូចនេះ។ ការដកហូតឯកសារផ្ទាល់ខ្លួន គឺជាធម្មតាដែលត្រូវបានធ្វើនៅកន្លែង៖ ដូចជានៅក្នុងរោងចក្រជាដើម ទោះបីជាខុសច្បាប់ក៏ដោយនៅប្រទេសថៃ។

កង្វះគោលនយោបាយកម្លាំងពលកម្ម និងការធ្វើចំណាកស្រុកឲ្យបានទូលំទូលាយផ្តល់នូវឱកាសដ៏ច្រើនដល់ "មេខ្យល់" ដើម្បីធ្វើអន្តរាគមន៍ និង មានក្នុងករណីខ្លះ ធ្វើការកេងប្រវ័ញ្ចកម្មករចំណាកស្រុកទៀតផង។ កម្មករចំណាកស្រុក ប្រើប្រាស់មេខ្យល់ក្នុងការធ្វើដំណើរស្វែងរកការងារធ្វើពីព្រោះរដ្ឋាភិបាលមិនបានផ្តល់សេវានៃកន្លែងសម្រាប់ស្វែងរកការងារដល់ពួកគេ និងមិនមានភ្នាក់ងារឯកជនដែលមានលក្ខណៈទៀងទាត់ណាមួយសម្រាប់ជនចំណាកស្រុកក្នុងការស្វែងរកការងារសម្រាប់ពួកគេឡើយ។ ជនចំណាស្រុកដែលត្រូវការប្តូរទីតាំងខេត្ត ក្នុងការស្វែងរកការងារ ត្រូវតែប្រើប្រាស់មេខ្យល់ដើម្បីឆ្លងកាត់កន្លែងប៉ូលីសឆែកឆេរនៅតាមផ្លូវទៅកាន់គោលដៅ។

មានឱកាសជាច្រើនសម្រាប់មេខ្យល់ និងនិយោជិកក្នុងការបោកប្រាស់ រំលោភបំពាន និងបង្ខិតបង្ខំកម្មករចំណាកស្រុក។ កម្មករចំណាកស្រុកទាំងឡាយណា ដែលដាក់ពាក្យបណ្តឹងនឹងនិយោជិកដែលរំលោភបំពាន នឹងត្រូវបានជាទូទៅគេបោះបង់ចោលភ្លាមៗ ពួកគេបន្ទាប់មកមានតែ ៧ ថ្ងៃប៉ុណ្ណោះក្នុងការស្វែងរកនិយោជិកថ្មី ដែលនេះជាការបង្ខំឲ្យពួកគេត្រូវទៅប្រើប្រាស់មេខ្យល់ដដែល។ ប្រសិនបើគេមិនស្វែងរកនិយោជិកថ្មីទេពួកគេនឹងបាត់បង់លក្ខខណ្ឌស្របច្បាប់ ដែលពួកគេអាចត្រូវបានគេចាប់បញ្ជូន មុននឹងពួកគេអាចបំពេញលក្ខខណ្ឌក្នុងករណីនេះ។

## ២.២ លក្ខខ័ណ្ឌនៃជីវភាពរស់នៅ

ចំនួនប្រហែលពាក់កណ្តាលនៃកម្មករដែលត្រូវបានសម្ភាសន៍ក្នុងរបាយការណ៍នេះ បានរស់នៅក្នុងកន្លែងសម្រាប់ស្នាក់នៅក្នុងរោងចក្រ។ នៅក្នុងរោងចក្រមួយ ស្ត្រីកម្មករបាននិយាយថា កម្មករទាំងអស់បានរស់នៅក្នុងបន្ទប់តែមួយរួមគ្នា ដែលនេះជាបទពិសោធន៍ជារួមរបស់កម្មករចំណាកស្រុក។ លក្ខខ័ណ្ឌរស់នៅទាំងឡាយនៅក្នុងកន្លែងរស់នៅ គឺមានសភាពអ៊ូអរ មិនមានអនាម័យ ជាមួយនឹងកង្វះកង្វះខាតនៃការគ្រប់គ្រងក្នុងការធ្វើឲ្យការងារទាំងឡាយមានភាពប្រសើរឡើង ។ ផ្ទុយទៅវិញទោះជាយ៉ាងណាក៏ដោយ កង្វះខាតលក្ខខណ្ឌនៃការរស់នៅក្នុងកន្លែងស្នាក់នៅ ដែលត្រូវចែកគ្នារស់នៅនេះ មិនបានផ្តល់នូវសុវត្ថិភាពសម្រាប់អ្នករស់នៅទីនោះពីការបៀតបៀនផ្សេងៗបានឡើយ។ ស្ត្រីម្នាក់ដែលកំពុងធ្វើការ និងកំពុងរស់នៅក្នុងរោងចក្រ ដែលផលិតខោខូវ ប៊ូយ បាននិយាយថា *"ខ្ញុំមានអារម្មណ៍ថាមិនមានសុវត្ថិភាពពីប៉ូលីស តាំងពីគ្មាននរណាម្នាក់មកជិតអគារ ដែលពួកយើងរស់នៅដោយសារតែមានក្លិនមិនល្អ និងត្រូវបានទទួលការបំផ្លាញ"* ។

កម្មករដែលរស់នៅក្នុងមណ្ឌល ក្នុងបរិវេណរោងចក្រ គឺជាក្រុមគោលដៅ ដែលត្រូវបានគេកាត់ប្រាក់ឈ្នួលដោយមិនបាច់គេពន្យល់ថាមកពីមូលហេតុអ្វីនោះទេ។ ពួកគេពេលខ្លះ ទទួលលិខិតកាត់ប្រាក់ដោយសរសេរដៃ ដែលបញ្ជាក់ពីវិកយ័ប័ត្រកាត់ប្រាក់សម្រាប់អគ្គីសនី ម្ហូបអារហារ និងថ្លៃជួល។ កម្មករដែលត្រូវបានគេសម្ភាសន៍ ពួកគេមិនបានយល់ឲ្យច្បាស់ពីមូលហេតុដែលប្រាក់ឈ្នួលរបស់ពួកគេត្រូវបានគេកាត់យ៉ាងដូច្នេះ ឡើយ។

សម្រាប់កម្មករដែលរស់នៅក្រៅរោងចក្រដែលមានលក្ខណៈស្មុគស្មាញ លក្ខខណ្ឌនៃការរស់នៅគឺមានភាពល្អប្រសើរ។ ស្ត្រីម្នាក់បាននិយាយថា កម្មករដែលរស់នៅក្នុងអាគារជិតរោងចក្រត្រូវបង់ប្រាក់ឈ្នួល ១៥០០បាត្រ (ប្រហែល៣០ដោន) ក្នុង ១ ខែ។ ពួកគេមានបន្ទប់ផ្ទាល់ខ្លួន ជាមួយនឹងបន្ទប់ទឹក និងសប្បាយចិត្តក្នុងការរស់នៅតែម្នាក់ឯង។ ប៉ុន្តែភាគច្រើនបំផុតនៃចំនួនកម្មករដែលរស់នៅខាងក្រៅ បានរស់នៅជាមួយនឹងមិត្តភក្តិ ដើម្បីសន្សំថវិកាទាក់ទងនឹងការចំណាយផ្សេងៗ ដែលពួកគេម្នាក់ចំណាយតែ ៣០០ បាត្រ (ប្រហែល៦ដោន) ក្នុង ១ ខែ។ ស្ត្រីម្នាក់បានរួមចំណែករស់នៅក្នុងបន្ទប់មួយជាមួយនឹងមនុស្ស ៨ នាក់ទៀត។ នាងបានលើកឡើងថា បន្ទប់ គឺមានទំហំធំគ្រប់គ្រាន់ក្នុងការដាក់អ្នក

រួមបន្ទប់បានចំនួន ៨ នាក់។ ពួកយើងបានប្រើប្រាស់វាំងននសម្រាប់ខណ្ឌចែកកន្លែងដែលពួកយើងរស់នៅ។

ជាទូទៅកម្មករចំណាកស្រុកជាស្ត្រី រស់នៅក្នុងសហគមន៍ចំណាកស្រុកដាច់ដោយឡែក។ មានស្ត្រីម្នាក់ក្នុងចំណោមស្ត្រីដែលត្រូវបានសម្ភាសន៍ បាននិយាយថា នាងមានមិត្តភក្តិជាជនជាតិថៃជាច្រើន និងសូម្បីតែនៅកន្លែងធ្វើការក៏ដោយ។ មានតែម្នាក់ ឬ ពីរនាក់ប៉ុណ្ណោះដែលអាចនិយាយភាសាថៃបានយ៉ាងល្អ។ ឱកាសរបស់គេក្នុងការជួប និងចូលរួមជាមួយសង្គមថៃ គឺមានកម្រិតយ៉ាងខ្លាំងដោយសារតែម៉ោងធ្វើការច្រើនហួសប្រមាណ និងដោយសារតែការរឹតត្បិតសិទ្ធិសេរីភាពរបស់ពួកគេ។

## ២.៣ ការទទួលបានសេវា

កម្មករចំណាកស្រុក ដែលបានចុះបញ្ជីសម្រាប់លក្ខខណ្ឌផ្ទៃច្បាប់ បានធ្វើការបញ្ជាក់ខាងលើបាននិយាយថា ពួកគេបានបង់ថ្លៃសេវាសុខភាពប្រចាំឆ្នាំ ១៣០០០បាត្រ (២៦ដោន) ដើម្បីទទួលបានសេវាសុខភាពជាតិនេះ ។ តាមការប៉ាន់ប្រមាណមានចំនួនជនចំណាកស្រុកពី ៦០០០០០ និង ១.២ លាននៃចំនួនកម្មករចំណាកស្រុកសរុបក្នុងប្រទេសថៃ ដែលទទួលបានសេវានេះ ។ ទោះបីជាយ៉ាងនេះក្តី ស្ត្រីដែលត្រូវបានគេសម្ភាសន៍សម្រាប់របាយការណ៍នេះ បានរៀបរាប់ពីព្រំដែននៃការទទួលបានសេវាផ្សេងៗ ដោយសារតែកត្តាមួយចំនួនដូចជាការបកប្រែភាសានៅមន្ទីរពេទ្យជាដើម ។ សម្រាប់ជនជាតិថៃភាគច្រើន អាចទទួលបាន សេវាថៃទាំសុខភាពដោយឥតគិតថ្លៃ តាមរយៈសេវាសុខភាពជាតិ ប៉ុន្តែសម្រាប់អ្នក ដែលធ្វើការនៅក្នុងវិស័យការងារជាផ្លូវការ ត្រូវបានកំពុងនឹងចូលរួមក្នុងប្រព័ន្ធសុវត្ថិភាពសង្គម ដែលផ្តល់ការការពារសុវត្ថិភាពសង្គមដ៏ទូលំទូលាយ រួមបញ្ចូលទាំងការសម្រាកមាតុភាព ប្រាក់ឧបត្ថម្ភពេលគ្មានការងារធ្វើ អត្ថប្រយោជន៍ពេលអសមត្ថភាព និងប្រាក់សោធននិវត្តន៍។ មានតែកម្មករចំនួន ៤០០០០០ នាក់ប៉ុណ្ណោះដែលទទួលការផ្ទៀងផ្ទាត់សញ្ជាតិ និងទទួលបានលិខិតឆ្លងដែនបណ្តោះអាសន្ន និងអាចចូលរួមក្នុងប្រព័ន្ធសុវត្ថិភាពសង្គម ដែលទាមទារឲ្យមាននិយោជិក និងរដ្ឋាភិបាល ដែលម្នាក់ៗបានចូលរួមចំនួន ៣% នៃប្រាក់ខែរបស់ពួកគេទៅក្នុងមូលនិធិសុវត្ថិភាពសង្គម។ ប៉ុន្តែបច្ចុប្បន្ននេះ វាមានលក្ខណៈមិនច្បាស់លាស់ ដែលនេះបានផ្តល់អត្ថប្រយោជន៍ដល់ជនចំណាកស្រុក ដែលនឹងត្រូវទទួលបានសិទ្ធិ។ មានតែស្ត្រីម្នាក់ក្នុងចំនោមស្ត្រីដែលត្រូវបានសំភាសន៍ ដែលបានលើកឡើងថា ខ្លួនបានស្គាល់អ្វីជាប្រព័ន្ធសុវត្ថិភាពសង្គម។

ជនចំណាកស្រុក ដែលគ្មានលិខិតឆ្លងដែនបណ្តោះអាសន្ន ត្រូវបានតម្រូវឲ្យបង់ថ្លៃសេវាថែទាំសុខភាពផ្ទាល់ខ្លួនរបស់គេ។ នៅមន្ទីរពេទ្យរបស់រដ្ឋ តម្លៃសម្រាប់សេវាសុខភាព គឺមានតម្លៃថោក ប៉ុន្តែតម្លៃសេវាសម្រាប់ការព្យាបាលបន្ត ឬការវះកាត់ គឺនៅឆ្ងាយពីលទ្ធភាពក្នុងការបង់ថ្លៃសេវារបស់កម្មករចំណាកស្រុក។ បន្ថែមលើនេះទៀត ក្នុងតំបន់ខ្លះនៅប្រទេសថៃ ជាពិសេសនៅបាងកក ជនចំណាកស្រុកដែលគ្មានឯកសារមានភាពរារែក ក្នុងការទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យរដ្ឋ ដោយសារតែភាពភ័យខ្លាចពួកគេអាចត្រូវបានគេឃាត់ខ្លួន[viii]។

លើកលែងតែពួកគេមានឯកសារ ដែលបញ្ជាក់អំពីស្ថានភាពនៃការធ្វើចំណាកស្រុកស្របច្បាប់របស់ខ្លួន ស្របតាមរដ្ឋធម្មនុញ្ញថៃ ឆ្នាំ២០០៧ ជនចំណាកស្រុក ត្រូវបានទទួលនូវសិទ្ធិ ដោយស្មើភាពក្នុងការទទួលបានយុត្តិធម៌ និងការការពារដោយស្មើភាពស្របតាមច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៨។ ប៉ុន្តែជនចំណាកស្រុកបានជួបប្រទះនឹងការលំបាកជាច្រើនក្នុងការទទួលបានយុត្តិធម៌ ។ បទបញ្ញត្តិស្តីពីការងារបានផាត់ចោលនូវចំនួនកម្មករដែលធ្វើការតាមផ្ទះ និងកម្មករដែលធ្វើការងារក្នុងវិស័យកសិកម្មតាមរយៈបទបញ្ញត្តិក្រសួងពិសេស និង ផាត់ចោលនូវចំនួនជនចំណាកស្រុកដ៏ច្រើន ។ កម្មករចំណាកស្រុក ក៏ត្រូវបានតម្រូវឲ្យបង្ហាញភស្តុតាងដើម្បីបង្ហាញថា ពួកគេមានទំនាក់ទំនងជាផ្លូវការជាមួយនឹងនិយោជិករបស់ពួកគេ ដើម្បីមានលទ្ធភាពក្នុងការប្រើប្រាស់ការការពារដែលមានចែងក្នុងបទបញ្ញត្តិការងារ។ នេះអាចជាបញ្ហាប្រឈមសម្រាប់កម្មករ ដែលធ្វើការគិតចំនួននៃលទ្ធផល ដែលខ្លួនធ្វើបាន ដោយពួកគេអាចត្រូវប្រឈមនឹងការបដិសេធពីនិយោជកថា ពួកគេមិនត្រូវបានគេជួលឲ្យធ្វើការ សម្រាប់ទទួលបានប្រាក់បៀវត្សន៍ ឬ សម្រាប់កម្មករកាត់ដេរ ដែលធ្វើការក្នុងរោងចក្រដែលប្រើប្រាស់បទបញ្ជានៅក្នុងកិច្ចសន្យាបណ្តោះអាសន្ន។

ជនចំណាកស្រុក ដែលបានដាក់ពាក្យបណ្តឹង ទៅកាន់ការិយាល័យការពារកម្មករ និងការិយាល័យសុខមាល ជាធម្មតា គឺជាក្រុមគោលដៅ ដែលត្រូវទទួលការបៀតបៀនពីនិយោជិករួមដែលរួមទាំងការបណ្តេញចេញផងដែ។ ជនចំណាកស្រុក ដែលបានដាក់ពាក្យបណ្តឹងចំពោះនិយោជកទៅកាន់ការិយាល័យទាំងនោះបានផ្តល់របាយការណ៍ថា ពួកគេត្រូវបានជាប់ឈ្មោះក្នុងបញ្ជីខ្មៅរបស់រោងចក្រដោយពួកគេពាក់ពន្ធ័និងសកម្មភាពសហជីព ។ ដោយសារតែការដំណើរការរឿងក្តីតាមច្បាប់

នៅគុលាការ ត្រូវចំណាយពេលយូរអស់រយៈពេលជាច្រើនឆ្នាំជនចំណាកស្រុកមិនអាចនៅបន្តរឿងក្តី លើកលែងតែគេស្វែងរកបានការងារថ្មីជំនួស។

ជនចំណាកស្រុកដែលមិនមានឯកសារគ្រប់គ្រាន់ត្រូវបាន ប៉ូលីសអន្តោប្រវេសន៍ធ្វើការត្រួតពិនិត្យជា ញឹកញាប់ បន្ទាប់ពីពួកគេបានដាក់ពាក្យបណ្តឹង និងត្រូវបានគេបញ្ជូនមកប្រទេសកំណើត ដែលធ្វើអោយពួកគេបាត់បង់ឱកាសក្នុងការទទួលបានយុត្តិធម៌។ ពេលដែលជនចំណាកស្រុករៀបចំខ្លួនក្នុងការជម្នះឧបសគ្គទាំងឡាយនោះ និងបន្តករណីទៅមុខពួកគេត្រូវជួប នឹងបញ្ហា និងប្រព័ន្ធការិយាល័យធិបតេយ្យដែលស្ថិតនៅលើនិយោជកជាអ្នកបង្កើត ។

បន្ថែមលើនេះទៀត មិនមានរោងចក្រណាមួយ ក្នុងចំណោមរោងចក្រជាច្រើន ដែលស្ត្រីបានចូលរួមក្នុងកិច្ចសំភាសន៍ក្នុងរបាយការណ៍នេះ បានបង្កើតឲ្យមានសហជីពឡើយ។ ច្បាប់នៃទំនាក់ទំនងការងារឆ្នាំ១៩៧៥បានតម្រូវឲ្យសមាជិកនៃគណៈកម្មការជាន់ខ្ពស់នៃសហជីពជាជនជាតិថៃ ដែលនេះបានផាត់ចោលជនចំណាកស្រុកដែលចង់បង្កើតសហជីពផ្ទាល់ខ្លួនរបស់គេ ។ ទោះបីជាមានសហជីពថៃមួយបានផ្តល់ឱកាសឲ្យមានសមាជិកជាកម្មករចំណាកស្រុកក៏ដោយ ក៏នៅតែមានការលំបាកសម្រាប់ជនចំណាកស្រុកក្នុងការក្លាយខ្លួនជាសមាជិកសកម្ម ដោយសារតែបញ្ហាភាសា ការរិតត្បិតសេរីភាពក្នុងការដើរហើរ និងទំនាក់ទំនងជាមួយនឹង សហជីព។

សហជីពថៃ គឺមានទីតាំងនៅទីក្រុងបាងកក និងមិនមានសាខានៅក្នុងតំបន់ដែលកម្មករចំណាកស្រុកធ្វើការឡើយ (ដូចជា Mae Sot ដែលជាញឹកញាប់ការធ្វើប្រតិបត្តិការដោយកម្មករចំណាកស្រុក)។ មានតែរោងចក្រសម្រាបម៉ាកល្បីៗរបស់បរទេសប៉ុណ្ណោះ ដែលមានតំណាងជាកម្មករដែលបានផ្តល់លទ្ធភាពដែលមានដែនកំណត់ ក្នុងការងារចរចារជាមួយនឹងនិយោជក។

## ២.៤ ការឆ្លើយតបនៅក្នុងមូលដ្ឋាន

មានអង្គការ ដែលធ្វើការនៅមូលដ្ឋានត្រូវបានសំភាសន៍សម្រាប់របាយការណ៍នេះ៖ ស្ត្រីដែលធ្វើការសម្រាប់សកម្មភាពសង្គម (SAW) សហជីពស្ត្រីមីយ៉ាន់ម៉ា(BWC) ក្រុមប្រឹក្សាមេធាវីមីយ៉ាន់ម៉ា (BLC) មូលនិធិ MAP និងសមាគមកម្មករ Yang Chi Oo ប្រធាននៃគណៈកម្មការសាមគ្គីការងារថៃ

(TLSC) គណៈកម្មការសហភាពសហជីព សហពន្ធ័នៃអង្គការមិនមែនរដ្ឋាភិបាល និងសហជីពក៏ត្រូវបានសំភាសន៍ផងដែរ។

អង្គការនៅមូលដ្ឋានទាំង ៥ ដែលត្រូវបានសម្ភាសន៍នេះពួកគេបានព្យាយាមសម្របសម្រួលជួយជនចំណាកស្រុកឲ្យទទួលបានយុត្តិធម៌ ។ ពួកគេបានរៀបចំវគ្គបណ្តុះបណ្តាលអំពីសិទ្ធិ ច្បាប់ គោលនយោបាយ ជាពិសេសអំពីសិទ្ធិស្ត្រី និងជួយឲ្យជនរងគ្រោះខិតខំប្រឹងប្រែង និងមានជំនឿលើខ្លួនឯង និងត្រូវបានពង្រឹងអំណាចក្នុងការប្រយុទ្ធប្រឆាំងទាមទារសិទ្ធិរបស់ខ្លួន។ ពួកគេបានផ្តល់បណ្តាញទំនាក់ទំនងដល់ជនចំណាកស្រុក ដើម្បីធ្វើការទាក់ទងជាមួយនឹងដៃគូ ដែលមានសក្តានុពលក្នុងការធ្វើសកម្មភាពរបស់ពួកគេដូចជា សហជីពក្នុងស្រុក ជំនួយក្នុងការទៅរកជំនួយពីរដ្ឋាភិបាលថៃដោយផ្ទាល់ និងយុទ្ធសាស្ត្រជាមួយនឹងកម្មករដែលមានបំណងក្នុងការប្តឹងប្រឆាំងនិយោជកនៅតុលាការ។ ដោយសារតែដំណើរការរឿងក្តីនៅតុលាការត្រូវដំណើរការអស់រយៈពេលយូរ មានអង្គការមួយចំនួនបានជួយជនរងគ្រោះក្នុងរយៈពេលនៃដំណើរការរឿងក្តីនៅតុលាការ ដូចជាអង្គការ MAP និងសហាគមន៍របស់កម្មករ Yaung Chi Oo ជាដើម។

ប្រភេទនៃសេវាផ្សេងទៀត ដែលត្រូវបានផ្តល់ដោយអង្គការទាំងនេះមានដូចជា៖ ការប្រជុំប្រចាំខែរវាងកម្មករទាំងនោះដើម្បីធ្វើការចែកចាយ បទពិសោធ និងយុទ្ធសាស្ត្រ ការផ្លាស់ប្តូរកម្មករ ការបណ្តុះបណ្តាលអំពីសិទ្ធ និងច្បាប់ កិច្ចសហការរវាងកម្មករចំណាកស្រុក និងសហជីពរបស់ប្រទេសថៃ ការពិគ្រោះយោបល់រវាង កម្មករចំណាកស្រុកភូមា នៅក្នុងប្រទេសថៃ និងម៉ាឡេស៊ី រួមទាំងមកពីប្រទេសកម្ពុជា។ អង្គការក៏បានផ្តល់ជំនួយមេធាវី និងជំនួយផ្នែកច្បាប់ផងដែរ ក្នុងការដាក់ពាក្យបណ្តឹងនៃការកេងប្រវ័ញ្ចទៅតុលាការតបតនឹងនិយោជក ក៏ដូចជាធនធាននៃមណ្ឌលការស្នាក់នៅ ក្នុងមណ្ឌលសកម្មភាពក្នុងការរកប្រាក់ចំណោញ និងមណ្ឌលស្នាក់នៅក្នុងករណីបន្ទាន់។

មានអង្គមួយចំនួនបានផ្តល់សកម្មភាពក្នុងការជួយពង្រឹងអំណាច និង សកម្មភាពក្នុងការជួយតស៊ូមតិ ដោយផ្តោតជាសំខាន់ទៅលើ ការបង្កើតបណ្តាញសម្រាប់ក្រុមជួយខ្លួនឯង ។ អង្គកា MAP ឧទាហរណ៍ បានផ្តល់ជំនួយក្នុងការអភិវឌ្ឍន៍ទៅដល់សមាគមន៍កម្មករជនចំណាកស្រុកនៅឈៀងម៉ៃ (សមាគមន៍សាមគ្គីកម្មករ (WSA) ។ ក្នុងនោះដែរក៏មានការតាំងចិត្តក្នុងការបង្កើតឲ្យមានសមាគមជាច្រើនទៀតក្នុងតំបន់ខុសៗគ្នា និងការរុករកជំនួយផ្សេងៗដែលអាចមានលទ្ធភាពអាចរកបាន ក្នុង

ការពង្រីកសេវារបស់ WSA ។ TLSC មានអនុគណៈកម្មការស្តីពីកម្មករចំណាកស្រុក និងបង្កើតបណ្តាញសម្រាប់ជនចំណាកស្រុកក្នុងការភ្ជាប់ទំនាក់ទំនងជាមួយនឹងសហជីពរបស់ប្រទេសថៃ និងបានរៀបចំជាការងារតស៊ូមតិដោយផ្ទាល់ជាមួយនឹងរដ្ឋាភិបាលថៃ

អង្គការនៅមូលដ្ឋានបានអំពាវនាវឲ្យអ្នកប្រើប្រាស់សម្លៀកបំពាក់ ដែលធ្វើដោយកម្មករចំណាកស្រុកជាស្ត្រី នៅក្នុងរោងចក្រកាត់ដេរនៅប្រទេសថៃ ឲ្យព្រមទទួលស្គាល់ពីលក្ខខណ្ឌការងារដែលមិនល្អក្នុងរោងចក្រទាំងឡាយនោះ និងធ្វើការស្នើសុំ ឲ្យអ្នកផលិតទាំងអស់ឲ្យធ្វើការកែលំអរស្ថានភាពកម្មករ ។ ពួកគេបានលើកឡើងពីតម្រូវការការនៃសម្លេងគាំទ្រតែមួយ ក្នុងការអំពាវនាវឲ្យមានការបញ្ចប់ការកេងប្រវ័ញ្ចទៅលើកម្មករចំណាកស្រុក និងការកែលម្អរស្ថានភាពលក្ខខណ្ឌការងារ សម្រាប់កម្មករទាំងនោះផងដែរ ដើម្បីលើកឡើងពីការទទួលស្គាល់លក្ខខណ្ឌការងារដែលមានបទដ្ឋានជាអន្តរជាតិមានសុវត្ថិភាព ផាសុខភាព និងប្រាក់បៀវត្សន៍សម្រាប់ការរស់នៅសមរម្យ ។

## ការធ្វើចំណាកស្រុកក្នុងស្រុកនៅប្រទេសកម្ពុជា

*កម្លាំងពលកម្ម ដែលជាកម្មករចំណាកស្រុកនៅប្រទេសកម្ពុជា គឺមានចំនួនច្រើនលើសលុប ដោយសារ ជនចំណាកស្រុកមកពីជនបទ មកទីកាន់ក្រុងដើម្បីស្វែងរកការងារ ។ នៅ ឆ្នាំ២០០៩ មាន ចំនួន ២.៥ លាននាក់ នៃជនចំណាកស្រុកក្នុងស្រុក នៅក្នុងប្រទេសកម្ពុជា ហើយភាគច្រើនពួកគេជា ស្ត្រីវ័យក្មេង[viii] ។*

កម្មករចំណាកស្រុកធ្វើការដោយប្រើកម្លាំង ប៉ុន្តែបានទទួលប្រាក់ឈ្នួលទាប នៅក្នុងការធ្វើ ការងារក្នុងរោងចក្រកាត់ដេរ ឬ ក្នុងវិស័យមិនផ្លូវការដូចជា ការងារធ្វើការតាមផ្ទះ និងការងារផ្តល់សេវា កំសាន្ត។ ការងារកាត់ដេរ និង វាយនភ័ណ្ឌបាននិងកំពុងដើតួនាទីយ៉ាងសកម្ម ក្នុងឋានះ ជានិយោជិក ផ្លូវការសម្រាប់ស្ត្រីវ័យក្មេងមិនទាន់រៀបការដែលមកពីជនបទ ដែលមិនមានការងារដើម្បីទទួលបាន ប្រាក់កម្រៃខ្ពស់ និងជាមួយភាពក្រីក្រមានស្ទើរគ្រប់ទីកន្លែង។ ប្រហែលជា ៩០% នៃកម្មករនៅរោង ចក្រកាត់ដេរ ក្នុងប្រទេសម្ពុជា គឺជាស្ត្រីចំណាកស្រុកវ័យក្មេងដែលមកពីតំបន់ដាច់ស្រយាល[ix] ។

ភាពចលចល និងការសង្កត់សង្កិននៅក្រោមសម័យខ្មែរក្រហម នៅឆ្នាំ ១៩៧៥ និងសង្គ្រាម ស៊ីវិល ដែលបានបញ្ចប់រហូតដល់ដើមឆ្នាំ ១៩៩០ ដែលបានបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ពន្ធ័របស់ ប្រទេសជាតិ ។ ប៉ុន្តែតាំងពីការបោះឆ្នោតដែលផ្តល់ជំនួយដោយអង្គការសហប្រជាជាតិ ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាជាប្រទេស ដែលនៅក្នុង វិថីឆ្ពោះទៅកាន់ការស្តាបនាឡើងវិញ ផ្នែកសេដ្ឋកិច្ច។ រដ្ឋាភិបាលបានធ្វើឲ្យទំនាក់ទំនងពាណិជ្ជកម្មរបស់ខ្លួនមានលក្ខណ:សាមញ្ញ ជាមួយនឹងប្រទេសមហា អំណាចលោកខាងលិច ក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចទាំងនៅថ្នាក់តំបន់ និងនៅក្នុងពិភពលោក បន្ទាប់ពី ១០ឆ្នាំ ដែលប្រទេសមួយនេះស្ថិតនៅដាច់តែឯង។ ប្រទេសកម្ពុជា បានចូលរួមក្នុងកម្មវិធីកិច្ច សហការសេដ្ឋកិច្ច ក្នុងប្រទេសអភិវឌ្ឍន៍អនុតំបន់ទន្លេមេគង្គតាំងពីឆ្នាំ ១៩៩២ ដែល ផ្តើមគំនិតដោយ ធនាគារអភិវឌ្ឍន៍អាស៊ី ប្រទេសកម្ពុជាចូលជាសមាជិករបស់អាស៊ាននៅឆ្នាំ ១៩៩៩ និងក្លាយជា សមាជិកពេញសិទ្ធិនៃអង្គការពាណិជ្ជកម្មពិភពលោកនៅឆ្នាំ ២០០៤ ។

រយៈពេលមួយទស្សវត្សន៍រវាងឆ្នាំ ១៩៩៦ និង២០០៧ GDP ប្រទេសកម្ពុជាបានរីកលូតលាស់ ប្រហែល ២.៥ដង ដែលការលូតលាស់នៃ GDP របស់ប្រទេសកម្ពុជានៅឆ្នាំ ២០០៥ មានតែ ១៣% ។

គោលនយោបាយ មីក្រូសេដ្ឋកិច្ចរបស់រដ្ឋាភិបាលកម្ពុជា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩០ ដើម្បីធ្វើការទាក់ទាញការធ្វើវិនិយោគដោយផ្ទាល់ពីបរទេស (FDI) ដើម្បីធ្វើឲ្យវិស័យនាំចេញរបស់ប្រទេសកម្ពុជាមានការប្រកួតប្រជែងកាន់តែខ្លាំងតទល់ជាមួយនឹងប្រទេសជិតខាង ដើម្បីដោះស្រាយអត្រាមិនមានការងារធ្វើ ១០% ។ FDI ក្នុងប្រទេសកម្ពុជាបានរីកចម្រើនម្តងទៀតដល់ ៨៦៧លានដុល្លារ នៅឆ្នាំ ២០០៧ បន្ទាប់មកបានធ្លាក់ចុះដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោក FDI បានដល់ ៨០០លានដុល្លារម្តងទៀត នៅឆ្នាំ២០១១ ។ ទោះបី ជាមានការរីកចម្រើនក្នុងរវាងឆ្នាំ ១៩៩០ និង ឆ្នាំ២០០០ ដើមទុន FDI គឺត្រូវបានចាត់ទុកថា មានកម្រិតទាបជាងគេក្នុងតំបន់[x]។

ឧស្សាហកម្មកាត់ដេរ និងវាយនភ័ណ្ឌ គឺជាវិស័យមួយដែលត្រូវបានទទួលអត្ថប្រយោជន៍ច្រើនជាងគេពីការរីកចម្រើននៃ FDI និងការនាំចេញ។ ការកាត់ដេរត្រូវបានអភិវឌ្ឍន៍ស្ទើរតែទាំងស្រុង ដោយការធ្វើវិនិយោគថ្នាក់តំបន់[xi]។ ការរីកចម្រើននេះនៅក្នុង FDI បានត្រលប់មកវិញជាការឧបត្ថម្ភ លើកទឹកចិត្តដូចជាការអនុគ្រោះពន្ធ ដែលផ្តល់ដោយរដ្ឋាភិបាល និងការបង្កើតឲ្យមានមណ្ឌលនៃដំណើរការនាំចេញដូចជា កម្លាំងពលកម្ម ដែលមានវ័យក្មេង និងតំលៃថោក។ មានរោងចក្រជាច្រើនដែលប្រតិបត្តិការនៅភ្នំពេញតែមួយ នៅឆ្នាំ ១៩៩៨ មានចំនួន ១២៩ និងបានឡើងដល់ ៣៥១ នៅឆ្នាំ ២០០៨ ។ ផលិតផលរោងចក្រកាត់ដេរ និងវាយនភណ្ឌមានតម្លៃប្រហែល ២ កោដិដុល្លារ ដល់សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០០៩ ត្រូវជា ១៦% សម្រាប់ GDP[xii] ។

ឧស្សាហកម្មបច្ចុប្បន្ន គឺមានចំនួនច្រើនលើសលុបនៃអ្នកនាំចេញនៅក្នុងប្រទេសកម្ពុជា ជាមួយនឹងផលិតផលកាត់ដេរ ដែលត្រូវជា ៩០% នៃការនាំចេញរបស់សរុបរបស់ប្រទេសកម្ពុជា។ ក្នុងឆ្នាំថ្មីៗកន្លងទៅនេះ រោងចក្រកាត់ដេរ និងវាយនភណ្ឌនៅក្នុងប្រទេសកម្ពុជាបាននាំចេញទៅកាន់សហរដ្ឋអាមេរិកមានចំនួនប្រហែល ៦៧% សហគមន៍អ៊ឺរ៉ុបមានចំនួន ២២% និងកាណាដាមានចំនួន ៦% ។

មានម៉ាកសម្លៀកបំពាក់សំខាន់ៗរបស់ប្រទេសលោកខាងលិច មានប្រភពដើមមកពីប្រទេសកម្ពុជា (ស្របតាមរបាយការណ៍ជាផ្លូវការមួយរបស់ USAID ដែលមានចំនួន ១ ភាគ ៣ នៃការនាំចេញសម្លៀកបំពាក់ទាំងអស់របស់ប្រទេសកម្ពុជានៅឆ្នាំ ២០០៥ គឺជាផលិតកម្មរបស់ Gap[xiii] )។ ម៉ាកល្បីៗផ្សេងៗទៀតដែលមានប្រភពពីប្រទេសកម្ពុជា មានដូចជា Adidas Puma Reebok Nike Marks & Spencer Levi Strauss Timberland Benetton Zara & H&M[xiv] .

## រោងចក្រកាត់ដេរនៅកម្ពុជា

### ៣.១ បទពិសោធន៍របស់ស្ត្រីចំណាកស្រុក

ការសម្ភាសន៍មួយត្រូវបានធ្វើជាមួយនឹងស្ត្រីកម្មករចំណាកស្រុកចំនួន ៣០នាក់ ដែលធ្វើការក្នុងរោងចក្រកាត់ដេរ។ ស្ត្រីកម្មករដែលត្រូវបានសំភាសន៍ មានអាយុចាប់ពី ១៩ឆ្នាំ ដល់ ៤០ឆ្នាំ ដែលភាគច្រើន (១៨នាក់ក្នុងចំណោម ៣០នាក់) មានអាយុចាប់ពី ១៩-២៥ ឆ្នាំ។

លើសពី ៩០% នៃស្ត្រីដែលត្រូវបានសំភាសន៍បានលើកឡើងថា ពួកគេបានធ្វើចំណាកស្រុកដោយសារតែបញ្ហាសេដ្ឋកិច្ច ហើយពួកគេបានរៀបរាប់ពីហេតុផលផ្សេងៗ ទៀតដែលពាក់ព័ន្ធ ដូចជាកង្វះប្រាក់ចំណូល បំណុល និងបាត់បង់ដីធ្លី ដោយសារតែការរឹបអូសយកដីពីសំណាក់អ្នកមាន និងដោយសារបំណុល ដែលបង្ខំឲ្យពួកគេលក់ដីរបស់ខ្លួន ។ មានអ្នកដែលត្រូវបានគេសម្ភាសន៍ជាច្រើនបានបន្ថែមថាដោយសារខ្លួនជាកូនស្រី ពួកគេមានកាតព្វកិច្ចក្នុងការសងគុណឪពុកម្តាយរបស់ពួកគេតាមរយៈការជួយរកចំណូលដើម្បីជួយទ្រទ្រង់គ្រួសារ។ នេះជាការលើកឡើងរបស់ស្ត្រីវ័យក្មេងម្នាក់មកពីខេត្តព្រៃវែង។

*ជាដំបូងខ្ញុំបានធ្វើចំណាកស្រុកមកភ្នំពេញ នៅពេលដែលខ្ញុំមានអាយុ ១៥ឆ្នាំ ដើម្បីធ្វើការជាអ្នកបម្រើតាមផ្ទះ សម្រាប់រយៈពេល ២ឆ្នាំ ប៉ុន្តែដោយសារលក្ខខ័ណ្ឌការងារមានការលំបាកខ្លាំង និងទទួលបានប្រាក់ឈ្នួលទាប ខ្ញុំក៏សម្រេចចិត្តចាកចេញ និងត្រលប់មកផ្ទះវិញ។ បន្ទាប់ពីស្នាក់នៅផ្ទះបានរយៈពេល ២-៣ខែ ម្តាយរបស់ខ្ញុំមានបំណងឲ្យខ្ញុំទៅភ្នំពេញវិញដើម្បីស្វែងរកការងារ ជាកម្មកររោងចក្រកាត់ដេរដូចក្មេងស្រីផ្សេងទៀតនៅក្នុងភូមិដែរដើម្បីជួយរកប្រាក់ចំណូលទ្រទ្រង់ជីវភាពគ្រួសារ និង ជួយសងបំណុល។*

ស្ត្រីដែលត្រូវបានសំភាសន៍ មួយចំនួនបាននិយាយថា គ្រួសាររបស់ពួកគេ បានសុំឲ្យពួកគេឈប់រៀន និងធ្វើចំណាកស្រុកមកភ្នំពេញដើម្បីស្វែងរកការងារ ដើម្បីជួយទ្រទ្រង់ជីវភាពគ្រួសារ និងជួយប្អូនៗរបស់ពួកគេដើម្បីបន្តការសិក្សា ។ ជាទម្លាប់គ្រួសារកម្ពុជា បានផ្តល់អាទិភាពការសិក្សាសម្រាប់កូនប្រុសជាជាងកូនស្រី ព្រោះពួកគេមានជំនឿថា បុរសដែលជាក្មេងជំទង់អាចស្វែងរកការងារ

ដែលមានប្រាក់ចំណូលប្រសើរជាងស្ត្រី។ ពេលដែលពួកគេធ្វើចំណាកស្រុកមកទីក្រុង កម្មករភាគច្រើនស្វែងរកការងារតាមរយៈមិត្តភក្តិ គ្រួសារ និងភ្នាក់ងារជ្រើសរើសពលករ។

ជាង ៨០% នៃស្ត្រីដែលត្រូវបានសំភាសន៍ បានលើកឡើងថា ពួកគេមានកិច្ចសន្យាការងារ។ មានតែស្ត្រីចំណាកស្រុកម្នាក់ប៉ុណ្ណោះ ដែលធ្វើការនៅក្នុងរោចក្រទទួលម៉ៅការបន្តគាត់បាននិយាយថា គាត់មិនបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរនោះទេ ។ កម្មករភាគច្រើនបានចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ប៉ុន្តែពួកគេមានការយល់ដឹងតិចតួចពីកិច្ចសន្យានោះ រួមទាំងប្រាក់ឈ្នួលរបស់ពួកគេ ហើយមិនតែប៉ុណ្ណោះ ជារឿយៗពួកគេមិនយល់ដឹងពីសិទ្ធិ និងអត្ថប្រយោជន៍ផ្សេងទៀតដែលពួកគេត្រូវទទួលបាននោះទេ។ស្ត្រីទាំងអស់ដែលត្រូវបានសំភាសន៍ បានលើកឡើងថា ពួកគេមានតែកិច្ចសន្យាដែលមានរយៈពេលខ្លី ក្នុងរយៈពេល ៣ខែ ទៅ ៦ខែ ហើយដែលបច្ចុប្បន្ន ការអនុវត្តន៍នេះបានក្លាយជាការអនុវត្តន៍ទូទៅ និងសាមញ្ញទៅហើយ។ យោងតាមប្រសាសន៍របស់លោក **អាត ធន** ប្រធានសម្ព័ន្ធសហជីពប្រជាធិតេយ្យកម្មករកាត់ដេរកម្ពុជាបានមានប្រសាសន៍ថា ៦០% នៃកម្មកររោងចក្រកាត់ដេរ ៩០០ បានប្រើប្រាស់កិច្ចសន្យារយៈពេលខ្លី[xv]។ ដោយសារតែភាពសម្បូរបែបផ្នែកពលកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ បានជម្រុញឲ្យនិយោជកមានភាពងាយស្រួលក្នុងការជួល ឬ ក៏បណ្តេញកម្មករចេញពីកន្លែងការងារ និងផ្តល់អត្ថប្រយោជន៍ដល់កម្មករតិចតួចបំផុត។ ឧទាហរណ៍ កម្មករដែលធ្វើការតិចជាង ១ ឆ្នាំ មិនត្រូវបានទទួលអត្ថប្រយោជន៍សម្រាប់ការសម្រាកមាតុភាពឡើយ។

ស្ត្រីទាំងអស់ដែលត្រូវបានសំភាសន៍ សម្រាប់របាយការណ៍នេះ បានលើកឡើងថាម៉ោងការងារធម្មតា គឺ ៨ម៉ោងក្នុង ១ថ្ងៃ និង ៦ថ្ងៃក្នុង ១សប្តាហ៍ ជាមួយនិងម៉ោងបន្ថែម ដែលត្រូវបានចាត់ទុកថាជាម៉ោងសម្រាប់ការងារថែមម៉ោង។ មានស្ត្រីជាច្រើនបានរាយការណ៍ថា រោងចក្ររបស់ពួកគេមានរដូវកាលដែលមានតម្រូវការខ្លាំង ហើយដែលត្រូវធ្វើការបន្ថែមម៉ោង ដែលជាតម្រូវការមិនអាចខកខានបាន ហើយពួកគេត្រូវឲ្យធ្វើការថែមម៉ោងពី ២ម៉ោង ទៅ ៤ម៉ោង ក្នុង ១ថ្ងៃ។ ជាងពាក់កណ្តាលនៃអ្នកដែលត្រូវបានសម្ភាសន៍ បានលើកឡើងថា ជាលក្ខណៈបច្ចេកទេស ពួកគេមានសិទ្ធិក្នុងការបដិសេធ ការងារថែមម៉ោងបាន ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង ពួកគេមិនអាចបដិសេធបានទេ ពីព្រោះពួកគេមានភាពភ័យខ្លាចពីការបណ្តេញចេញពីការងារ។ ស្ត្រីផ្សេងទៀតបានរាយការណ៍ថា ពួកគេធ្លាប់

ទទួលបទពិសោធន៍ក្នុងការបណ្តេញចេញពីការងារ និងទទួលការគំរាមគំហែងពីនិយោជករបស់ពួកគេ ក្នុងការដែលមិនព្រមធ្វើការថែមម៉ោង។

ស្ត្រីទាំងអស់ដែលត្រូវសំភាសន៍បាននិយាយថា ពួកគេអាចសន្សំបានចំណូលបន្ថែមពីការងារថែមម៉ោង ក្នុងរដូវកាលដែលរវល់ជាងរដូវកាលដែលធ្លាក់ចុះ។ ក្នុងអំឡុងពេលដែលប្រាក់ឈ្នួលប្រចាំខែអប្បរមាសម្រាប់កម្មកររោងចក្រផលិតស្បែកជើង ៦១ដុល្លា ក្នុងឆ្នាំ ២០១០ តាមរយៈការសិក្សាស្រាវជ្រាវរបស់ក្រុមប្រឹក្សាការងា ដែលពេលនោះកម្មករអាចរកចំណូលបានក្នុងរង្វង់ពី ៨០ ដុល្លា ទៅ ៩០ ដុល្លាក្នុងរដូវកាលរវល់ខ្លាំង ជាមួយនឹងរយៈពេល ២ម៉ោងបន្ថែមសម្រាប់ការងារបន្ថែមម៉ោងរៀងរាល់ថ្ងៃ។ ប៉ុន្តែពួកគេត្រូវធ្វើការក្នុងរយៈពេលយូរ បរិភោគតិច ជាមួយនឹងម៉ោងពេលសម្រាកតិចតួច។ ជាង ៩០% នៃស្ត្រីដែលត្រូវបានសំភាសន៍ បាននិយាយថា រោងចក្ររបស់ពួកគេ ផ្តល់ប្រាក់បៀវត្សន៍ប្រចាំខែជាមូលដ្ឋានដល់កម្មករ ប៉ុន្តែមានស្ត្រីម្នាក់ជាអ្នករៀបចំការងារដែលគិតជាភាគ។ ស្ត្រីទាំងអស់បានលើកឡើងថា ពួកគេមិនបានដឹងអ្វី ដែលពីរបៀបគណនាប្រាក់បៀវត្សន៍របស់ពួកគេជារៀងរាល់ខែឡើយ ដែលកិច្ចការទាំងអស់នេះ គឺជាភារកិច្ចរបស់និយោជក និងអ្នកគ្រប់គ្រងតែប៉ុណ្ណោះ។

## ៣.២ លក្ខខ័ណ្ឌនៃការរស់នៅ

ជាង ៩០% នៃចំនួនស្ត្រីដែលត្រូវបានសំភាសន៍បាននិយាយថា ពួកគេបានចែកចំណែកនៃការរស់នៅក្នុងបន្ទប់មួយដ៏តូច និងនៅជិតរោងចក្ររបស់ពួកគេ ជាមួយមនុស្សចំនួនពី ៤នាក់ ទៅ ៥នាក់ផ្សេងទៀត ដើម្បីអាចសន្សំលុយបានខ្លះ។ ស្ត្រីភាគច្រើនត្រូវចំណាយពី ៥ដុល្លា ទៅ ១០ដុល្លារសម្រាប់ថ្លៃឈ្នួលផ្ទះ អគ្គីសនី និងថ្លៃទឹកជាប្រចាំខែ។ ពាក់កណ្តាលនៃស្ត្រីទាំងអស់ បានរាយការណ៍ថា វាជាការលំបាកសម្រាប់ពួកគេ ក្នុងការធ្វើដំណើរទៅរោងចក្រក្នុង រដូវភ្លៀង ពីព្រោះទីកន្លែងដែលនៅជុំវិញបន្ទប់ជួលរបស់ពួកគេ គឺជោគជាំទៅដោយភក់ជ្រាំ។ ពួកគេទាំងអស់គ្នាបានលើកឡើងថា ពួកគេបរិភោគអាហារតិច ដើម្បីអាចសន្សំថវិកា។ ពួកគេចំនាយតែ ១ដុល្លា សម្រាប់ចំណីអារហារក្នុង ១ថ្ងៃ ជាពិសេសអាហារដែលគ្មានអនាម័យ លក់លើចញ្ចើមផ្លូវ។ ស្ត្រីម្នាក់ដែលមានអាយុ ២៩ឆ្នាំ ដែលជាស្ត្រីកម្មករ ចំណាកស្រុក ពីខេត្តកំពង់ធំបាននិយាយថា៖

*ខ្ញុំរស់នៅជាមួយនឹងមិត្តភក្តិ ៤នាក់ផ្សេងទៀត ដែលមកពីភូមិជាមួយខ្ញុំ។ ពួកយើងចំនាយ ២០ដុល្លារសម្រាប់ថ្លៃជួលផ្ទះ និង១០ដុល្លារទៀតសម្រាប់ថ្លៃទឹក ថ្លៃភ្លើង។ ទីកន្លែងដែលយើងរស់នៅពិតជាមាន*

*សភាពចង្អៀតខ្លាំងណាស់សម្រាប់យើង ប៉ុន្តែយើងគ្មានជម្រើស។ ពួកយើងត្រូវរស់នៅជាមួយគ្នាដើម្បីអាចសន្សំថវិកាបានខ្លះ។ យើងចំណាយតែ ០.៥ដុល្លា ទៅ ១ដុល្លារសម្រាប់អាហារប្រចាំថ្ងៃ។ យើងហូបរួមគ្នារៀងរាល់ថ្ងៃ។ អាហាររបស់យើងមិនល្អគ្រប់គ្រាន់សម្រាប់សុខភាពយើងឡើយ ប៉ុន្តែពួកយើងមិនដឹងថាត្រូវធ្វើឲ្យល្អប្រសើរយ៉ាងដូចម្តេច។គ្រួសាររបស់ខ្ញុំនៅឯផ្ទះត្រូវការឲ្យខ្ញុំផ្ញើថវិការទៅ អោយពួកគេសម្រាប់ការចំណាយទៅលើតម្រូវការប្រចាំថ្ងៃ ព្រោះពួកគេពុំមានការងារណាផ្សេងសម្រាប់ទ្រទ្រង់ជីវភាពគ្រួសារ ក្រៅពីការងារដាំដុះ។*

ជនចំណាកស្រុកត្រូវតែរស់នៅដោយខ្វះខាត ដោយសារតែប្រាក់ឧបត្ថម្ភអាហារដ៏ទាប។ បន្ថែមលើនេះទៀត អ្នកដែលត្រូវធ្វើដំណើរទៅរោងចក្រជាមួយគ្នា ពួកគេត្រូវចំនាយ ពី ៥ដុល្លាទៅ ១០ដុល្លារក្នុង ១ខែ សម្រាប់ថ្លៃធ្វើដំណើរ។ ទោះបីជាគ្រប់ការចំនាយទាំងអស់ ស្ត្រីដែលត្រូវបានសំភាសន៍បាននិយាយថា ពួកគេព្យាយាមផ្ញើប្រាក់សន្សំទៅផ្ទះដែលមានពី ២០ដុល្លារ ទៅ ៣០ដុល្លារ ក្នុង ១ខែ ។ ជាងពាក់កណ្តាលនៃស្ត្រីដែលត្រូវបានសំភាសន៍បានលើកថាប្រាក់ឈ្នួលអប្បបរិមា មិនគ្រប់គ្រាន់សម្រាប់ជួយទ្រទ្រង់ដល់តម្រូវការជាមូលដ្ឋាន ការស្នាក់នៅ ថ្លៃទឹក ថ្លៃភ្លើង និងថ្លៃថ្នាំព្យាបាលឡើយ។

**ការធ្វើទុកបុកម្នេញដើម្បីអោយត្រលប់ទៅធ្វើការខារវិញ**

នៅថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១០ មានកម្មករជាង ៣០០០នាក់ ដែលធ្វើការក្នុងរោងចក្រកាត់ដេរឈ្មោះ PCCS នៅទីក្រុងភ្នំពេញ បានធ្វើកូដកម្ម ដើម្បីតបតនឹងការព្យួរតំណាងសហជីពរបស់ពួកគេដោយសារតែមានជម្លោះពីការសុំច្បាប់ឈឺ។ រោងចក្រកាត់ដេរ PCCS គឺជាកម្មសិទ្ធិរបស់ថៅកែជនជាតិម៉ាឡេស៊ី និងជារោងចក្រផលិតទំនិញសម្រាប់ហាងសម្លៀកបំពាក់អន្តរជាតិ ដូចជា Gap និង Benetton ក៏ដូចជាការផលិតផលសម្រាប់កីឡាម៉ាកល្បីៗដូចជា Adidas និង Puma ។ មានប៉ូលីសជាង៣០០នាក់ ដែលប្រដាប់ដោយដំបងឆក់ បានប្រើប្រាស់ដំបងមូលវែង ដើម្បីវាយទៅលើស្ត្រីកម្មករ និងបានប្រើឧស្ម័នទឹកភ្នែក ដើម្បីបង្ខំឲ្យស្ត្រីកម្មករ ត្រលប់ទៅរោងចក្រវិញ។ មានស្ត្រីជាច្រើន ត្រូវទទួលរងរបួសនៅក្នុងការប៉ះទង្គិចគ្នាជាមួយនឹងប៉ូលីស ហើយពួកគេទាំងអស់គ្នាត្រូវបានគេចាប់បង្ខំឲ្យត្រលប់ទៅរោងចក្រវិញ ដោយគ្មានការឆ្លើយតបពីសំណើរបស់ពួកគេឡើយ។ ករណីនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពលំបាកក្នុងការអនុវត្តន៍សិទ្ធិរបស់កម្មករក្នុងព្រះរាជាណាចក្រកម្ពុជាពិសេសសិទ្ធិសេរីភាពក្នុងការចងក្រងជាសហគមន៍ ដែលសិទ្ធិនេះត្រូវបានការពារផងដែរ ដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

### ៣.៣ ការទទួលបានសេវា

ក្នុងខណៈពេលដែលមានអ្នកទិញជាជនបរទេសជាច្រើន (ម៉ាកទំនិញ) ដែលមានក្រមសីលធម៌ទាក់ទងនឹងកម្មករនៅក្នុងសង្វាក់នៃការផ្គត់ផ្គង់ទំនិញដល់ពួកគេដែលជាញឹកញាប់មានតែអ្នកគ្រប់គ្រងរោងចក្រដែលដឹងអំពីក្រមសីលធមនោះ។ មិនមានស្ត្រីណាម្នាក់ ដែលផ្តល់ការសម្ភាសន៍សម្រាប់របាយការណ៍នេះ បានដឹងអំពីក្រមសីលធម៌ពាក់ព័ន្ធនឹងការងាររបស់គេឡើយ។ កម្មករភាគច្រើនមានភាពស្រពិចស្រពិលអំពីម៉ាកសម្លៀកបំពាក់ដែលពួកគេកំពុងផលិត ដែលនេះបង្កើតឲ្យមានភាពអសមត្ថភាពសម្រាប់កម្មករក្នុងការស្វែងរកក្រមសីលធម៌ណាមួយដែលឆ្លើយតបចំពោះការងារពួកគេ។

ស្របតាមច្បាប់កម្ពុជារោងចក្រកម្ពុជា តម្រូវឲ្យគ្រប់រោងចក្រទាំងអស់ត្រូវបានតំណាងជាកម្មករដែលបោះឆ្នោតដោយកម្មករ ដែលតំណាងនេះមានតួនាទីក្នុងការជួយសម្របសម្រួលជម្លោះ។ ទោះបីជាយ៉ាងណាក៏ដោយមិនមានស្ត្រីណាមួយ ក្នុងចំណោមស្ត្រីដែលត្រូវបានសម្ភាសន៍ សម្រាប់របាយការណ៍នេះបានស្គាល់ថា នរណាជាតំណាងរបស់កម្មករនៅក្នុងរោងចក្ររបស់ពួកគេឡើយ។ កម្មការនីមួយចំនួនបាននិយាយថា៖ តំណាងកម្មករក្នុងរោងចក្រត្រូវបានជ្រើសរើសដោយនិយោជក ដូច្នេះអ្នកតំណាងទាំងនោះមិនធ្វើជាតំណាងដើម្បីផលប្រយោជន៍របស់កម្មករឡើយ។

ស្ត្រីជាង ៩០% នៃស្ត្រីទាំងអស់ដែលត្រូវបាន សម្ភាសន៍បានលើកឡើងថា៖ មានសហជីពនៅក្នុងរោងចក្ររបស់ពួកគេ ។ ចំនួនកម្មការនីជាងពាក់កណ្តាលបាននិយាយថា៖ មានសហជីពជាច្រើននៅក្នុងរោងចក្ររបស់ពួកគេ ដែលរួមមានសហជីពដែលបង្កើតឡើង ដោយរដ្ឋាភិបាល សហជីពដែលបង្កើតដោយ និយោជក និងសហជីពដែលដឹកនាំដោយកម្មករ ដែលនេះជាហេតុផលធ្វើអោយពួកគេមានការភ័ន្តច្រឡំក្នុងការចូលជាសមាជិកក្នុងសហជីព។ កម្មការនីជាងពាក់កណ្តាលទៀតបាននិយាយថា៖ សហជីពពិតជាសកម្មក្នុងការជួយកម្មករចរចារជាមួយនឹងម្ចាស់រោងចក្រអំពីម៉ោងការងារ ការងារបន្ថែមម៉ោង ឬអំពីការបណ្តេញចេញដោយ អយុត្តិធម៌ ។ មានស្ត្រី ២នាក់បាននិយាយថា៖ ពួកគេមានអារម្មណ៍ថា និយោជក និងអ្នកគ្រប់គ្រងរបស់ពួកគេ បានរើសអើងសមាជិកសហជីព ដូចជាពេលគេធ្វើអ្វីមួយខុស សមាជិកសហជីព ត្រូវប្រឈមមុខនឹងការបណ្តេញចេញពីការងារ ឬត្រូវ ទទួលពិន័យខ្លាំងជាងកម្មករ ដែលមិនមែនជាសមាជិកសហជីព។

ស្ត្រីទាំងអស់ដែលត្រូវបានសម្ភាសន៍សម្រាប់របាយការណ៍នេះបានរាយការណ៍ថា ៖ ពេលដែលពួកគេស្នើសុំអោយមានលក្ខខណ្ឌការងារប្រសើរជាងមុន ឬ ធ្វើកូដកម្មតបតនឹងការបណ្តេញចេញដោយអយុត្តិធម៌ ពួកគេធ្វើតាមរយៈអ្នកតំណាងសហជីព។ ប្រសិនបើពួកគេធ្វើកូដកម្ម ស្ត្រីទាំងអស់បាននិយាយថា៖ ថៅកែរោងចក្ររបស់ពួកគេកម្រនឹងឆ្លើយតបទៅតាមតម្រូវការដែលគេចង់បាន ហើយពួកគេបានលើកឡើងទៀតថា និយោជករបស់ពួកគេបានប្រើប្រាស់ប្រព័ន្ធតុលាការ ឬ ប៉ូលីស ដើម្បីបង្ខំអោយពួកគេត្រឡប់ទៅធ្វើការវិញ។

ស្ត្រីទាំងអស់ដែលត្រូវបានសម្ភាសន៍សម្រាប់ធ្វើ របាយការណ៍នេះ បាននិយាយថា៖ ពួកគេអាចសុំច្បាប់ឈឺបាន។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយមានកម្មការនីតិចជាងពាក់កណ្តាលនៃកម្មការនីទាំងអស់ដែលបានសម្ភាសន៍ អាចមានលទ្ធភាពទទួលបានច្បាប់សម្រាកពេលឈឺ (ដោយសារតែពួកគេមានវិញ្ញាប័នបត្រដែលចេញដោយគ្លីនិក ឬ មន្ទីរពេទ្យនៅប្រទេសកម្ពុជាបញ្ជាក់ថា ពួកគេមានជម្ងឺដែលវិញ្ញាប័នបត្រនេះមានតម្លៃថ្លៃ ក្នុងការទទួលបាន។ ប្រសិនបើពួកគេមិនអាចធ្វើការបង្ហាញពីវិញ្ញាប័នបត្រនេះទេ និយោជកនឹងកាត់ប្រាក់បៀវត្សរ៍របស់ពួកគេតាមរយៈពេលនៃច្បាប់ឈឺ)។ ពួកគេក៏មានបញ្ហានៅក្នុងការទទួលបានការទទួលស្គាល់ថាពួកគេមានជម្ងឺផងដែរ នៅពេលដែលពួកគេមានជម្ងឺបន្តិចបន្តួចដូចជា ឈឺក្បាល ដែលតម្រូវអោយឈប់សម្រាកព្យាបាលតែក្នុងរយៈពេលខ្លីនៅផ្ទះជំនួសអោយការសម្រាកនៅមន្ទីរពេទ្យ។

## ៣.៤ ការឆ្លើយតបថ្នាក់មូលដ្ឋាន

សហជីពបំពេញតួនាទីយ៉ាងសំខាន់នៅ ក្នុងការការពារ និងលើកកម្ពស់សិទ្ធិកម្មករនៅក្នុងវិស័យកាត់ដេរ និងវាយនភ័ណ្ឌ។ មានចំនួនសហជីពនៅក្នុងរោងចក្រក្នុងជាច្រើន កំពុងតែប្រតិបត្តការនៅតាមរោងចក្រ។ សហភាពសហជីព ជាញឹកញាប់មានទំនោរទៅកាន់បក្សនយោបាយ។ សហជីពនៅកម្ពុជាត្រូវបានបែងចែកជាទូទៅកចំនួន៣ប្រភេទ៖ សហជីពដែលមានទំនោរជាមួយគណបក្សកាន់អំណាច សហជីពដែលមានទំនោរជាមួយបក្សប្រឆាំង និងសហជីពដែលមិនមានទំនោរជាមួយគណបក្សនយោបាយណាមួយ។ ខណៈពេលដែលមានអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនប៉ុណ្ណោះដែលធ្វើការពាក់ព័ន្ធសិទ្ធិរបស់កម្មករកាត់ដេរ។ ពួកគេបានផ្តល់វគ្គបណ្តុះបណ្តាលផ្នែកច្បាប់ដូចជាសិទ្ធិរបស់ពលករ ឬ បានផ្តល់សេវាថែទាំសុខភាព និងការផ្តល់សេវាផ្នែកច្បាប់នៅពេល ដែលមាន

ករណីនៅតុលាការ ឬ នៅក្រុមប្រឹក្សាអាជ្ញាកណ្តាលជាដើម។ ប៉ុន្តែជំនួយផ្នែកច្បាប់នៅ មានកម្រិតនៅឡើយ ដោយសារឧបសគ្គថវិកា។ អង្គការមិនមែនរដ្ឋាភិបាល ២ ត្រូវបានសម្ភាសន៍ សម្រាប់ការស្រាវជ្រាវនេះ៖ មជ្ឈមណ្ឌលអប់រំច្បាប់ សហគមន៍ (CLEC) គឺជាអង្គការដែលផ្តល់ការបណ្តុះបណ្តាលផ្នែកច្បាប់ផ្តោតទៅលើសិទ្ធិកម្មករ នៅក្នុងការចូលជាសមាជិកសហជីព និងកម្មករផ្សេងទៀត និងសម្ព័ន្ធសហជីពប្រជាធិ តេយ្យកម្មករ កាត់ដេរកម្ពុជា (CCAWDU) គឺជាសម្ព័ន្ធមួយនៃសហជីពកម្មករដែលមានសមាជិកនៅក្នុងរោងចក្រកាត់ដេរ។ អង្គការទាំង ២ នេះ បានមើល ឃើញពីបញ្ហាប្រឈមសំខាន់ៗមួយចំនួន ដូចជា៖ កង្វះការទទួលខុសត្រូវ និងឆន្ទៈនយោបាយរបស់រដ្ឋាភិបាលក្នុងការឆ្លើយតបចំពោះការរំលោភសិទ្ធិរបស់កម្មករ។ រដ្ឋាភិបាលជាញឹកញាប់បានបង្ក្រាបការធ្វើកូដកម្មរបស់កម្មករដែលបាននិយាយថា៖ គឺជាកូដកម្មខុសច្បាប់ បន្ថែមលើនេះទៀត និយោជក ជាញឹកញាប់បានគំរាមកំហែងដល់កម្មករក្នុងការដាក់បណ្តឹងតទល់នឹងពួកគេនៅតុលាការ។

សមាជិកសហជីព និងសកម្មជនបាន ជួបប្រទះនឹងការបំភិតបំភ័យ និងការគំរាមកំហែង។ លើសពីនេះទៅទៀត រដ្ឋាភិបាលជាញឹកញាប់ បដិសេធមិនទទួលស្គាល់ ឬមិនស្តាប់ក្រុមអង្គការសង្គមស៊ីវិល និងសហជីព ដូច្នេះការចូលរួមពីកម្មករគឺមានកម្រិត។ អំឡុងពេលកម្មករមានសិទ្ធិក្នុងការចូលរួមជាមួយសហជីព កង្វះខាតនៃការសាមគ្គី ក្នុងចំណោមសហជីពបាន បង្កើតអោយមានភាពលំបាកនៅក្នុងការធ្វើសំណើសុំជារួមមួយ។

សកម្មជននៅក្នុងប្រទេសកម្ពុជា បាននឹងកំពុងធ្វើយុទ្ធនាការទាមទារអោយមានកិច្ចសន្យាការងារសម្រាប់ រយៈពេលវែងជាមួយ នឹងការបង្កើនអត្ថប្រយោជន៍សម្រាប់កម្មករ ក៏ដូចជាការបង្កើនប្រាក់ឈ្នួលអប្បបរមាយ៉ាងហោចណាស់ ៩៣ ដុល្លារក្នុង មួយខែ។ ពួកគេមិនត្រឹមតែធ្វើការនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិប៉ុណ្ណោះទេ ប៉ុន្តែពួកគេធ្វើការជាមួយ នឹងសហគមន៍អន្តរជាតិ ជាមួយសមាជិកសហជីពកម្មករអន្តរជាតិ សកម្មជនពលករ និងអ្នកប្រើប្រាស់ ដើម្បីដាក់សំពាធលើរដ្ឋាភិបាល អ្នកផ្គត់ផ្គង់ និងអ្នកបញ្ជាទិញអន្តរជាតិអោយគោរពសិទ្ធិកម្មការនីនៅប្រទេសកម្ពុជា។

## កំលាំងពលកម្មដែលមានប្រភពមកពីខាងក្រៅប្រទេសម៉ាឡេស៊ី

មានពលករទេសន្តប្រវេសន៍ចំនួនជាង ២.៣លាននាក់បានចុះបញ្ជីធ្វើការងារដោយស្របតាមកម្មវិធីចុះបញ្ជីជាផ្លូវការរបស់រដ្ឋាភិបាលម៉ាឡេស៊ីនាខែកក្កដា ឆ្នាំ ២០១១ ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏មានចំនួនពលករទេសន្តប្រវេសន៍ជាច្រើនទៀត ដែលសំរេចចិត្តមិនចុះបញ្ជីតាមប្រពន្ធ័នេះ[xvi]។ ពលករទេសន្តប្រវេសន៍នៅប្រទេសម៉ាឡេស៊ី បានធ្វើចំណាកស្រុកមកពីបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ និងបណ្តាប្រទេសនៅអាស៊ីខាងត្បូងដែលប្រហាក់ប្រហែលពាក់កណ្តាល មកពីឥណ្ឌូនេស៊ី និង មកពីប្រទេសផ្សេងទៀតដូចជាបង់ក្លាដេស នេប៉ាល់ ឥណ្ឌា កម្ពុជា និងប្រទេសហ្វីលីពីន ។ ជិត ៥០% នៃពលករទេសន្តប្រវេសន៍ ដែលចុះបញ្ជីធ្វើការងារតាមរោងចក្រ និងច្រើនជាង ២០% ធ្វើការងារសំណង់[xvii] ។ ជាមួយគ្នានេះផង ដែរមានពលករទេសន្តប្រវេសន៍ ប្រហែលជា ៣០០.០០០ នាក់ត្រូវបានដាក់អោយធ្វើការងារក្នុងរោងចក្រអេឡិចត្រូនិច ដែលមាន ៧០% ទៅ ៨០%ជាស្រ្តី [xviii]។ រោងចក្រកាត់ដេរ និង រោងចក្រអេឡិចត្រូនិច បានប្រើប្រាស់កំលាំងពលកម្មជាង ៦៨,០០០នាក់[xix] ។

ចាប់តាំងពីទស្សវត្សន៍៨០មកសេដ្ឋកិច្ចរបស់ ប្រទេសម៉ាឡេស៊ីបាននាំមុខយ៉ាងខ្លាំង តាមរយៈការនាំចេញវិស័យវាយនភណ្ឌ។ តម្រូវការកំលាំងពលកម្មទេសន្តប្រវេសន៍ មានការកើនឡើងជាខ្លាំងនៅក្នុងឧស្សាហកម្មបែបនេះ ដោយសារតែប្រជាពលរដ្ឋម៉ាឡេស៊ីមានកំណើនយឺតហើយជនជាតិម៉ាឡេស៊ី បង្វែទិសដៅរបស់ពួកគេឆ្ពោះទៅរកការងារដែលមានសុវត្ថិភាព និងមានសិទ្ធិក្នុងការសំរេចចិត្ត។ នៅក្នុងប្រទេសម៉ាឡេស៊ី គ្រាន់តែពលករទេសន្តដែលចុះបញ្ជីប៉ុណ្ណោះមានចំនួន ២០% នៃកំលាំងពលកម្មសរុបរបស់ជាតិ ប៉ុន្តែប្រសិនបើយើងធ្វើការពិចារណា ទៅលើពលករទេសន្តប្រវេសន៍ដែលមិនបានចុះបញ្ជីទៀតនោះ នោះចំនួនកំលាំងពលកម្មទេសន្តប្រវេសន៍ នឹងមានចំនួនច្រើនជាងនេះ ។

ការប្រកួតប្រជែងខាងផ្នែកសេដ្ឋកិច្ចរបស់ ប្រទេសម៉ាឡេស៊ី ពឹងផ្អែកទាំងស្រុងទៅលើកំលាំងពលកម្មដែលមានតំលៃថោករបស់ពលករទេសន្តប្រវេសន៍ ហេតុដូច្នេះហើយបានជារដ្ឋាភិបាលរបស់ប្រទេសនេះ បានអនុញ្ញាតអោយ មានការជួលកំលាំងពលកម្មទេសន្តប្រវេសន៍ចាប់តាំងពីទស្សវត្សន៍ទី៩០មក។ គោលនយោបាយស្តីពីការជួលកំលាំងពលកម្មបរទេសដែលបានដាក់អោយប្រើប្រាស់ក្នុងឆ្នាំ ១៩៩១បានកំណត់ថា ការរៀបចំនិងចាត់ចែងអោយពលកបរទេសធ្វើការងារនៅប្រទេសម៉ាឡេស៊ី

ត្រូវតែធ្វើឡើងអោយដូចកម្មករក្នុងស្រុកដែ ដែលរួមមានទាំងប្រាក់ឈ្នួល ផលប្រយោជន៍ កិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរ ម្ហូបអាហារ និងការស្នាក់នៅ ។ ទោះបីជាគោលនយោបាយបានកំណត់បែបនេះក៏ដោយ ក៏ ពលករទេសន្តរប្រវេសន៍ត្រូវបានគេបដិសេធមិនអោយទទួលបានប្រាក់ឈ្នួលសមរម្យ និងមិនមានភាពស្មើភាពគ្នាជាមួយនិង កម្មករក្នុងស្រុកជាងពីរទស្សវត្សន៍មកហើយ ។

ដើម្បីជំរុញអោយសេដ្ឋកិច្ចជាតិ មានការកើនឡើង រដ្ឋាភិបាលប្រទេសម៉ាឡេស៊ីបានលើក ទឹកចិត្តអោយវិនិយោគគិនបរទេស ធ្វើការវិនិយោគលើវិស័យវាយនភណ្ឌ និង វិស័យអេឡិចត្រូនិក តាមរយៈការបង្កើតអោយមានតំបន់ឧស្សាហកម្មជាង ២០០ និងតំបន់សេដ្ឋកិច្ចពិសេសចំនួន១៨ ជាមួយ និងហេដ្ឋារចនាសម្ពន្ធ័នានាពេញលេញដូចជាផ្លូវថ្នល់ និង ទឹក ប្រពន្ធ័ទំនាក់ទំនងដើម្បីប្រែក្លាយតំបន់ទាំងនោះ អោយក្លាយជាតំបន់នាំចេញមួយ ។

ក្រុមហ៊ុនដែលវិនិយោគ ក្នុងតំបន់សេដ្ឋកិច្ចពិសេស បានទទួលការលើកលែងពន្ធលើការនាំចូលនូវវត្ថុធាតុដើម ឧបករណ៍ និងសំភារៈផ្សេងទៀតដែលចាំបាច់សំរាប់ដំណើការផលិត ។ គោលនយោបាយរបស់រដ្ឋភិបាល បង្កើតឡើងដើម្បីរក្សាស្ថានភាពរបស់កម្មករអោយមានលក្ខណៈមិនទៀងទាត់ តាមរយៈការរិតត្បិតសិទ្ធិខាងផ្នែកគ្រួសារ ហើយធ្វើអោយកម្មករទាំងនោះពឹងផ្អែកទាំងស្រុងទៅលើនិយោជករបស់ពួកគេ ។ ឧទាហរណ៍ពលករទេសន្តប្រវេសន៍ដែលគ្មានជំនាញ និងពាក់កណ្តាលជំនាញ មិនត្រូវបានគេអនុញ្ញាតអោយរៀបការជាមួយជាមួយជនជាតិម៉ាឡេស៊ីឡើយ និងមិនត្រូវបានផ្តល់ការអនុញ្ញាតិអោយស្នាក់ ទទួលបានសញ្ជាតិ និងត្រូវបានគេចាប់បង្ខំអោយធ្វើតេស្តឈាមស្វែងរកមេរោគអេដស៍ និងជំងឺអេដស៍ របេង និងផ្ទៃពោះ ហើយនៅក្នុងករណីដែលគេរកឃើញនោះ ពលករទេសន្តប្រវេសន៍ទាំងនោះត្រូវគេចាប់ បញ្ជូនត្រលប់មកវិញដោយបង្ខំ ។ ជាមួយគ្នានេះផងដែ ពលករទាំង នោះក៏ប្រឈមមុខ និងការឃាត់ខ្លួនតាមផ្លូវ តាមផ្ទះពីសំណាក់ប៉ូលីស និងអាជ្ញាធរអន្តោប្រវេស ហើយបន្ទាប់មកពួកគេត្រូវគេយកទៅ ឃុំខ្លួននៅមន្ទីឃុំឃាំងអន្តោប្រវេសន៍ តាមរយៈគោលនយោបាយបំភិតបំភ័យរបស់ម៉ាឡេស៊ី ។ នៅពេលដែលពលករដាក់ពាក្យបណ្តឹងប្រឆាំងនិងនិយោជកនោះ ពួកគេក៏ត្រូវប្រឈមុខនិងការបណ្តេញចេញពីការងារ និងត្រូវគេបញ្ជូនត្រលប់មកវិញ ប្រសិនបើពលករ ណាមួយត្រូវបានគេរកឃើញថាមានសកម្មភាព នៅក្នុងការប្រមូលផ្តុំ និងការចងក្រងគ្នា[xx]។

និយោជកដែលជួលកម្មករនិយោជិតជាជនជាតិបរទេសដែលមានចំនួនតិចជាង៥០នាក់ នោះតម្រូវអោយនិយោជកនោះជួលកម្មករនិយោជិតទាំងនោះ តាមរយៈទីភ្នាក់ងារមួយផ្សេងទៀត ដែលតាមរយៈប្រពន្ធ័ធ្វើអោយកម្មករនិយោជិត បាត់បង់ទំនាក់ទំនងការងារជាមួយទីកន្លែងធ្វើការងាររបស់ពួកគេ (ថៅកែ) ការដាក់ចេញគោលនយោបាយបែបនេះ ក្នុងឆ្នាំ ២០០៦ បានធ្វើអោយមានការកើនឡើងនូវទីភ្នាក់ងារផ្គត់ផ្គង់កំលាំងពលកម្មបរទេសចំនួន២៧៧ក្នុងកំឡុងពេល២ឆ្នាំ។ គោលនយោបាយបែបនេះបានបង្កើតនូវបញ្ហាជាច្រើនដល់ពលករទេសន្តប្រវេសន៍ ដោយសារតែពួកគេ ត្រូវបានជួលដោយស្របច្បាប់ ពីសំណាក់ទីភ្នាក់ងារទាំងនោះ ជាជាងការជួលដោយផ្ទាល់ពីសំណាក់ថៅកែរបស់ពួកគេ ។ ពួកគេមិនមានសិទ្ធិចូលរួមក្នុងការចរចារពាក់ពន្ធ័សិទ្ធិ ការងារ និងលក្ខខណ្ឌការងារនៅទីកន្លែងធ្វើ ការងារទេ[xxi] ។

ច្រើនជាងនេះទៅទៀត កិច្ចសន្យាការងាររបស់ ពួកគេបានចែងយ៉ាងច្បាស់ ពីការហាមប្រាមពួកគេមិនអោយចូលរួមក្នុងសហជីព និងសមាគមផ្សេងឡើយ ។ ទង្វើទាំងនេះបានបង្ហាញពីការបំពានដោយប្រយោលទៅលើច្បាប់ចំនួន ០៣ ដូចជា ច្បាប់ស្តីពីសហជីព ដែលបានអនុម័តឆ្នាំ ១៩៥៩ ដែលកំណត់ថាពលករទេសន្តប្រវេសន៍មានសិទ្ធិចូលរួមជាសមាជិកសជីព ច្បាប់ការផ្តល់ការងារអោយធ្វើដែលបានអនុម័តឆ្នាំ ១៩៥៥ បានកំណត់ថា រាល់កិច្ចសន្យាការងារទាំងឡាយណា មិនត្រូវចែងពីការហាមប្រាមកម្មករនិយោជិតក្នុងការចូលរួមជាសមាជិកសហជីពឡើយ ហើយនិងច្បាប់ស្តីពីទំនាក់ទំនងក្នុងវិស័យឧស្សាហកម្ម បានអនុម័តឆ្នាំ ១៩៦៧ បានកំណត់ថា គ្មានកម្មករនិយោជិតណាមួយត្រូវបានគេបណ្តេញ ចេញពីការងារ ដោយសារហេតុផលចូលជា សមាជិកសហជីពនោះឡើយ ។

ទោះបីជាមានការទាមទារ ពីសំណាក់កម្មករ សហជីព អង្គការសង្គមស៊ីវិលយ៉ាងណាក៏ដោយរដ្ឋាភិបាលម៉ាឡេស៊ីនៅតែបន្តធ្វើការអនុម័តច្បាប់ការផ្តល់ការងារអោយធ្វើ (ការធ្វើវិសោធនកម្មលើច្បាប់ ១៩៥៥) នៅក្នុងឆ្នាំ ២០១១ តាមរយៈសភានៅចុងឆ្នាំ ២០១១ ខាងមុខនេះ ។ នៅពេលចូលជាធរមាន ច្បាប់នេះនិងធ្វើការពិចារណាក្នុងការផ្តល់សិទ្ធិអោយទីភ្នាក់ងារជ្រើសទាំងនោះទទួលបានឋានៈជានិយោជក របស់កម្មករនិយោជិតដែលគេបានជួល ។ សំណើដែលបានលើកឡើងអោយមានការធ្វើវិសោធនកម្មនេះ និងធ្វើអោយប៉ះពាល់ដល់ សិទ្ធិរបស់កម្មករ សហជីព និងទំនាក់ទំនងការងាររបស់កម្មករ និងអ្នកប្រើប្រាស់កំលាំង ពលកម្មចុងក្រោយ (និយោជក) ។

អេឡិចត្រូនិចបានក្លាយខ្លួនជាវិស័យមួយ ដែលទទួលបានជោគជ័យបំផុតនៅក្នុងប្រទេសម៉ាឡេស៊ី វិស័យនេះបានចូលរួមចំនួន ៦០% ក្នុងវិស័យឧស្សាហកម្មនាំចេញរបស់ប្រទេសម៉ាឡេស៊ី ហើយវាមានតំលៃ ៨% នៃផលទុនរបស់ជាតិ ។ ភាគច្រើននៃរោងចក្រអេឡិចត្រូនិក នៅប្រទេសម៉ាឡេស៊ីជារបស់អ្នកវិនិយោគបរទេស ។ ក្រុមហ៊ុនបរទេសសំខាន់ៗ ដែលវិនិយោគក្នុងវិស័យនេះ (រួមបញ្ចូលទាំងអាមេរិក)រួមមាន Dell, Western Digital, Motorola, Seagate, Texas Instrument, Freescale Semiconductor ។ ក្រុមហ៊ុនមកពី បណ្តាប្រទេសអាស៊ីផ្សេងទៀតរួមមាន Fujitsu, Sony, BenQ, NEC, Panasonic, Hitachi, Toshiba, Sanyo, Alps, Brothers, Canon, JVC, Konika-Minolta, Rohm, Samsung, Nichia, Funai, TDK, Sharp, Mitsubishi, Fuji electronics ក្រុមហ៊ុនមកពីបណ្តាប្រទេសអឺរ៉ុបរួមមាន Bosch,Infineon, Osram, Siemens, Alcatel, Philips, STMicroelectronics and Marconi[xxii] ។ មានក្រុមហ៊ុនបញ្ញាទិញសំខាន់មួយចំនួនដែល មានប្រភពពីខាងក្រៅប្រទេស សំរាប់បញ្ញាទិញ វិស័យឧស្សាហកម្មវាយនភណ្ឌមាន ដូចជា Addidas, Nike, Reebok, Gap, Levi Strauss[xxiii]

## ៤.១. បទពិសោធន៍របស់ស្ត្រីចំណាកស្រុក

ស្ត្រីចំនួន៣០នាក់មកពីប្រទេសភូមា ហើយភាគច្រើនមានឯកសារស្របច្បាប់សំរាប់ធ្វើការងារ ត្រូវបានជ្រើសរើសដើម្បីធ្វើការសំភាសន៍ ស្ត្រីចំណាកស្រុកទាំងនោះមានអាយុចន្លោះពី ១៨ ឆ្នាំ ទៅ ៣២ ឆ្នាំ ហើយកំពុងបំពេញការងារ ក្នុងរោងចក្រកាត់ដេរ និងរោងចក្រអេឡិចត្រូនិក ។ ការសំភាសន៍បានបង្ហាញថាមូលហេតុចំបង ដែលពួកគេធ្វើចំណាកស្រុកមកប្រទេសម៉ាឡេស៊ី គឺដើម្បីស្វែងរកការរស់រានមានជីវិតសំរាប់ខ្លួនគេ និងក្រុមគ្រួសារ និងគេចចេញពីស្ថានភាពនយោបាយដ៏អាក្រក់នៅប្រទេសភូមា និងការស្វែងរកសេរីភាពដែលមានភាពប្រសើជាងប្រទេសរបស់ខ្លួន ។ អ្នកដែលត្រូវបានសំភាសទាំងអស់បានឆ្លើយថា ស្ថានភាពសេដ្ឋកិច្ច នៅក្នុងប្រទេសភូមារមានលក្ខណៈអាក្រក់ ដែលធ្វើអោយពួកគេមិនអាចចញ្ចឹមជិវិត ឬ ស្វែងរកលុយបានគ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារ ហើយដែលស្ទើតែស្ត្រីទាំង អស់បានទទួលស្គាល់ថា ការចញ្ចឹមគ្រួសារ ជាការតព្វកិច្ចរបស់ពួកគេជាកូនស្ត្រី ។ ស្ត្រីភូមារ ម្នាក់ដែលធ្វើការងារនៅក្នុងរោងចក្រ អេឡិច ត្រូនិកនៅក្នុងខេត្ត Selangor បាននិយាយថា ៖

*ខ្ញុំជាកូនស្រីច្បង ហើយខ្ញុំត្រូវទៅធ្វើការងារនៅ ប្រទេសណាមួយដែលមានប្រាក់ខែថ្លៃ។ ប្រាក់ខែរបស់ខ្ញុំសំរាប់ផ្គត់ផ្គង់ការចំណាយប្រចាំថ្ងៃរបស់ក្រុមគ្រួសារ និងថ្លៃសាលារៀនសំរាប់ ប្អូនស្រី ប្រុសរបស់ខ្ញុំ ។*

ភាគច្រើននៃស្ត្រី ដែលបានសំភាសន៍ បាននិយាយថា ពួកគេធ្វើការងារ ៦ ថ្ងៃក្នុងមួយអាទិត្យ និង ១៣ ម៉ោងក្នុងមួយថ្ងៃក្នុងរដូវ មមាញឹក និង៥ ថ្ងៃក្នុងមួយអាទិត្យ និង ៨ ម៉ោង និង៤៥ នាទីក្នុងមួយថ្ងៃក្នុងរដូវមិនសូវមមាញឹក រោងចក្រកំរនិងផ្តល់អោយការសំរាក ហើយ ភាគច្រើនអ្នកដែលបានសំភាសមិនទទួលបានការបង់លុយអោយនៅពេលវិស្សមកាល ឬ ការឈប់សំរាកឡើយ ។ នៅក្នុងខែដែលមាមាញឹក ពួកគេធ្វើការងារដោយគ្មានថ្ងៃឈប់សំរាក ភាគច្រើនបំផុតនៃអ្នកដែលបានសំភាសបាន និយាយថា ពួកគេមិនអាចប្រកែកមិនធ្វើការថែមម៉ោងបានឡើយ ។ ស្ត្រីភូមារម្នាក់ដែលបានសំភាស ក្នុងខេត្ត Selangor បាននិយាយថា ៖

*ថៅកែរបស់ខ្ញុំតែងតែនិយាយថា យើងមិនមានកម្មករគ្រប់គ្រាន់ទេ ប៉ុន្តែទោះបីជាពួកបានខិតខំធ្វើការងា យ៉ាងណាក៏ដោយ ក៏ពួកយើងមិនអាចធ្វើអ្វីបានច្រើនជាងហ្នឹងទៀតទេ ។ ខែមុនមានស្ត្រីកម្មករឥណ្ឌូស៊ីចំនួន ១៨នាក់ បានរត់គេចចេញពីរោងចក្ររបស់យើងដោយសារស្ថានការងារលំបាកពេក ។*

ភាគច្រើនស្ត្រី ដែលបានសំភាសបាននិយាយថា ពួកគេធ្វើការងារក្រោមសំពាធធ្ងន់ធ្ងរ និងមើលឃើញថាបរិយាកាសការងាររបស់ពួកគេពោពេញដោយស្រ្តេស ។ មានស្ត្រីម្នាក់ ដែលមកពីរោងចក្រអេឡិចត្រូនិក នៅក្នុងតំបន់ Butterworth, Penang បាននិយាយថា ៖

*អ្នកគ្រប់គ្រងរបស់ខ្ញុំតែងតែប្រាប់ខ្ញុំថា កុំអោយមានកុំហុស ហើយគាត់បានបន្ថែមទៀតថា ខ្ញុំធ្វើការងារយឺតណាស់ ។ ខ្ញុំមានអារម្មណ៍ហត់នឿយណាស់ ប៉ុន្តែអ្នកគ្រប់គ្រងនៅតែរឹតបន្តឹងខ្ញុំគ្រប់ពេលវេលា ។ ខ្ញុំមិនអាចដេរបាន ៦៥០ ដុំ តាមតម្រូវការបានទេនៅ ខែទី ១ ដោយសារតែខ្ញុំទើបតែចាប់ផ្តើមការងារថ្មី ខ្ញុំមិនដែលទទួលបានប្រាក់ថែមម៉ោង ហើយខ្ញុំទទួលបាន ប្រាក់ខែតែ ១៥០ រីងហ្គីត (ប្រហែល ៣០ដោន) ក្នុងមួយខែបន្ទាប់ពីការកាត់ចំណាយផ្សេងៗ។ ខ្ញុំចង់ផ្លាស់ប្តូរថៅកែរបស់ខ្ញុំ ប៉ុន្តែខ្ញុំមានអារម្មណ៍ភ័យខ្លាចជាមួយទីភ្នាក់ងារជ្រើសរើសរបស់ខ្ញុំ[xxiv] ។*

អ្នកសំភាសទាំងអស់បានប្រាប់ថា ថៅកែ ឬ ទីភ្នាក់ងារជ្រើសរើសរបស់គេបានដកហូតយកលិខិតឆ្លងដែន ហើយអោយពួកគេកាន់លិខិតឆ្លងដែនថតចំលងជំនួសប៉ុណ្ណោះ ។ ទោះបីបញ្ហានៃការដកហូតលិខិតឆ្លងដែនពលករទេសន្តប្រវេសន៍បរទេស ត្រូវបានរដ្ឋមន្ត្រីធនធានមនុស្សបានលើកយកមកពិភាក្សាដោយចំហរ ពីបញ្ហានៃភាពស្របច្បាប់របស់វាក៏ដោយ [xxv] ក៏អ្នកដែលត្រូវបានសំភាស

ភាគច្រើនមិនបានសុំអោយថៅកែរបស់ពួកគេ ប្រគល់លិខិតឆ្លងដែន និងលិខិតអនុញ្ញាតការងារមកវិញឡើយទោះបីជាពួកគេប្រឈមមុខនិងការឃាត់ខ្លួននៅពេល ដែលពួកគេធ្វើការងារដោយគ្មាន ឯកសារទាំងនោះក៏ដោយ ។

នៅក្នុងឆ្នាំ ២០០៩ រដ្ឋាភិបាលប្រទេសម៉ាឡេស៊ីបានប្រកាសថា រាល់ការចំណាយ និង ពន្ធលើកម្មករនិយោជិតបរទេសទាំងអស់ ត្រូវតែជាការទទួលខុសត្រូវរបស់ថៅកែ ហើយដែលការចំណាយទាំងនោះ មិនត្រូវបានអនុញ្ញាតអោយកាត់ចេញពីប្រាក់ខែរបស់កម្មករឡើយ ។ ទោះបីជាមានការប្រកាសបែប នេះក៏ដោយក៏ស្ត្រីភាគច្រើនដែលបានសំភាស បានរាយការណ៍ពីបទពិសោធន៍ របស់ពួកគេ ដែលទទួលរងនូវការកាត់ប្រាក់ខែផ្សេងៗពីគ្នា ដែលរួមមាន ពន្ធសំរាប់ការអនុញ្ញាតអោយធ្វើការងារ ចំណាយលើការធ្វើតេស្តសុខភាព ការសំអាតកន្លែងស្នាក់នៅ ការដឹកជញ្ជូន និងទណ្ឌកម្មនៅពេល ដែលពួកគេអវត្តមានពីទីកន្លែងធ្វើការងារដោយសារមានជំងឺ ឬ មកយឺត ។ វិធានការប្រាក់លើកទឹកចិត្ត អនុវត្តសំរាប់តែអ្នកបំពេញការងារទៀងទាត់ ប្រាក់លើកទឹកចិត្តនេះផ្តល់អោយតែកម្មករនិយោជិតណា ដែលមកបំពេញការងារបានល្អ និងមិនដែល អវត្តមានពីទីកន្លែងធ្វើការងារ ។ ប្រាក់លើកទឹក ចិត្តនេះបានដាក់បញ្ចូលជាមួយប្រាក់ឈ្នួល ដែលកម្មកររំពឹងនឹងទទួលបាន ប៉ុន្តែភាគច្រើនអ្នកដែលសំភាសបាននិយាយថា ពួកគេមិនបានទទួលទេ ហើយថែមទាំងបើកប្រាក់ឈ្នួលអោយពួកគេយឺត និងមិនទៀងទាត់ទៀតផង ។

**ខ្ញុំបានចុះឈ្មោះតាមរយះភ្នាក់ងារនៅប្រទេស ភូមារ ពួកគេបានប្រាប់ថា ខ្ញុំនឹងទទួលបានប្រាក់ឈ្នួល ៩០០ រីងហ្គីត (១៨០ដោន) មួយខែ ប៉ុន្តែឥឡូវនេះខ្ញុំដឹងថាពួកគេបោកប្រាស់ខ្ញុំ ។ ពួកយើងមិនទទួលបានប្រាក់ឈ្នួល តាមកិច្ចសន្យា និងអ្វីដែលពួកគេសន្យាទេ ខ្ញុំទទួលបានតែ ២៨០ រីងហ្គីត (៥៦ ដោន) បន្ទាប់ពីពួក គេបានកាត់កងរួច ។**

កម្មកររោងចក្រកាត់ដេខ្លះ មិនបានអាន ឬ ចុះហត្ថលេខាលើកិច្ចសន្យាការងាររបស់ពួកគេ។ ពួកគេចុះហត្ថលេខាលើក្រដាស ដែលបញ្ជាក់ពីចំនួនទឹកប្រាក់ ដែលពួកគេត្រូវសងត្រលប់ទៅទីភ្នាក់ងារជ្រើសរើសប៉ុណ្ណោះ និងអនុញ្ញាតអោយទីភ្នាក់ងារទាំងនោះ កាត់ប្រាក់ឈ្នួលរបស់ពួកគេ ។ ពលករចំណាកស្រុកមិនចង់ និយាយពីទីភ្នាក់ងារជ្រើសរើសរបស់ពួកគេទេ ប៉ុន្តែពួកគេទទួលស្គាល់ថាពួកគេបានបង់ប្រាក់ ចំនួនពី ៨០០ ដុល្លា ទៅ ១០០០ដុល្លាដើម្បីទទួលបានការងារធ្វើនៅប្រទេស

ម៉ាឡេស៊ី ។ ដើម្បីបានប្រាក់នេះត្រលប់មកវិញប្រាក់ចំនួន ៣០០ ទៅ ៤០០ រីងហ្គីត (៦០ ទៅ ៨០ ដោន) ត្រូវបានកាត់ចេញពីប្រាក់ខែរបស់ពួកគេក្នុងកំឡុងពេល ៦ ខែទៅ ៧ ខែតំបូងបន្ទាប់ពីពួកគេគេចាប់ផ្តើមធ្វើការងារនៅប្រទេសម៉ាឡេស៊ី ។ ស្ត្រីចំណាកស្រុកម្នាក់បាននិយាយថាៈ

*ការកាត់ប្រាក់ឈ្នួល សំរាប់សេវារកការងារអោយធ្វើវាពិតជាមានបញ្ហាខ្លាំងណាស់ ។ ទីភ្នាក់ងារជ្រើសរើសបានយកប្រាក់ចំណេញពីយើង ។ តំបូងខ្ញុំសង្ឃឹមថា ខ្ញុំអាចរកប្រាក់បង់អោយទីភ្នាក់ងារជ្រើសរើស ដើម្បីបានធ្វើការងារនៅទីនេះ ប៉ុន្តែឥឡូវខ្ញុំគិតថាមកធ្វើការងារមិនស្របច្បាប់ប្រសើជាង ដោយខ្ញុំមិនចាំបាច់បង់លុយអោយទីភ្នាក់ងារ ហើយខ្ញុំអាច ផ្ញើលុយត្រលប់ទៅផ្ទះបាន ។*

តំលៃផ្លាស់ប្តូរទីកន្លែងការងារមានតំលៃខ្ពស់ នៅពេលពលករទេសន្តប្រវេសចង់ផ្លាស់ប្តូរទីកន្លែងធ្វើការងាររបស់ខ្លួន ។ តាមការអោយដឹងពីស្ត្រីភូមារម្នាក់ដែលផ្លាស់ប្តូទីកន្លែងធ្វើការងារពីរោងចក្រកាត់ដេរនៅតំបន់ Suban Jala, Selangor ទៅ Butterworth Penang បានអោយដឹងថាៈ

*ភ្នាក់ងារជ្រើសរើស បានកាត់ប្រាក់ឈ្នួលខ្ញុំ ៥០០ រីងហ្គីត (១០០ ដោន) ក្នុងមួយខែ សំរាប់ សេវាជ្រើសរើស និងរកការងារអោយធ្វើ និងការចំណាយផ្សេងៗទៀត ។ ដោយសារតែចំណាយខ្ពស់ ខ្ញុំមិនអាចសន្សំលុយបានទេ ដូច្នេះខ្ញុំសំរេចចិត្តចាកចេញពីភ្នាក់ងារ និងរោងចក្រនោះ ។ នៅពេលដែលខ្ញុំសុំលិខិតឆ្លងដែន និងលិខិតអនុញ្ញាតអោយធ្វើការងារកវិញ ពួកគេបាននិយាយថា ខ្ញុំត្រូវតែបង់លុយអោយពួកគេបន្ថែមចំនួន១៥០០ រីងហ្គីត (៣០០ដោន)ទៀត ដល់ភ្នាក់ងារជ្រើសរើស ។*

ដោយសារតែការអនុវត្តមិនស្របច្បាប់ទាំងនេះហើយ បានធ្វើអោយកម្មករមិនអាចសន្សំលុយបានតាមការសន្យារបស់ពួកគេ ។ ពលករចំណាកស្រុកទាំងអស់ ទទួលបានប្រាក់ឈ្នួល តិចជាង ៥០០ រីងហ្គីត (១០០ដោន) មួយខែ ហើយបើប្រៀបជាមួយកម្មករជនជាតិម៉ាឡេស៊ី ដែលទទួលបានពី ៩០០ ទៅ១២០០ រីងហ្គីត (១៨០ ទៅ ២៤០ដោន) ។ ទោះបីជាមើលឃើញនូវស្ថានភាពដ៏អាក្រក់នេះក៏ដោយ ក៏ថៅកែ ឬ អ្នកបញ្ជាទិញខ្លះប្រើប្រាស់នូវប្រពន្ធ័កំណត់ចំនួនទិន្នផល ជាជាងម៉ោងធ្វើការងារ។ យោងតាមស្ត្រីចំណាកស្រុក ដែលធ្វើការអោយ រោងចក្រកាត់ដេ សំរាប់ផលិតសំលៀកបំពាក់អោយក្រុមហ៊ុន Eider UK, Reebok, Addidas, and Nike បាននិយាយថា *" រោងចក្រតំរូវអោយយើងដេ*

*អោយបាន ២០០ អាវក្នុងរយៈពេល ៨ ម៉ោង។ ដូច្នេះយើងត្រូវធ្វើការថែមម៉ោងដើម្បី អោយគ្រប់ចំនួន ហើយយើងមិនទទួលបានប្រាក់ថែមម៉ោងទេ "*

គ្រប់អ្នកសំភាសទាំងអស់ បាននិយាយថា ទោះបីជាពួកគេខំធ្វើការងារថែមម៉ោង ក៏ដោយ ក៏ប្រាក់ឈ្នួលរបស់ពួកគេមិនគ្រប់គ្រាន់ដែ សំរាប់ចំណាយទៅលើការរស់នៅ ។ តាមសំដីរបស់ស្ត្រីចំណាកស្រុកម្នាក់ដែលធ្វើការងារនៅក្នុងរោងចក្រកាត់ដេរតំបន់ Kajang បាននិយាយថា *" ប្រសិនបើអ្នកសួរយើងថា តើយើងត្រូវការប៉ុន្មាន ដើម្បីរស់នៅអោយបាន សមរម្យ និងមានលុយផ្ញើទៅផ្ទះ ខ្ញុំគិតថា ប្រហែលជា ១០០០ រីងហ្គីត (២០០ដោន) មួយ ខែ ។ ប៉ុន្តែខែមុនបន្ទាប់ពីក្រុមហ៊ុនកាត់ ខ្ញុំសន្សំបានតែ ៣២០រីងហ្គីត (ប្រហែល ៦៥ ដោន) ។*

នៅក្នុងរោងចក្រកាត់ដេរតូចមួយនៅក្នុង រដ្ឋ Penang កម្មករទាំងអស់ធ្វើការនៅទីនោះដោយស្របច្បាប់ ប៉ុន្តែពួកគេបានជ្រើសរើសការធ្វើ ការងារដោយមិនស្របច្បាប់វិញ ដោយសាតែពួកគេអាចសន្សំបានប្រាក់ច្រើនជាង និងមិនចាំបាច់ទទួលបន្ទុកបង់ប្រាក់អោយភ្នាក់ងារទៀតផង ។ ស្ត្រីចំណាកស្នាក់ដែលធ្វើការងារនៅទីនោះបាននិយាយថា " យើងរកប្រាក់បាន ៤០០ ទៅ ៥៥០ រីងហ្គីត (៨០ ទៅ ១១០ដោន)ក្នុងមួយខែ ។ ខ្ញុំបានផ្ញើលុយទៅផ្ទះនៅប្រទេសភូមារចំនួន ២០០ ទៅ ៣០០ រីងហ្គីត (៤០ ទៅ ៦០ដោន)ក្នុងមួយខែ ។ ឥឡូវនេះ ខ្ញុំអាចសន្សំប្រាក់បានច្រើនជាងពេល ដែលខ្ញុំធ្វើការងារមានលិខិតអនុញ្ញាត ។ មានស្ត្រីម្នាក់ទៀតបាននិយាយថា *" ពីមុនទោះជាខ្ញុំមាន លិខិតឆ្លងដែន និងលិខិតអនុញ្ញាតអោយធ្វើការងារ ប៉ុន្តែខ្ញុំមិនដែលឃើញវាទេ ។ វាមិនខុសគ្នាទេការធ្វើការងារដោយមាន ឯកសារ និង គ្មានឯកសារ ប៉ុន្តែបញ្ហានៅពេលដែលខ្ញុំត្រូវការ ត្រលប់ទៅផ្ទះវិញ ខ្ញុំមិនដឹងត្រូវធ្វើយ៉ាងណាទេ នៅពេលត្រលប់ទៅផ្ទះវិញដោយគ្មាន លិខិតឆ្លងដែន "*

### ៤.២. លក្ខខណ្ឌនៃការរស់នៅ

ភាគច្រើនបំផុតនៃស្ត្រី ដែលបានសំភាសបាននិយាយថា ពួកគេបានរស់នៅទីកន្លែងដែលថៅកែរបស់ពួកគេបានផ្តល់អោយ នៅជិតទីកន្លែងធ្វើការងារ ជាមួយនិងកម្មករជាច្រើនទៀត ។ ស្ត្រីចំណាកស្រុកម្នាក់នៅតំបន់ Shah Alam បាននិយាយថានាងរស់នៅជាមួយកម្មករ ១៧នាក់ផ្សេងទៀត ហើយបន្ទប់របស់ នាងស្នាក់នៅមានទំហំតែ ៣ ម៉ែត្រការ៉េតែប៉ុណ្ណោះ ។ ស្ត្រីចំណាកស្រុកត្រូវ

ចំណាយ ៨ទៅ ១០ រីងហ្គីត (១.៦០ ទៅ ២ ដោន) រាល់ខែសំរាប់ថ្លៃទឹក ភ្លើង និងថ្លៃផ្សេងៗទៀត ។ ស្ត្រីចំណាកស្រុកមួយក្រុមនៅតំបន់ ButterWorth, រដ្ឋ Penang បានអះអាងថា៖

*យើងចំណាយ ៨ រីងហ្គីត (១.៦០ដោន) សំរាប់ថ្លៃអគ្គីសនីមួយខែ ២ រីងហ្គីត (០.៤០ដោន) មួយខែសំរាប់ថ្លៃទឹក ។ ខែមុនកន្លែងស្តុកទឹក នៅកន្លែងយើងខូច ដូច្នេះយើងត្រូវចំណាយលើថ្លៃជួសជុលអស់ ២៧ រីងហ្គីត (៥.៤០ដោន) ក្នុងម្នាក់ ។ នៅក្នុងកន្លែងយើងស្នាក់នៅមានមនុស្ស ១០នាក់រស់នៅជាមួយគ្នា ក្នុងបន្ទប់គេងពី ដែលមានតែបង្គន់តែមួយប៉ុណ្ណោះ។*

ភាគច្រើនស្ត្រី ដែលបានសំភាសមានអារម្មណ៍ថា ពួកគេទទួលការរើសអើងពីសំណាក់សង្គមម៉ាឡេស៊ី ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ពួកគេក៏មិនតវ៉ាអ្វីដែ ដោយសារតែអត្ថិភាពរបស់ពួកគេគឺរក្សាការងារគេអោយបានល្អ ។ ក្នុងចំណោមទីកន្លែងពីបី ដែលមានសំរាប់ពួកគេជួបជុំគ្នា ក៏មានវត្តភូមារដែលជនជាតិភូមារអាចទៅកាន់ទីនោះ នៅកំលុងពេលបុណ្យព្រះពុទ្ធសាសនា ហើយនិងទីផ្សាពេលល្ងាចដែលពួកគេអាចជួបគ្នា ជាមួយជនជាតិភូមារផ្សេងទៀត ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ភាគច្រើននៃពួកគេមិនហ៊ាននិយាយភាសារ ភូមារនៅទីសាធារណទេ។ ស្ត្រី ៧នាក់ក្នុងចំណោមស្ត្រី ៣០នាក់ដែលសំភាស អាចនិយាយភាសា បាហាសាម៉ាឡាយូ (ភាសារក្នុងស្រុកម៉ាឡេស៊ី) ឬ ភាសារអង់គ្លេស ។ កង្វះខាតចំណេះដឹងផ្នែកភាសារបានដើតួរនាទីយ៉ាងសំខាន់ក្នុងការផ្តាច់ចេញពលករចំណាកស្រុកពីសហគមម៉ាឡេស៊ី មានតែស្ត្រីតិចតួចប៉ុណ្ណោះ ដែលមានមិត្តភក្រ័ជាជនជាតិម៉ាឡេស៊ី ហើយអ្នកទាំងនោះជា មិត្តភក្រ័របស់ពួកគេនៅទីកន្លែងធ្វើការងារ ។ ក្រៅពីបញ្ហាភាសារការផ្តាច់ចេញពួកគេពីសង្គមម៉ាឡេស៊ី កើតមានឡើងដោយសារកង្វះខាតពេលវេលា និង ឳកាស និងការរឹតត្បឹតក្នុងការធ្វើដំណើរដោយសារតែពួកគេមានបានកាន់លិខិតឆ្លងដែន និងលិខិតអនុញ្ញាតអោយធ្វើការងារ ។

ស្ត្រីភាគច្រើនបានអោយដឹងថា ពួកគេបានទូរសព្ទ័ទៅផ្ទះមួយដងក្នុងមួយខែ ដោយប្រើប្រាស់ទូរសព្ទ័របស់អ្នកជិតខាង ជារៀយៗបន្ទាប់ពីពួកគេបានផ្ញើលុយទៅក្រុមគ្រួសារ ។ មានស្ត្រី៥នាក់ក្នុងចំណោមស្ត្រី ដែលបានសំភាសបាននិយាយថា ពួកគេមិនទាន់បានទូរសព្ទ័ទៅផ្ទះទេ ដោយសារតែពួកគេមិនទាន់មានលុយគ្រប់គ្រាន់ដើម្បីផ្ញើទៅផ្ទះ ។ ស្ត្រីម្នាក់ ដែលធ្វើការងារនៅ Penang បានអោយដឹងថា *" ខ្ញុំនឹងក្រុមគ្រួសារណាស់ ប៉ុន្តែខ្ញុំមិនទាន់ ទំនាក់ទំនងទៅពួកគាត់ទេ ដោយសារខ្ញុំខ្លាច ពេលដែលខ្ញុំទូរសព្ទ័ទៅពួកគេសុំលុយ។ កាលពីខែមុនខ្ញុំសន្សំលុយបានតែ ១៧៦ រីងហ្គីតទេ (៣៥.២០ដោន) ហើយខ្ញុំ*

*បានចំណាយលុយ ទាំងនោះសំរាប់ខ្លួនខ្ញុំអស់ហើយ។ ខ្ញុំរង់ចាំខែ ណា ដែលខ្ញុំអាចសន្សំលុយបានគ្រប់គ្រាន់សំរាប់ ខ្ញុំនិងទូរសព្ទ័ទៅកេពួកគេ ” ។*

## ៤.៣ ការទទួលបានយុត្តិធម៌

នៅពេលដែលអ្នកបញ្ជាទិញបរទេស ចុះកិច្ចសន្យាជាមួយរោងចក្រម៉ាឡេស៊ី ពួកគេប្រហែលជាមានក្រមសិលធម៌របស់ពួកគេ ប៉ុន្តែ ព័ត៌មានពីក្រមសិលធម៌នោះ មិនត្រូវបានផ្សព្វផ្សាយអោយកម្មករបានដឹងទេ ។ នៅពេលណា ដែលមានអ្នកមកធ្វើទស្សនកិច្ច នៅរោងចក្រតំណាងកម្មករត្រូវបានខាងរោងចក្រ ជ្រើសរើសឡើងដើម្បីជួបជាមួយគេ ។ ស្ត្រីមួយក្រុមដែលធ្វើការងារនៅតំបន់ Selangor បាន អោយដឹងថា ៖

***រយៈពេល ពី ឬ បី ខែកន្លងទៅនេះ ពួកយើងបានឃើញជនជាតិជប៉ុនមកកាន់រោងចក្រ។ មួយថ្ងៃមុននេះ អ្នកគ្រប់គ្រងរបស់យើងបាន ប្រាប់ពួកយើងអោយសំអាតរោងចក្រ និងបន្ទប់ស្នាក់នៅរបស់ពួកយើង ។ ក្រោយមកទើបយើងដឹងថា គណៈប្រតិភូនោះមកពីក្រុម អ្នកបញ្ជាទិញដែលល្បីឈ្មោះ ដើម្បីមកត្រួតពិនិត្យ មើលលក្ខខណ្ឌការងាររបស់ពួកយើង ។ ប៉ុន្តែ អ្វីជាបញ្ហានោះ គ្រប់តំណាងកម្មករទាំងអស់ ដែល ចូលរួមប្រជុំជាមួយគណៈប្រតិភូនោះ សុទ្ធតែត្រូវបានជ្រើសរើសដោយរោងចក្រ ។***

ការទទួលបានព័ត៌មានសំរាប់ជនចំណាកស្រុកជនជាតិភូមារ ត្រូវពឹងផ្អែកទាំងស្រុងទៅលើទស្សនាវត្តីចំនួន២ជាភាសារភូមារ ដែលមានតំលៃប្រហែលជា ២ រីងហ្គីត(០.៤០ ដោន)ក្នុងមួយក្បាល។ ការទំនាក់ទំនងរវាងជនចំណាកស្រុក និងអង្គការសង្គមស៊ីវិលត្រូវបាន គេមើលឃើញថាមានកំរិតផងដែរ ។ ស្ត្រីចំណាកស្រុក ភូមារម្នាក់បាននិយាយថា គាត់ធ្លាប់ជួបក្រុមភូមារមួយក្រុម ប៉ុន្តែក្រុមនោះមិនត្រឹមតែមិនបាននិយាយពីសិទ្ធិរបស់កម្មករប៉ុណ្ណោះទេ ពួកគេថែមទាំងមិនបានសាកសួរ ពីលក្ខខណ្ឌការងារ និងរស់នៅរបស់គាត់ទេ ។ ពួកគេមិនបានដឹងអ្វីទាំងអស់ពីសហជីពម៉ាឡេស៊ី ឬ អង្គការសង្គមស៊ីវិល ។

ពាក់ពន្ធ័ជាមួយនិងការថែទាំសុខភាពវិញ ច្បាប់ស្តីពីការផ្តល់ការងារអោយធ្វើដែលបានអនុម័តក្នុងឆ្នាំ ១៩៥៥ បានកំណត់ថា ការចំណាយទៅលើការថែទាំសុខភាពជាបន្ទុករបស់និយោជក ហើយកម្មករមានសិទ្ធិទទួលបានការចំណាយនៅពេលមានជំងឺ ប្រសិនបើជំងឺ ឬ គ្រោះថ្នាក់ ការងារកើត

ឡើងក្នុងកំឡុងពេលបំពេញការងារ ។ ប៉ុន្តែគ្មាននណាម្នាក់ក្នុងចំណោមស្ត្រី ដែលបានសំភាស បានទទួលការចំណាយនៅពេលមានជំងឺទេ ។ មានអ្នកខ្លះត្រូវទទួលការពិន័យ អ្នកខ្លះទទួលត្រូវគេបណ្តេញចេញពីការងារ នៅពេលដែលពួកគេឈប់នៅពេលមានជំងឺ ។ ស្ត្រីម្នាក់ដែលធ្វើការក្នុងរោងចក្រ ButterWorth, រដ្ឋ Penang បានអោយដឹងថា ***" នៅពេលដែលខ្ញុំមានអារម្មណ៍នៅពេលព្រឹក ខ្ញុំមិនអាចធ្វើដំណើទៅគ្លីនីកដោយផ្ទាល់ទេ ។ ខ្ញុំត្រូវធ្វើដំណើរទៅកាន់រោងចក្រ ដើម្បីសុំការអនុញ្ញាតពីអ្នកគ្រប់គ្រងទៅជួបគ្រូពេទ្យសិន"***

ស្ត្រីម្នាក់ទៀតដែលបានសំភាសមកពី Selangor បាននិយាយថា *" ពួកយើងមិនអាចទៅមន្ទីពេទ្យរដ្ឋបានទេ ដោយសាតែគ្មានលិខិតឆ្លងដែន ។ លិខិតឆ្លងដែនរបស់ពួកយើង ត្រូវបានភ្នាក់ងាររបស់យើងរក្សាទុក "* ដូច្នេះ នៅពេល ដែលពួកគេឈឺនៅទីកន្លែងធ្វើការងារ ស្ត្រីភាគច្រើនសំរាកក្នុងបន្ទប់ មួយម៉ោង ឬ ពីម៉ោង មុនពេលពួកគេចាប់ផ្តើមការងារជាថ្មី ។ ពួកគេទាំង អស់គ្នាប្រើប្រាស់ថ្នាំប៉ារ៉ាសេតាម៉ុល និង ប្រេងកូឡាប្រូបខ្លានៅពេលដែលពួកគេឈឺ ។

គ្មាននណាម្នាក់ក្នុងចំណោមស្ត្រី ដែលបានសំភាសបានទទួលការបណ្តុះបណ្តាល ពីសុវត្ថិភាពការងារ ។ កម្មករជារឿយៗទទួលរងការឈឺចាប់ចង្កេះ ដោយសារតែពួកគេអង្គុយយូរពេកនៅកន្លែងតែមួយ ឬ នៅក្នុងករណីខ្លះ ដោយសារតែពួកគេឈជាប់ៗ គ្នារយៈពេល ច្រើនម៉ោងពេក ។ ស្ត្រីពីនាក់បានប្រាប់ពីការ ឈឺចាប់នៅក្នុងភ្នែករបស់ពួកគេ ដោយសារតែ ពួកគេប្រឹង មើលសំភារៈអេឡិចត្រូនិកតូចៗយូរពេក ។ ទោះបីជាមានច្បាប់ស្តីពីសំណងគ្រោះថ្នាក់ការងារ ធានានូវសំណងនៅពេល មានគ្រោះថ្នាក់ការងារប៉ុន្តែគ្មាននណាម្នាក់ ក្នុង ចំណោមអ្នក ដែលសំភាសបានដឹងពីព័ត៌មាន នេះឡើយ ។

ភាគច្រើនបំផុត នៃស្ត្រីដែលសំភាសបានប្រាប់ថាពួកគេមិនដែលទទួលបានការអប់រំ ឬ បណ្តុះបណ្តាលពីសុខភាព និងសុខភាពផ្លូវភេទទេ ។ ផ្អែកតាមប្រពៃណីទំនៀមទំលាប់ ដែលកំណត់ថា ស្ត្រីដែលមិនទាន់រៀបការ មិនគួរធ្វើសកម្មភាពពាក់ពន្ធ័ផ្លូវភេទនោះ មានស្ត្រីជាច្រើនមានការស្ទាក់ស្ទើ ក្នុងការនិយាយពីបញ្ហាទាំងនេះ ។ មានស្ត្រីខ្លះនិយាយថា ពួកគេ មិនចាំបាច់ដឹងពីបញ្ហាសុខភាពផ្លូវភេទទេ ដោយសារតែពួកគេមិនទាន់រៀបការ។ មានតែ ស្ត្រីពីនាក់ប៉ុណ្ណោះដែលប្រាប់ថា ពួកគេធ្លាប់ទទួលការបណ្តុះបណ្តាល ពីអង្គការយូនីសេព្វ នៅប្រទេសភូមារពី ការប្រើប្រាស់ស្រោម អនាម័យ ។

## ៤.៤. អន្តរាគមន៍ពីអង្គការនៅមូលដ្ឋាន

មានអង្គការចំនួន ៥ ដែលធ្វើការជាមួយ ជនចំណាកស្រុកភូមារត្រូវបានសំភាស ដែលរួមមានៈ Multinational Women of Burma (MNWOB), Burma Campaign-Malaysia (BCM), National League for Democracy-Liberated Area, Burma (NLD-LA-Burma), Worker Hub for Change (WH4C) និង Network of Action for Migrant in Malaysia (NAMM) ។ គ្រប់អង្គការទាំងអស់លើកលែងតែ (MNWOB) សុទ្ធតែមាន ទំនាក់ទំនង ជាមួយកម្មករស្ត្រីចំណាកស្រុក ដែលធ្វើការងារក្នុងរោងចក្រកាត់ដេ និង អេឡិចត្រូនិក ។ (MNWOB) ធ្វើការងារជាមួយ ជាមួយកម្មករស្ត្រីចំណាកនៅក្នុងវិស័យផ្សេងៗទៀត ។

ការងារសំខាន់របស់អង្គការទាំងនោះផ្តោតទៅលើ ការផ្តល់យោបល់ផ្នែកច្បាប់ដែលពាក់ពន្ធ័ និងសិទ្ធិកម្មករចំណាកស្រុក និងទំនាក់ទំនងជាមួយអង្គការពាក់ពន្ធ័សហជីពដើម្បីផ្តល់ការគាំទ្របន្ថែម BCM និង NLD-LA-Burma ជាអ្នកផ្តល់សេវាផ្ទាល់ដល់កម្មកចំណាកស្រុក ដូចជាជូនកម្មករចំណាកស្រុកទៅមន្ទីពេទ្យជាដើម ទស្សនវិស័យរបស់ BCM គឺពង្រឹងអំណាចដល់ជនចំណាកស្រុក ដើម្បីអោយពួកគេក្លាយខ្លួន ជាភ្នាក់ងារសកម្មមួយ ដើម្បីអនាគតនៃការផ្លាស់ប្តូនៅភូមារ ដូច្នេះជនចំណាកស្រុកដែល ចូលរួមក្នុងសកម្មភាពរបស់ BCM ពួកគេត្រូវ រៀនសូត្រពីលទ្ធិប្រជាធិបតេយ្យព្រមជាមួយ និងសិទ្ធិរបស់កម្មករផងដែ ។ WH4C ធ្វើការងារលើការអប់រំពីសិទ្ធិការងារ និងសិទ្ធិមនុស្ស និងធ្វើការបណ្តុះបណ្តាលពីយន្តការក្នុងការទទួលបានសំណងខូចខាត នៅប្រទេសម៉ាឡេស៊ីដល់ជនចំណាកស្រុក។ អង្គការនេះ ក៏បានបង្កើតជាសំភារះផ្សព្វផ្សាយ សំរាប់កម្មករចំណាកស្រុកអោយយល់ពីសិទ្ធិ និងធ្វើយុទ្ធនាការតស៊ូ មតិ ដើម្បីអោយការផ្លាស់ប្តូគោលនយោបាយ ផងដែនៅកំរីតថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិផងដែរ ។ នៅកំរីតថ្នាក់ជាតិ WH4C ធ្វើការងារជាមួយ NAMM សហជីព និងនាយកដ្ឋានការងារ និងគណៈកម្មាធិការសិទ្ធិ មនុស្សថ្នាក់ជាតិ (Suhakam) ។ នៅថ្នាក់តំបន់ WH4C ធ្វើការងារជាមួយបណ្តាញ ចំណាក ស្រុកមេគង្គ (MMN) និង Asia Pacific Forum on Women, Law and Development (APWLD) និងនៅកំរីតអន្តរជាតិ WH4C ធ្វើការងារជាមួយ Clean Clothes Campaign (CCC), Good Electronic Network និង Worker Rights Consortium ។ រាល់អង្គការទាំងអស់ដែលសំភាសបានបញ្ជាក់ ថាពីសារសំខាន់នៃការបណ្តុះបណ្តាល និង ការពង្រឹងអំណាចដល់កម្មករ ដើម្បី

អោយពួកគេមានលទ្ធភាពស្វែងរកយុត្តិធម៌ និងធ្វើអោយ មានភាពប្រសើឡើង នូវស្ថានភាពរបស់ពួកគេ។ ការពង្រឹងអំណាចធ្វើឡើងតាមរយៈ ការបណ្តុះបណ្តាល និងការពិគ្រោះយោបល់លើ សិទ្ធិកម្មករ ច្បាប់ គោលនយោបាយ សិទ្ធិខាងផ្នែកសុខភាព និងជួយពួកគេអោយទទួលបាននូវសេវាសង្គមនានា ដូចជាសេវាសុខាភិបាល ។ នៅពេលដែលជនចំណាកស្រុក សំរេចចិត្តប្តឹង និយោជករបស់ពួកគេ ទៅកាន់នាយកដ្ឋានការងារ បន្ទាប់ពីពួកគេបានទទួលព័ត៌មាន ពាក់ពន្ធ័ ពីអង្គការពាក់ពន្ធ័ជនចំណាកស្រុកទាំង នោះនឹងត្រូវបានគេបញ្ជូនបន្តរ ទៅសហភាពការងារម៉ាឡេស៊ី ដែលនិងអមជនចំណាកស្រុកដែលមានបញ្ហានោះទៅតុលាការ និងបន្តជំនួយ ចាប់ផ្តើមពីចំណុចនោះទៅ ។

លើសពីនេះទៅទៀត ការសំភាសជាក្រុមបានយល់ព្រមទាំងអស់គ្នាពីការបណ្តុះបណ្តាល ជាពិសេសទៅលើសិទ្ធិស្ត្រី ។ ទោះបីជាយ៉ាងនេះក្តី អង្គការសហគមផ្សេងៗទៀត ដូចជាសហភាពការងារម៉ាឡេស៊ី NLD និង BCM ដែលជាអង្គការ មានទំនោលើបុរសនោះ បានមើលឃើញពីសារសំខាន់ ក្នុងការកែប្រែការបណ្តុះបណ្តាល ដោយផ្តោតលើសិទ្ធិស្ត្រី និងផ្តល់ពេលវេលា និង ទីកន្លែងអោយស្ត្រីចំណាកស្រុក បានពិភាក្សាពីស្ថានភាពរបស់ពួកគេដោយសេរី ។

បញ្ហាសំខាន់បំផុត ដែលកំណត់ដោយអង្គការ ទាំងអស់ គឺមានចំនួនជនចំណាកស្រុកភូមារ ជាច្រើនដែលមិនបានចុះបញ្ជីត្រឹមត្រូវ ដូច្នេះហើយវាមានការលំបាកសំរាប់ពួកគេក្នុងការទាមទារសិទ្ធិ និងសេរីភាពរបស់ខ្លួន ។ ស្ថានភាពបែបនេះ ក៏មានលក្ខណះតឹងតែងសំរាប់ជនចំណាកស្រុកភូមារ ដែលមានឯកសាត្រឹមត្រូវក្នុងការទទួលបានសេវាកម្មគាំទ្រពីស្ថានទូតរបស់ភូមាផងដែ ដែលខុសពីស្ថានទូតរបស់ប្រទេសដ៏ទៃទៀតដែលគេមាន អនុពន្ធ័ ការងារ និង/ឬ ផ្តល់កន្លែងស្នាក់នៅសំរាប់ជនចំណាកស្រុកដែលមានវិបត្តិ ។ អង្គការទាំងនោះបានសង្កេតឃើញថា នៅពេលជនចំណាកស្រុកភូមារ ដែលមានឯកសារទំនាក់ទំនងមកស្ថានទូតភូមារដើម្បីសុំជំនួយ ពួកគេត្រូវបានមន្ត្រីស្ថានទូតប្រាប់ថា ស្ថានទូតមិនអាចធ្វើអ្វីបានទេ ។

ក្រុមអង្គការទាំងនោះក៏បានកំណត់ពីបញ្ហាកង្វះខាតនៃការអនុវត្តច្បាប់ការងារដោយរដ្ឋាភិបាលម៉ាឡេស៊ី ព្រមជាមួយការអនុវត្តនូវគោលនយោបាយ និងការអនុវត្តនានាដែលមានលក្ខណះរើសអើងលើពលករចំណាកស្រុក និងអាកប្បកិរិយាប្រកាន់យកបុរសជាធំ នៅសហគមចំពោះជនចំណាកស្រុកជាស្ត្រី បានធ្វើអោយមានការលំបាកកាន់តែខ្លាំងឡើងៗសំរាប់ស្ត្រីចំណាកស្រុកក្នុងការទាមទារសិទ្ធិ

និងសេរីភាពរបស់ពួកគេ ។ ពួកគេបានចង្អុលបង្ហាញផងដែរថា រដ្ឋាភិបាលប្រទេសប្រភព (រដ្ឋសន្តិភាព និងក្រុមប្រឹក្សាអភិវឌ្ឍក្នុងប្រទេសភូមារ) ធ្វើការតែជាមួយទីភ្នាក់ងារជ្រើសរើស និងភ្នាក់ងារនៅក្រៅប្រទេសដើម្បី ប្រមូលកំរៃតែប៉ុណ្ណោះ ពួកគេមិនបានជួយអ្វី ច្រើនដល់ជនចំណាកស្រុកឡើយ ។

ទោះបីជាមានបញ្ហាជាច្រើនក៏ដោយ ក៏មាន សមិទ្ធិផល ដែលគួរអោយកត់សំគាល់មួយចំនួន បានសំរេចបានផងដែ ។ នៅក្នុង ២០០៩ WH4C និងដៃគូរបស់ខ្លួនបានធ្វើការងារជាមួយគ្នាដើម្បីជួយដល់កម្មករភូមារដែល ទទួលរងគ្រោះថ្នាក់នៅទីកន្លែងធ្វើការងារ ។ បន្ទាប់ពីគ្រោះថ្នាក់ការងារកម្មករនោះបាន បាត់បង់ការងាររបស់ខ្លួន និងបានក្លាយខ្លួនជា អ្នកដែលគ្មានការងារធ្វើ ហើយធ្វើអោយគាត់បាត់បង់លិខិតអនុញ្ញាតអោយធ្វើការងារ និងក្លាយខ្លួនជាជនចំណាកស្រុកគ្មានឯកសារ ។ អង្គការបានជួយអោយកម្មករនោះ ទទួលបាន នូវប្រាក់ឈ្នួល និងសំណងជំងឺចិត្តមកវិញ ។ នេះជាករណីទី ១ ដែលជនចំណាកស្រុកមិនមានឯកសារអាចមានលទ្ធភាពទាមទារផលប្រយោជន៍បានដោយជោគជ័យ ចាប់តាំង ពីពេលនោះមកមានការកើនឡើងនូវចំនួនបណ្តឹង ដែលធ្វើឡើងដោយជនចំណាកស្រុក ក្នុងការទាមទារសិទ្ធិរបស់ពួកគេ ។ ក្រុមអ្នកគាំទ្រទាំងនោះនៅតែបន្តលើកឡើង ពីបញ្ហាកង្វល់ ដែលកើតមានឡើង នៅសហាគមជនចំណាកស្រុក អោយបានដល់សាធារណជន និងអាជ្ញាធរពាក់ពន្ធ័ និងធ្វើការរាយការណ៍ ត្រលប់មកវិញ ពីចំណាត់ការរបស់អាជ្ញាធរមកសហាគមវិញ ។ ទំនុកចិត្តរបស់ជនចំណាកស្រុក ហាក់បីដូចជាមានការកើនឡើង ហើយពួកគេមានឆន្ទះកាន់តែខ្លាំងឡើងៗ ក្នុងការទាមទារសិទ្ធិរបស់ខ្លួន ។

## អ្នកការពារសិទ្ធិស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់

អង្គការ និងបុគ្គលដែលកំពុងតែធ្វើយុទ្ធនាការដើម្បីសិទ្ធិជនចំណាកស្រុក នៅប្រទេសម៉ាឡេស៊ី កំពុងតែប្រឈមមុខនិងគ្រោះថ្នាក់ ពីសំណាក់ក្រុមហ៊ុន និងរដ្ឋាភិបាលម៉ាឡេស៊ី ។ ករណីនេះជាការលើកឡើងពីវិវាទរវាង ក្រុមហ៊ុន Asahi kosei និងអ្នកការពារសិទ្ធិមនុស្ស Charl Hector:

Asahi Kosei Malaysia Sdn Bhd, ជាក្រុមហ៊ុនដែលគ្រប់គ្រងដោយជនជាតិជប៉ុន ដែលមានរោងចក្រប្រើប្រាស់កំលាំងពលកម្មជិត ១៧០០នាក់ ។ រោងចក្រនេះផលិតប្រអប់ជាតិអាលុយមីញ៉ូមស្រោបពីក្រៅ hard dish drive ។ ជនចំណាកស្រុកភូមារដែលធ្វើការងារនៅទីនេះបានរាយការថាពួកគេទទួលបានប្រាក់ខែតិចជាងការសន្យា ពិបាកក្នុងការសុំច្បាប់ឈប់សំរាកពេលមានជំងឺ និងការដកហូតលិខិតឆ្លងដែនរបស់ពួកគេ ។ លើសពីនេះទៅទៀត ពួកគេទទួលរងនូវការគំរាមកំហែង ក្នុងការបញ្ជូនពួកគេត្រលប់មកវិញ នៅពេលដែលពួកគេដាក់ពាក្យបណ្តឹងនៅក្នុងខែកុម្ភះ ២០១១ ទៅកាន់ គណះកម្មាធិការសិទ្ធិមនុស្ស នាយកដ្ឋានការងារ និងអ្នកការពារសិទ្ធិមនុស្ស Charl Hector ។

Charl Hector បានទំនាក់ទំនងទៅ Asahi Kosei ដើម្បីសុំការបំភ្លឺពីការចោទប្រកាន់លើបញ្ហាគំរាមកំហែងក្នុងការបញ្ចប់កិច្ចសន្យា និងការបញ្ជូនជនចំណាកស្រុកទាំងនោះ ត្រលប់មកវិញ ។ ក្រោយពីមិនបានទទួលការបំភ្លឺពី ក្រុមហ៊ុន Hector បានចងក្រងឯកសារទាំងនោះនិងដាក់ចូលប្លុករបស់គាត់ ។ បន្ទាប់មកក្រុមហ៊ុន ក៏បានដាក់ពាក្យបណ្តឹងសងសឹកគាត់វិញដោយទាមទាអោយគាត់សងជំងឺចិត្ត១០លានរីងហ្គីត (២លានដោន) និងអោយគាត់ធ្វើការសុំទោសជាសាធារណៈ និងលុបចោលនូវការផុសក្នុងប្លុករបស់គាត់ ។ ក្រុមហ៊ុនបាននិយាយថាគាត់បានបរិហារកេរ្តិ៍ដោយសារតែ ក្រុមហ៊ុនមិនមានទំនាក់ទំនងការងារណាមួយជាមួយជនចំណាកស្រុកទាំងនោះទេដោយសារតែជនចំណាកស្រុកទាំងនោះត្រូវផ្តល់អោយដោយភ្នាក់ងារមួយផ្សេង។ ករណីបានក្លាយជាសំនួរថាតើនណាជាអ្នកទទួលខុសត្រូវលើកម្មករទាំងនោះក្នុងនាមជានិយោជក ហើយបញ្ហានេះបង្ហាញពីភាពងាយរងគ្រោះក្នុងការទាមទារសិទ្ធិសំរាប់ជនចំណាកស្រុកនៅប្រទេសម៉ាឡេស៊ី ។

ក្នុងថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១ Charl Hector និង Asahi kosei បានឈានដល់ដំណោះស្រាយមួយដែលតម្រូវអោយ គាត់បង់ប្រាក់ ១ រីងហ្គីត សំរាប់ការចំណាយរឿងក្តី និង រីងហ្គីត លើថ្លៃខូចខាត ហើយថែមទាំងអោយគាត់ ផ្សព្វផ្សាយចំនួនកន្លះទំព័រពីការសំរេចនេះនៅទំព័រកាសែតជាតិចំនួន២ដែលចេញផ្សាយប្រចាំថ្ងៃ ។ ករណីនេះបានបង្ហាញពីផលប្រយោជន៍ ដ៏មានឥទ្ធិពលរបស់សាជីវកម្មមកលើអ្នកការពារសិទ្ធិមនុស្ស ។ ការប្រើប្រាស់ពាក្យបណ្តឹងបរិហារកេរ្តិ៍ ប្រឆាំងនិង អ្នកការពារសិទ្ធិមនុស្ស ដែលគ្រាន់តែរាយការពីករណីរំលោភបំពានសិទ្ធិមនុស្ស បានបង្កើតគំរូដ៏មានគ្រោះថ្នាក់មួយ ដែលធ្វើអោយមានភាពភ័យខ្លាចដល់ការងារស្របច្បាប់របស់អ្នកការពារសិទ្ធិមនុស្សនាពេលអនាគត ។

# សេចក្តីសន្និដ្ឋាន

ករណីសិក្សានៅប្រទេសថៃ ម៉ាឡេស៊ី និងកម្ពុជា បានបង្ហាញអោយឃើញយុទ្ធសាស្រ្តពីការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសទាំងបី ។ ប្រទេសនីមួយៗព្យាយាមអភិវឌ្ឍសេដ្ឋកិច្ចរបស់ខ្លួនតាមរយៈពង្រីកការនាំចេញរបស់ខ្លួន និងការទាក់ទាញវិនិយោគបរទេស តាមតែអាចធ្វើទៅបាន ។ ការខិតខំប្រឹងប្រែងទាក់ទាញវិនិយោគបរទេស របស់រដ្ឋាភិបាលនីមួយៗ ត្រូវបានពន្យល់ថាជាមធ្យោបាយក្នុងការពង្រឹងម៉ាក្រូសេដ្ឋកិច្ច ការបង្កើតការងារ និងកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសនីមួយៗ ។ ដើម្បីទាក់ទាញការវិនិយោគបរទេស រដ្ឋាភិបាលប្រទេសនីមួយៗបានបង្កើតជាតំបន់សេដ្ឋកិច្ចពិសេស ដែលតាមរយៈគោលនយោបាយនេះ ប្រាក់ឈ្នួលរបស់កម្មកត្រូវបានគេកំណត់ទាបបំផុត ដើម្បីរក្សារអោយមានការប្រកួតប្រជែងជាមួយប្រទេសផ្សេងទៀត ។ កម្មករចំណាកស្រុក ជាពិសេសស្រ្តីចំណាកស្រុក ដែលពួកគេត្រូវបានផ្តល់អោយស្ថានភាពមិនជាក់លាក់មួយ ដែលតាមស្ថានភាពនេះ ពួកគេមានភាពងាយស្រួលក្នុងការចាត់ចែង និងបោះបង់កំលាំងពលកម្មទាំងនោះ ។

តំបន់សេដ្ឋកិច្ចពិសេសត្រូវបានគេពិចារណាបង្កើតឡើងនៅទីកន្លែងណា ដែលអាចទាក់ទាញកំលាំងពលកម្មចំណាកស្រុក ដែលពួកគេមិនមានលទ្ធភាពក្នុងការទាមទារសិទ្ធិរបស់ពួកគេ ។ ភាពជោគជ័យនៃតំបន់សេដ្ឋកិច្ចពិសេសទាំងនេះ គឺពឹងផ្អែកទាំងស្រុងទៅលើកំលាំងពលកម្ម របស់ជនចំណាក ប៉ុន្តែផ្ទុយមកវិញជនចំណាកស្រុកទាំងនោះត្រូវទទួលខុសត្រូវចំពោះការកេងប្រវញ្ច័ ការឃាត់ខ្លួន និងការចាប់បញ្ជូនត្រលប់មកវិញ ។ ស្ថានភាពរបស់ជនចំណាកស្រុកនៅក្នុងប្រទេសថៃ និងម៉ាឡេស៊ីមានភាពផុយស្រួលណាស់ទោះបីជាពួកគេ ជាជនចំណាកស្រុកដែលមានឯកសារស្របច្បាប់ក៏ដោយ ។ និយោជក និងទីភ្នាក់ងារជ្រើសរើស បានដកហូតយកនូវឯកសារផ្ទាល់ខ្លួនរបស់គេ ទោះបីជាពួកគេមានសិទ្ធិក្នុងការរក្សារទុកឯកសាររបស់ពួកគេក៏ដោយ ។ ជនចំណាកស្រុកទាំងឡាយណាដែលមិនមានឯកសារស្របច្បាប់មានភាពភ័យខ្លាចក្នុងការឃាត់ខ្លួន ឃុំខ្លួន និងការបញ្ជូនត្រលប់មកវិញ នៅពេលដែលពួកគេចង់តវ៉ាពីការរំលោភបំពានពីលក្ខខណ្ឌការងាររបស់ពួកគេ។ នៅប្រទេសកម្ពុជាទោះបីជនចំណាកស្រុកមិនប្រឈមមុខនិងបញ្ហាអន្តោប្រវេសន៍ក៏ដោយ ក៏ពួកគេទទួលបានតិច

តូច ឬ មិនទទួលបានសុវត្ថិភាពការងារ និងជាពិសេសកិច្ចសន្យាការងាររបស់ពួកគេមានរយៈពេលខ្លី ៣ទៅ ៦ខែ ។ និយោជកបានទទួលផលចំណេញពីការកើនឡើងនៃការប្រកួតប្រជែង តាមរយៈការបង្កើនអោយមានស្ថានភាពមិនជាក់លាក់ និងការធ្វើអោយមានអស្ថិរភាពកំលាំងពលកម្មចំណាកស្រុកនៅក្នុងតំបន់ទាំងនោះ ។

ឧស្សាហកម្មនាំចេញ ដូចជាវិស័យវាយតណ្ឌ័ និងកាត់ដេនៅក្នុងប្រទេសកម្ពុជា ម៉ាឡេស៊ី និងថៃ និងវិស័យអេឡិចត្រូនិកនៅប្រទេសម៉ាឡេស៊ី ជាវិស័យដែលត្រូវមើលឃើញថាមានគ្រោះថ្នាក់ និងធ្វេសប្រហែសក្នុងការអនុវត្តនៅបទដ្ឋានប្រាក់ឈ្នួល និងលក្ខខណ្ឌការងារសំរាប់ជនចំណាកស្រុកជាស្ត្រី ។ នៅក្នុងប្រទេសទាំង៣ ដែលត្រូវបានលើកយកមកសិក្សាខាងលើនេះ ស្ត្រីចំណាកស្រុកប្រឈមមុខក្នុងការទទួលបានតម្រូវការមូលដ្ឋាន ត្រូវបានគេដាក់អោយធ្វើការងារច្រើនម៉ោងជាងកម្មករដែលធ្វើការងារនៅប្រទេសអង់គ្លេស ដើម្បីចំណាយទៅលើសំភារះរស់នៅប្រចាំថ្ងៃប៉ុណ្ណោះ ។ ម៉ោងធ្វើការងារធម្មតានៅក្នុងវិស័យវាយនតណ្ឌ័ និងកាត់ដេជារឿយៗវាំរំលោភទៅលើច្បាប់ការងារ ដែលកំណត់ម៉ោងធ្វើការងារ ៨ ម៉ោងតែមួយថ្ងៃ ។ នៅក្នុងប្រទេសទាំង ៣ ស្ត្រីទាំងអស់ដែលបានសំភាសបានអោយដឹងថា ម៉ោងធ្វើការងារធម្មតារបស់ពួកគេមានរយៈពេល ១០ ម៉ោង ។ និយោជកពិចារណាលើការងារលើសម៉ោងនៅពេលដែលកម្មករទាំងនោះធ្វើការងារលើសពី ១០ ម៉ោង ឬ ១១ ម៉ោង ហើយការងារថែមម៉ោងជារឿយត្រូវបានគេគិតនៅក្នុងអត្រាមួយ ដែលទាបជាងការកំណត់របស់ច្បាប់ការងារ។

ខណៈពេលដែលមានជនចំណាកស្រុកជាស្ត្រីជាច្រើន មានបំណងចង់សន្សំលុយផ្ញើត្រលប់មកផ្ទះមកវិញ ដោយសារតែប្រាក់ខែទាប ពួកគេបានព្យាយាមរក្សាការចំណាយពួកគេអោយនៅទាបហើយសំរាប់តែការចំណាយ ប្រចាំថ្ងៃប៉ុណ្ណោះ ដើម្បីសន្សំលុយផ្ញើត្រលប់មកផ្ទះវិញ ។ ទោះបីជាយ៉ាងនេះក៏ដោយ ពួកគេភាគច្រើនបានបញ្ជាក់ថា ប្រាក់ចំណូលរបស់ពួកគេ មិនគ្រប់គ្រាន់សំរាប់ឧបត្ថម្ភអោយបានសមរម្យទេ ហើយប្រាក់ដែលគេផ្ញើទាំងនោះគ្រាន់តែសំរាប់ការចំណាយប្រចាំថ្ងៃ និងសំរាប់ការរស់នៅប្រចាំថ្ងៃរបស់ក្រុមគ្រួសាររបស់ពួកគេប៉ុណ្ណោះ ។ ជនចំណាកស្រុកនៅប្រទេស ម៉ាឡេស៊ីកំរនិងផ្ញើប្រាក់ត្រលប់មកផ្ទះវិញនៅដំណាក់កាល ៦ ខែ តំបូង ដោយសារតែពួកគេ បានចំណាយថវិកាសំរាប់ទីភ្នាក់ងារជ្រើសរើស និងពន្ធផ្សេងៗដែលកាត់ដោយនិយោជករបស់ពួកគេ ។ បរិស្ថានការងារ

ដែលមានលក្ខណៈគ្រោះថ្នាក់ដល់រូបរាងកាយ ផ្លូវចិត្ត សុខមាលភាពរបស់ជនចំណាកស្រុកជាស្ត្រី ហើយជាពិសេសស្ត្រីដែលមិនអាចមានលទ្ធភាពទទួលបានការថែទាំងសុខភាព និងសេវាគាំទ្រផ្សេងៗទៀត ។

ស្ត្រីចំណាកស្រុកនៅក្នុងប្រទេសថៃ និងប្រទេសម៉ាឡេស៊ី មិនទទួលបានការបង់ប្រាក់ឈ្នួលនៅពេលមានជំងឺចំណែកនៅប្រទេសកម្ពុជាវិញ ស្ត្រីកម្មករោងចក្រកាត់ដេមានសិទ្ធិទទួលប្រាក់ឈ្នួល ប៉ុន្តែពួកគេមានឧបសគ្គនៅក្នុងទទួលបានប្រាក់ឈ្នួលនោះ ។ នៅក្នុងប្រទេសទាំង បី ជនចំណាកស្រុករស់នៅទីកន្លែងដែលនៅជិតរោងចក្រ ឬ នៅទីកន្លែងដែលអោយដោយនិយោជករបស់គេ។

ជារឿយៗទីកន្លែងស្នាក់នៅទាំងនោះមានលក្ខណៈតូចចង្អៀត និងមិនមានអនាម័យ ហើយលើសពីនេះទៅទៀតជនចំណាកស្រុកទាំងនោះក៏បានរាយការណ៍ ពីបញ្ហាអសន្តិសុខនៅកន្លែងដែលពួកគេ រស់នៅ និងពីទីកន្លែងដែលគេរស់នៅទៅកាន់ទីកន្លែងធ្វើការងាររបស់ពួកគេ ។

ស្ត្រីនៅក្នុងប្រទេសទាំងបីដែលបានលើកឡើងក្នុងករណីសិក្សានេះ ត្រូវបានគេបដិសេធសិទ្ធិទទួលបានសុខភាពផ្លូវភេទ និងប្រឈមមុខនិងការរើសអើង ប្រសិនបើពួកគេមានទំងន់ ។ នៅក្នុងប្រទេសម៉ាឡេស៊ី ស្ត្រីចំណាកស្រុកទាំងអស់ត្រូវបានចាប់បង្ខំអោយធ្វើការត្រួតពិនិត្យសុខភាព និងតេស្តដើម្បីពិនិត្យថាពួកគេមានទំងន់ ឬ អត់ មុនពេលជនចំណាកស្រុកទាំងនោះចូលក្នុងប្រទេសម៉ាឡេស៊ី ហើយអ្នកទាំងនោះនិងមិនត្រូវបានគេផ្តល់លិខិតអនុញ្ញាតអោយធ្វើការងារទេ ប្រសិនបើលទ្ធផលនៃការធ្វើតេស្តវិជ្ជមាន ។ ជាថ្មីម្តងទៀតស្ត្រីទាំងអស់នៅពេលមកដល់ប្រទេសម៉ាឡេស៊ី ពួកគេត្រូវចាប់បង្ខំអោយធ្វើតេស្តម្តងទៀត ហើយប្រសិនបើគេរកឃើញ ស្ត្រីទាំងនោះនិងត្រូវគេចាប់បង្ខំបញ្ជូនត្រលប់មកវិញ ។ នៅក្នុងប្រទេសថៃ គោលនយោបាយមិនបានដោះស្រាយបញ្ហាជនចំណាកស្រុកជាស្ត្រីដែលមានទំងន់ទេ ប៉ុន្តែទោះបីយ៉ាងនេះក៏ដោយ ស្ត្រីចំណាកស្រុកមិនអាចទទួលបានសិទ្ធិសំរាកមាតុភាពឡើយ ហើយស្ត្រីទាំងនោះអាចស្នាក់នៅបាននៅក្នុងប្រទេសថៃបានលុះត្រាតែគេមានការងារធ្វើ ។ និយោជកភាគច្រើន បានបណ្តេញស្ត្រីដែលមានផ្ទៃពោះចេញពីការងារ ដែលបន្ទាប់មកស្ត្រីទាំងនោះបានបាត់បង់ស្ថានភាពស្របច្បាប់ដើម្បីរស់នៅក្នុងប្រទេសថៃ ។

ស្ត្រីចំណាកស្រុកនៅក្នុងប្រទេសទាំងបីខាងលើ មានឧបសគ្គចំបងក្នុងការចូលរួមយ៉ាងសកម្ម នៅក្នុងសកម្មភាពសហជីព ។ ប្រសិនបើគ្មានសហជីពទេ ស្ត្រីទាំងនោះមិនអាចអនុវត្តសិទ្ធិក្នុងការចរចារួម ហើយពួកគេត្រូវតែបន្តរការតស៊ូជាលក្ខណៈបុគ្គលជាមួយនិយោជករបស់គេ ហើយលទ្ធផលដែលទទួលបាននោះមិនអាចអោយមានការផ្លាស់ប្តូច្រើនទេ ។ នៅក្នុងប្រទេសថៃ ជនចំណាកស្រុកត្រូវបានគេអនុញ្ញាតអោយចូលជាសមាជិកសហជីព ប៉ុន្តែពួកគេមិនមានសិទ្ធិបង្កើតសហជីពទេ។ ដោយសារតែ ការធ្វើការងារច្រើនម៉ោង ការរឹតត្បឹតក្នុងការធ្វើដំណើរ ប្រាក់ឈ្នួលទាប និងបញ្ហាលំបាកក្នុងការប្រើប្រាស់ភាសារ បានបង្កើតជារនាំងមួយសំរាប់ស្ត្រីចំណាកស្រុក ក្នុងការចូលរួមសកម្មនៅក្នុងសហជីពថៃ ។ នៅប្រទេសម៉ាឡេស៊ី ជនចំណាកស្រុកក៏ត្រូវបានអនុញ្ញាតអោយចូលរួមជាសមាជិកសហជីពដែ ប៉ុន្តែភាគច្រើននៃកិច្ចសន្យាការងាររបស់ពួកគេបានហាមប្រាមពួកគេមិនអោយចូលរួម ឬពាក់ពន្ធ័សកម្មភាពសហជីព ។ ជាមួយគ្នានេះផងដែរ ទោះបីជាច្បាប់មិនបានហាមប្រាមស្ត្រីចំណាកស្រុកក្នុងការចូលរួម និងបង្កើតសហជីពនៅប្រទេសកម្ពុជាក៏ដោយ ក៏សហជីពឯករាជ្យមួយចំនួនបានអនុវត្តសកម្មភាពរបស់ខ្លួនក្នុងស្ថានភាពគ្រោះថ្នាក់ និង ភ័យខ្លាច ។

ស្ត្រីចំណាកស្រុកកំរនិងដឹងថាតើអ្នកបញ្ជាទិញណាមួយដែលគេផលិតអោយ ហើយនេះជាកត្តាមួយដែលធ្វើអោយអំណាចក្នុងការចរចាររបស់ពួកគេមានភាពទន់ខ្សោយ ។ កម្មករមិនបានដឹង ពីក្រមសិលធម៌ដែលគ្របដណ្តប់នៅរោងចក្រដែលគេធ្វើការនោះទេ ទោះបីជាមានជនចំណាកស្រុកដែលធ្វើការងារនៅក្នុងប្រទេសថៃ និង ម៉ាឡេស៊ីធ្លាប់បាននិយាយថាពួកគេធ្លាប់ឃើញតំណាង របស់អ្នកបញ្ជាទិញធំៗ ឬ ជនបរទេសមកទស្សនកិច្ចរោងចក្រគេក៏ដោយ ។ នៅក្នុងករណីសិក្សារបស់ប្រទេសម៉ាឡេស៊ី និន្នាការនៃការប្រើប្រាស់កិច្ចសន្យាការងារបន្តដើម្បីគេចវេសពីការជួលដោយផ្ទាល់បានធ្វើអោយមានភាពមិនច្បាស់លាស់ ថាតើនណាជាអ្នកទទួលខុសត្រូវស្របច្បាប់លើកម្មករទាំងនោះ ហើយជាលទ្ធផលមាននិយោជកជាច្រើនបានគេចវេសពីការតព្វកិច្ចរបស់ពួកគេ ក្នុងការការពារសិទ្ធិរបស់កម្មករទាំងនោះ ។ អង្គការនៅថ្នាក់មូលដ្ឋាន ដែលបានលើកយកមកសិក្សានៅក្នុងប្រទេសទាំងបីដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះ បានបញ្ជាក់ពីសារសំខាន់នៃការចងក្រងបណ្តាញនិងកិច្ចសហការគ្នាជាលក្ខណៈអន្តរជាតិ ដើម្បីដាក់សំពាធទៅលើរដ្ឋាភិបាល អ្នកបញ្ជាទិញអន្តរជាតិនិងរោងចក្រអោយគោរពសិទ្ធិកម្មករ ។

War on Want កំពង់តែធ្វើយុទ្ធនាការ ដើម្បីអោយកម្មករទាំងអស់ ដែលធ្វើការងារអោយក្រុមហ៊ុន អង់គ្លេស អោយទទួលបានប្រាក់ឈ្នួល និង លក្ខខណ្ឌការងារសមរម្យនៅគ្រប់ទីកន្លែងទាំងអស់នៅលើពិភពលោកយើងនេះ ។ ដើម្បីអោយសំរេចលទ្ធផលនេះ យើងស្នើសុំអ្នកអានទាំងអស់ ៖

១. អំពាវនាវដល់រដ្ឋាភិបាលអង់គ្លេសអោយបញ្ឈប់ក្រុមហ៊ុនរបស់ខ្លួនកុំអោយបន្តធ្វើអាជីវកម្មលើវិស័យកាត់ដេរ ។ War on Want អំពាវនាវរាជរដ្ឋាភិបាលអង់គ្លេសអោយបង្កើតគណៈកម្មាធិការជំនាញមួយ ដែលទទួលបន្ទុកលើបញ្ហា ជំនួញ សិទ្ធិមនុស្ស និងបរិស្ថាន ដើម្បីដាក់វិធានការអោយក្រុមហ៊ុនអង់គ្លេសទទួលខុសត្រូវរាល់ការកេងប្រវ័ញ្ចទាំងឡាយណាដែលកើតឡើងនៅតាមខ្សែសង្វាក់ផលិតកម្មរបស់ពួកគេ (រោងចក្រ) ។ គណៈកម្មាធិការដែលបង្កើតឡើងនេះត្រូវមានអំណាចក្នុងការអង្កេតរាល់ពាក្យបណ្តឹងដែលបានដាក់ដោយកម្មករដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាននៅក្នុងខ្សែសង្វាក់ផលិតកម្មដែលផ្គត់ផ្គង់អោយក្រុមហ៊ុនលក់រាយនៅអង់គ្លេស ។ ជាមួយគ្នានេះផងដែរាជរដ្ឋាភិបាលអង់គ្លេសត្រូវអនុវត្តតាមសេចក្តីអំពាវនាវរបស់អ្នកតំណាងពិសេសរបស់អង្គការ សហប្រជាតិទទួលបន្ទុកធុរកិច្ច និងសិទ្ធិមនុស្ស លោក John Ruggie ដែលអំពាវនាវអោយមានការបង្កើតយន្តការទទួលពាក្យបណ្តឹងមួយដែលមិនមានលក្ខណៈផ្លូវច្បាប់ ដើម្បីបំពេញបន្ថែមទៅលើប្រពន្ធ័យុត្តិធម៌ដែលមានស្រាប់ សំរាប់ទាមទារសំណងនៃការខូចខាត[xxvi] ។

សូមសរសេរមកលោក Rt Hon Kenneth Clarke QC រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមានអាសយដ្ឋាន 102 Petty, France, London, SWIH 9AJ ដើម្បីអំពាវនាវអោយមានការបង្កើត គណៈកម្មាធិការទទួលបន្ទុក ធុរកិច្ច សិទ្ធិមនុស្ស និងបរិស្ថាន ដើម្បីការពារសិទ្ធិកម្មករដែលធ្វើការងារនៅតាមខ្សែសង្វាក់ផលិតកម្មដែលផលិតសំលៀកបំពាក់សំរាប់អ្នកលក់រាយនៅប្រទេសអង់គ្លេស ។

២. ស្នើសុំដោយទទូចអោយបណ្តាក្រុមហ៊ុនដែលមានប្រភពមកពីប្រទេសកម្ពុជា ម៉ាឡេស៊ី និងថៃ អោយគោរពសិទ្ធិ និងសំលេងរបស់កម្មករនៅក្នុងខ្សែសង្វាក់ផលិតកម្មផ្គត់ផ្គង់របស់ពួកគេ ។ ការងារនេះរួមមានការពិគ្រោះយោបល់ជាមួយសមាគមកម្មករ ឬ អង្គការសង្គមស៊ីវិលនានាដែលពាក់ពន្ធ័ ។ ជួយគាំទ្រដើម្បីអោយពួកគេមានលទ្ធភាពបង្កើតសមាគម និងតំណាងពួកគេ និងធ្វើការទទួលស្គាល់ជាផ្លូវការសិទ្ធិរបស់កម្មករក្នុងការចរចាររួម ។

៣. អំពាវនាវដល់សមាជិកសភារបស់អ្នកអោយផ្សព្វផ្សាយជាសធារណៈដើម្បីបញ្ចប់ការកេងប្រវញ្ច័នៅក្នុងខ្សែសង្វាក់ផលិតកម្មដែលផលិតសំរាប់នាំចេញទៅបរទេស ។ សូមសរសេទៅសមាជិកសភារបស់ហើយអំពាវនាវដល់ពួកគេអោយ ៖

ក) គាំទ្រនូវការការបង្កើតអោយមាន គណៈកម្មាធិការទទួលបន្ទុក ធុរកិច្ច សិទ្ធិមនុស្ស និងបរិស្ថាន

ខ) អោយសមាជិកសភារបស់អ្នកចូលរួមនៅក្នុងក្រុមការងារសភា All-Party Parliamentarian Group on International Corporate Responsibilities: ធុរកិច្ច សិទ្ធិមនុស្ស និង បរិស្ថាន ។

ប្រសិនបើអ្នកមិនស្គាល់ឈ្មោះរបស់អ្នកទេអ្នកអាចស្វែងរកនៅក្នុង www.theyworkforyou.com

៤. ចូលរួម War on Want ដើម្បីនាំយកយុត្តិធម៌ជូនកម្មករនៅក្នុងពិភពលោកទាំងមូល ។ ការងារទាំងអស់ អាចសំរេចបានលុះត្រាតែមានការតាំងចិត្តគាំទ្រពីសាធារណជន សកម្មជនសហាជីពនៅក្នុងប្រទេសអង់គ្លេស ដើម្បីអោយ War on Want អាចបន្តនូវយុទ្ធនាការទាមទារសិទ្ធិសំរាប់កម្មករនៅក្នុងពិភពលោកទាំងមូល ។ សូមចូលរួមជាមួយពួកយើង ដោយចូលរួមជាសមាជិករបស់ War on Want នាថ្ងៃនេះ ។ លោកអ្នកអាចទៅកាន់ www.waronwant.org/ដើម្បីចូលរួមជាមួយពួកយើង ឬទំនាក់ទំនងមក ០២០ ៧៣២៤៥០៤៦។

**ឯកសារភ្ជាប់ទី១**

តារាងប្រៀបធៀបប្រាក់ឈ្នួល កំលាំងពលកម្មដែលប្រើប្រាស់ និងតំលៃសំភារះ

| | កម្ពុជា | | ថៃ (ប្រាក់ឈ្នួលពលករតាមការងារជាក់លាក់) | | ម៉ាឡេស៊ី | | អង់គ្លេស ប្រាក់ឈ្នួលអប្បបរិមា | |
|---|---|---|---|---|---|---|---|---|
| | តំលៃ | ចំនួនម៉ោងធ្វើការ | តំលៃ | ចំនួនម៉ោងធ្វើការ | តំលៃ | ចំនួនម៉ោងធ្វើការ | តំលៃ | ចំនួនម៉ោងធ្វើការ |
| អង្ករ (១ គ.ក) | ១១៧០៛ (១៧ ផេននី) | ១ ម៉ោង | ៣០បាត (៦០ ផេននី) | ជិត២ ម៉ោងកន្លះ | ៦ រីង្គីត (១.២០ ផោន) | ២.៧ ម៉ោង | ២ផោន | ២០នាទី |
| ប្រេងឆា (១.ល) | ៧០០០៛ (១.១០ ផោន) | ជិត ៦ ម៉ោង | ៥០បាត (១ផោន) | ៤ ម៉ោង | ៣.៩រីង្គីត (១.២០ ផោន) រដ្ឋាភិបាលជួយ ៨០ ផេននី | ១.៨ ម៉ោង | ១.៨០ ផោន | ១៨ នាទី |
| សាច់មាន់ (១ គ.ក) | ១៩០០៛ (៣០ ផេននី) | ស្ទើតែ ២ ម៉ោង | ៧៥បាត (១.៥០ ផោន) | ៦ ម៉ោង | ១.៩៥ រីង្គីត (៤ ផោន) | ៩ ម៉ោង | ២.៥០ ផោន | ២៥ នាទី |
| ស៊ាំង (១.ល) | ៥០០០៛ (៨០ ផេននី) | ច្រើនជាង ៤ ម៉ោង | ៤០បាត (៨០ ផេននី) | លើស ៣ ម៉ោង | ១.៩ រីង្គីត (១.២០ ផោន) រដ្ឋាភិបាលជួយ ៤០ ផេននី) | ប្រហែល ៤៥នាទី | ១.៣៥ ផោន | ប្រហែល ១៥នាទី |

# ឯកសារយោង

[i] The unelected military regime in Burma change the name of the  country to Myanmar: Researcher for this report prefer to use the name Burma until the people of that country have the opportunity to choose for themselves

[ii] Office of National Security Council figure, cited in the UNGASS country progress report: Thailand, United Nations, 2010

[iii] Vichaya Pitsuwan and  Nanchanok Wongsamuth, Thai Textile Exports Set to Pick Up, Bangkok Post, 23 July 2009

[iv] Nanchanok Wongsamuth, "Incentives Sought to Invest Oversea , Bangkok Post 7 January 2011

[v] Data on supply chain sourcing taken from company factory lists, annual report and other records

[vi] Minimum wages in Thailand vary by province. The 2010 rate for Bangkok and Samut Prakarn was 206 baths per day, increase in 2011 215 baths a day. In Chiang Mai it was 171 baths, increase 180 bath in 2011.

[vii] See, for example, the case of  Burmese migrant Charlie Tiyu, "Chained to a hospital bed with no escape", Bangkok post 3 February 2011

[viii] Labour and Social Trend in Cambodia 2010. Cambodia National Institute of Statistic and ILO, September 2010

[ix] Cambodian Women Migrant Worker : findings from a Migration Mapping Study, UNIFEM June 2006

[x] World Investment Report 2011: Non-Equity Modes of International Production and Development, UNCTAD, July 2011

[xi] Kaoru Natsuda, Kenta Goto Thobun, "Challenges to Cambodian Garment industry in the Global Garment Value  Chain", Working Paper No.90-3, Ritsumeikan Centre for Asia Pacific studies, July 2009

[xii] Kang Chandararot, Sok Sina and Liv Dennet, " Rapid Assessment of the impact of financial crisis in Cambodia", ILO Asia Pacific Working Paper Series, ILO, March 2009

[xiii] Measuring Competiveness and Labor Productivity in Cambodia's Garment Industry, USAID, June 2005

[xiv] Data on supply Chain sourcing taken from company factory lists, annual report and other records

[xv] Kong Sothanarith, "Unions Want Longer Contracts for Worker", VOA Khmer, 26 May 2010

[xvi] More than 2.3 billion foreign registered under 6P Programme, Burma (Malaysia National News Agency), 5 September 2011

[xvii] Asrul Hadi Abdullah Sani  "Foreign Worker Levy Hike 2011", Malaysian Insider, 20 May 2010

[xviii] Migration in Digital Age: Migrant Worker in Malaysian Electronics Industry, Malaysian Investment Development Authority,

[xix] "Industries in Malaysia: Textile and Apparel Industry " Malaysian Investment and Development Authority www.mida.gov.my

[xx] Thin Lei Win, "Sabah's stateless children seek official status, Alertnet, 23 August 2011; 'Malaysia' Joint United Nations Initiative on Mobility and HIV/AIDS in South East Asia, www.jumina.org; undocumented migrant and refugees in Malaysia Raids, Detention and Discrimination, International Freedom for Human Rights and SUARA, March 2008

[xxi] Philip Robertson "Migrant Worker in Malaysia : issue, Concerns and Points for Action" Fair Labor association, October 2008

[xxii] Data from  Malaysian Investment Development Authority, cites in Migration and a Digital Age: Migrant Worker in the Malaysian Electronics Industry, WEED, December 2010

[xxiii] Data on supply chain sourcing taken from company factory lists, annual report and other records

[xxiv] For convenience of illustration, the conversion rate from Malaysian Ringgit to sterling has been rounded up through this report to5 RM= 1 £.

[xxv] Sylvia Looi, Flooren A, Samy and A. Raman, "Subra: No reason for boss to hold passports"'

[xxvi] Guiding Principle on Business and Human Rights: Implementing the United Nations "Protect, Respect and Remedies Framework, Final report of the special representative of the Secretary General on the issue of human Right and transactional corporation and other business enterprises, John Ruggie, UN document A/HCR/17/31. 21 March 2011